មាតិការឿង

១. បទសម្ភាសន៍របស់វិទ្យុខ្មែរប៉ុស្តិ៍ ០២
២. អង់គ្លេស ០៣
៣. គណបក្សនយោបាយចំនួន១០ប្តេជ្ញាចិត្ត... ០៤
៤. អតីតព្រះមហាក្សត្រអភ័យទោស.......... ០៥
៥. សុខភាព.. ១១
៧. "បណ្តឹងចំពោះខ្មែរប៉ុស្តិ៍ ", ជីវិតអកុសល... ២០
៦. តាម៉ុក និយាយពីសេដ្ឋកិច្ច.................. ២៣

ខ្មែរប៉ុស្តិ៍
The Khmer Post

KHMER BILINGUAL BIWEEKLY NEWSPAPER

VOLUME 02 ISSUE 19 August 09th-23th 2008 ADVERTISING (267) 253-3947 WWW.THEKHMERPOST.COM

Lynn Skin Care
Professional Esthetician
215-467-4082
Lynn Skin Care
Lynn Skin Care ជាជម្រើសចិត្ត របស់លោកអ្នក !
Sale & Skin Care Consultant: Lynn B. Kong
Open 7 Days A Week: Sun to Thurs: 10 a.m. - 7 p.m. / Fri. & Sat: 10 a.m. - 8 p.m.
1730 Snyder Avenue, Philadelphia, Pa 19145

ការដឹកនាំប្រទេសថ្មីធ្លាក់ក្នុងកណ្តាប់ដៃមនុស្សដដែលៗ

ភ្នំពេញ : ចាន់កុសល

- ពលរដ្ឋរាប់ម៉ឺននាក់គ្មានឈ្មោះបោះឆ្នោត
- ប្រតិកម្មរបស់អង្គការឃ្លាំមើលការបោះឆ្នោត
- គណបក្សធំបដិសេធលទ្ធផលបោះឆ្នោត
- លទ្ធផលបណ្តោះអាសន្ន

(តទៅទំព័រទី១៧)

សិក្ខាកម្មវិធីបង្កើនថាមពលដើម្បីអប់រំកូនចៅ " PEAK "

ខ្មែរប៉ុស្តិ៍ •••ហ្វីឡាដែលហ្វីយ៉ា (តទៅទំព័រទី១៤)

ថៃនាំមន្ត្រីយោធាអមស្ថានទូត១១ប្រទេសមកពិនិត្យតំបន់ជម្លោះប្រាសាទព្រះវិហារ

ដោយ : ម៉ម ឃិន

•••ព្រឹកថ្ងៃច័ន្ទ ទី២៨ ខែកក្កដា (តទៅទំព័រទី០៧)

លោក ជា ស៊ីម ប្រធានគណបក្សប្រជាជនកម្ពុជា

លោក សម រង្ស៊ី ប្រធានគណបក្ស សម រង្ស៊ី

លោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្ស

សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ប្រធានគណបក្ស រណឫទ្ធិ

ព្រះអង្គម្ចាស់ អរុណរស្មី ប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិច

ស្ថានភាពនៅកម្ពុជាក្រោយថ្ងៃបោះឆ្នោតជាតិ ឆ្នាំ២០០៨

ដោយ : ម៉ម ឃិន

•••ការបោះឆ្នោតសកលអាណត្តិទី៤ ដែលទើប តែបញ្ចប់ទៅ នៅថ្ងៃអាទិត្យទី ២៧ ខែកក្កដា ឆ្នាំ ២០០៨ នេះ ទោះបីជាគណកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនទាន់ប្រកាន់លទ្ធិផលជាផ្លូវការក៏ដោយក្តី គេក៏បានដឹងថា ជោគជ័យដ៏ធំធេងបានទៅលើគណបក្សប្រជាជនកម្ពុជា៩០អាសនៈ ហើយ និងគណបក្សផ្សេងៗមួយចំនួនក៏បានទទួលអាសនៈ ក្នុងរដ្ឋសភាបន្តិចបន្តួច គណបក្ស សម រង្ស៊ី ទទួលបាន ២៦អាសនៈ គណបក្សសិទ្ធិមនុស្សទទួលបាន៣អាសនៈ គណបក្សហ្វ៊ុនស៊ិនប៉ិចទទួលបាន២អាសនៈ និងគណបក្សនរោត្តម រណឫទ្ធិ ទទួលបាន ២អាសនៈ ។

បើតាមមតិទូទៅនៃមន្ត្រីថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជាបាននិយាយតាមប្រព័ន្ធសារព័ត៌មានរដ្ឋ និងសារព័ត៌មានឯកជនជាបន្តបន្ទាប់សរសើរថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានរៀបចំការបោះឆ្នោតបានល្អប្រសើរជាងអាណត្តិកន្លងទៅ ។

ចំណែកឯមតិរបស់អង្គការនៃក្រៅរដ្ឋាភិបាលជាតិខ្មែរ និងអន្តរជាតិទាំងនៅក្រុង និងក្រៅប្រទេសមួយចំនួន ជាពិសេសមេដឹកនាំគណបក្សចាញ់ឆ្នោត បានតាមដានត្រួតពិនិត្យសកម្មភាព នៅក្នុងថ្ងៃបោះឆ្នោត ឃើញថា មានការប្រព្រឹត្តខុសពីច្បាប់បទដ្ឋានជាតិ និងអន្តរជាតិ ដែលខុសពីប្រក្រតីខ្លាំងក្លាណាស់ ។

ភាពខុសប្រក្រតីដ៏ធ្ងន់ធ្ងរនោះ មានច្រើនយ៉ាង បើតាមការសង្កេតឃើញនៃមេគណបក្សចាញ់ឆ្នោតផ្ទាល់ និងអង្គការត្រួតពិនិត្យការបោះឆ្នោតនានា បានលើកឡើងអំពីការបាត់ឈ្មោះប្រជាពលរដ្ឋពីបញ្ជីបោះឆ្នោតមានចំនួនដល់ទៅរាប់លាននាក់ ព្រមទាំងមានអំណាចរំលោភបំពានពីសំណាក់មន្ត្រីមូលដ្ឋានស្ទើរតែពេញប្រទេសទាំងមូលពីអាជ្ញាធរកាន់អំណាច ដើម្បីប្រមែប្រមូលប្រជាពលរដ្ឋដែលស្ម័គ្រចិត្តបោះឆ្នោតបក្សកាន់អំណាច ទោះបីពុំមានឯកសារសំគាល់ខ្លួនត្រឹមត្រូវដូចម្តេចក៏ដោយ ជាពិសេសជនជាតិអន្តោប្រវេសន៍យួនខុសច្បាប់ ក៏មានអត្តសញ្ញាណខ្មែរទៅបោះឆ្នោតបានយ៉ាងពេញសិទ្ធិត្រឹមត្រូវបំផុតថែមទៀតផង ។

ដោយសារតែភាពខុសប្រក្រតី និងខុសពីបទដ្ឋានជាតិ និងអន្តរជាតិដ៏ជាក់ស្តែងនេះហើយ ដែលធ្វើឱ្យមានប្រតិកម្មពុះពារពីសំណាក់មេដឹកនាំគណបក្សមួយចំនួន និងប្រជាពលរដ្ឋរងគ្រោះ ដោយបាត់សិទ្ធិសេរីភាពរបស់ខ្លួន (តទៅទំព័រទី១០)

គ្រោះថ្នាក់នៃរបបលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សខ្មែរ

ដោយ : ពិន សំខុន

•••ឆ្នោត"ស្រឡាញ់"ចំពោះគណបក្សប្រជាជន មានដល់តំណាងរាស្ត្រចំនួនប្រមាណ៩០ អាសនៈ រីឯឆ្នោតមិនស្រឡាញ់គណបក្សប្រជាជនមានតែជាង៣០ប៉ុណ្ណោះ ។ ឃើញថា ចំនួន ២ ភាគ៣ នៃអាសនៈសភាជាតិស្ថិតនៅក្នុងកណ្តាប់ដៃនៃគណបក្សតែមួយ ដែលធ្លាប់មានប្រវត្តិជាគណបក្សដឹកនាំប្រទេសតាមបែបកុម្មុយនីស្ត ។

ខ្មែរគ្រប់រូបធ្លាប់បានភ្លក់រសជាតិនៃរបបកុម្មុយនីស្តនេះ បានយ៉ាងឆ្អែតឆ្អន់ ហើយនៅចាំភាពញ័ររន្ធត់ នៅពេលឮថា "អង្គការត្រូវការអ្នក "ម្តងៗ ។ គឺជាគណបក្សដែលផ្អែកទៅលើវិន័យរបស់បក្សធំ ជាង"សភាវល្អ" របស់សង្គមសេរី ។ ការបោះឆ្នោត នៅកម្ពុជា ដែលទើបនឹងកន្លងទៅថ្មីនេះ គឺជាគម្រោងនៃការកសាងរបបសេរីនិយមរៀបចំឡើង ដោយជំនួយនៃអង្គការសហប្រជាជាតិ តែលទ្ធផលនៃការបោះឆ្នោតលើកនេះ គឺជាលទ្ធផលផ្ទុយស្រឡះពីគម្រោងដើមរបស់វា ។ គណបក្សដែលមានសម្លេងលើស ២ភាគ៣ នៅក្នុងសភាជាតិ គឺអាចប្រព្រឹត្តអំពើផ្តាច់ការលើប្រជាជាតិរបស់ខ្លួន បានដោយស្របច្បាប់ ។

គេអាចជឿហើយឆ្ងល់ថា ហេតុអ្វីក៏ខ្មែរស្រឡាញ់គណបក្សប្រជាជន រហូតដល់ប្រគល់អំណាចផ្តាច់ការជូនទៅគេយ៉ាងដូច្នោះ ? ចម្លើយអាចនិយាយបានថា "ស្រឡាញ់ដោយបង្ខំ" (តទៅទំព័រទី១៧)

សូមអញ្ជើញស្តាប់វិទ្យុសម្លេងខ្មែរអាមេរិកាំង នៅ ហ្វីឡាដែលហ្វីយ៉ា FM/540 នៅរៀងរាល់ថ្ងៃសៅរ៍ ពីម៉ោង ៣ ដល់ ៤ រសៀល

បទសម្ភាសន៍របស់វិទ្យុខ្មែរប៉ុស្តិ៍


លោក ប៉ែន សុវណ្ណ

•••ជាមួយលោកអតីតនាយករដ្ឋមន្ត្រីសាធារណ រដ្ឋកម្ពុជាប្រជាមានិត ប៉ែន សុវណ្ណ បានឆ្លើយនឹងអំពីស្ថានភាពជីវិតរបស់លោកក្រោយពីបានយួនដោះលែងលោកឱ្យចេញពីគុកងងឹតក្រុងហាណូយ ប្រទេសវៀតណាមកុម្មុយនីស្ត ដោយសារមានអន្តរាគមន៍ពីរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ រ.ជ.ប.ខ ដឹកនាំដោយលោកតា សឺន សាន តាមរយៈអង្គការសហប្រជាជាតិ អ៊ុនតាក់ នាឆ្នាំ១៩៩៣ ។

ក្នុងសំនួរទី១ លោក ប៉ែន សុវណ្ណ បានឆ្លើយថា : មានអ្នកយកព័តិមាន បានសួរទៅលោក ហ៊ុន សែន អំពីករណីលោក ប៉ែន សុវណ្ណ ត្រូវធ្វើមាតុភូមិនិវត្តន៍ថា : កិច្ចគេសួរមួយទៀត នៅចំណុចទី៤ បើអត់ឱ្យមានសកម្មភាព នៅក្នុងគណបក្សប្រជាជនលើលោក ប៉ែន សុវណ្ណ ធ្វើមាតុភូមិនិវត្តន៍ឱ្យធ្វើអ្វី នៅក្នុងឆាកជីវិតរបស់គាត់ ? លោក ហ៊ុន សែន បានឆ្លើយថា : ខ្ញុំ និងគណបក្សប្រជាជនកម្ពុជានឹងបញ្ជូនលោក ប៉ែន សុវណ្ណ ឱ្យទៅនៅស្រុកកំណើតរបស់គាត់ ។ គាត់រកស៊ីធ្វើជាកសិករ ដូចជាប្រជាពលរដ្ឋខ្មែរដទៃទៀតដែរ អាហ្នឹងគាត់អីចឹង ។ មូលហេតុដែលគាត់យកខ្ញុំមកដាក់នៅ ហៅថា ភូមិស្នោ សព្វថ្ងៃនៅភូមិស្នោ ឃុំរកាក្នុង ស្រុកដូនកែវ ខេត្តតាកែវ ជាស្រុកកំណើតរបស់ខ្ញុំនៅក្បែរវាលបឹង ហេតុនេះ គ្មានរបបគ្មាននយោបាយ ដើម្បីឧបត្ថម្ភជាអតីតអ្នកតស៊ូរជន ដែលហ៊ានពលិកម្មដើម្បីជាតិមាតុភូមិ ក៏គ្មានឱ្យផ្ទះសម្បែងណាឱ្យត្រឹមត្រូវដូចជាពួកគេទេ ហើយដីនៅត្រង់ហ្នឹង ត្រូវដាំដំណាំដាំតាំងពីល្ហុង ដាំម្ទេស ដាំស្លឹកគ្រៃ ចិញ្ចឹមមាន់ ចិញ្ចឹមជ្រូក ដាំចេក លក់ស្រយូងចេក លក់ចេកខ្ចី លក់ចេកទុំ លក់ល្ហុង លក់ម្ទេស លក់ពងមាន់ លក់ជ្រូក លក់អ្វីដែលខ្ញុំចិញ្ចឹមតែអីចឹង ។ ពីព្រោះលោក ហ៊ុន សែន គាត់ថា បើអីចឹងទី១ អ្នកដែលជាមន្ត្រីរាជការ ក្នុងគណបក្សប្រជាជនកម្ពុជា គេមកខ្សឹបខ្ញុំថា : បើចង់ចូលបំរើក្នុងគនបក្សប្រជាចនកម្ពុជា សុំហាមពីរ : គឺទី១កុំចង្អៀតចង្អល់នឹងវៀតណាម កុំរិះគន់នឹងនិគមជនវៀតណាម ដែលមកតាំងទីលំនៅ នៅក្នុងស្រុកខ្មែរនេះ ។ បញ្ហាទី២ គឺថា កុំនិយាយពីរឿងមាន ១២តោន ពេជ្រ ២គីឡូ ដែលជាជ័យភ័ណ្ឌ ខ្ញុំយកពីរបប ប៉ុល ពត កាលពីឆ្នាំ១៩៧៩ ហើយយកមកដាក់រាត់រាយមិនទាន់មានធនាគារជាអ្នកគ្រប់គ្រងទេ យកមកទុកនៅក្នុងបរិវេណលំនៅស្ថានរបស់ខ្ញុំ ។ កាលណោះមានអង្គរក្សការពារខ្លះ កាលបើកែទម្រង់រចនាសម្ព័ន្ធរបស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ពេលហ្នឹងបានខ្ញុំមានគ្រប់វារៈ លក្ខណៈសម្បត្តិបក្សទាំងរដ្ឋាភិបាលផង ។

ខ្ញុំបានអញ្ជើញគណប្រតិភូគណបក្ស និងរដ្ឋាភិបាលមកចូលឃ្លាំងមាសហ្នឹងមាន៧២កេស ក្នុងមួយកេសមានទម្ងន់ ២៥០គីឡូ សុទ្ធតែមាស ដុំមាសនៅមានជានិច្ច ដល់ចំណុចត្រង់នេះ អ្នកយកព័តិមានខ្មែរប៉ុស្តិ៍ បានសួរគាត់ថា : លោក ប៉ែន សុវណ្ណ ត្រង់រឿងមាសនេះ ខ្ញុំសុំសួរកាត់បន្តិចថា តើមាសទាំងប៉ុន្មានហ្នឹង សព្វថ្ងៃនៅឯណា ?

លោក ប៉ែន សុវណ្ណ បាននិយាយបន្តថា : ចាំខ្ញុំជំរាបអស់សិនទៅ ពេលខ្ញុំចេញពីគុក ហើយមុននេះ ខ្ញុំបានប្រគល់ឱ្យគេហើយ កាលហ្នឹងខ្ញុំនៅកាន់អំណាច បានប្រគល់ឱ្យអ្នកដឹកនាំ ទាំងរដ្ឋភិបាល ទាំងបក្ស នៅម៉ោង ៨ព្រឹក ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៨១ ។ អស់លោកបានទទួលស្គាល់ ឆ្លើយថាមានមាសមែនពិត ហើយខ្ញុំឱ្យចុះហត្ថលេខាក្នុងសៀវភៅហ្នឹង ហើយដល់ទៅមាសហ្នឹងដល់ពេលខ្ញុំចេញពីគុក ខ្ញុំបានសួរកូនចៅចាស់ខ្ញុំ ខ្ញុំមិនប្រាប់ឈ្មោះគេទេ ថាមាសហ្នឹង គេយកទៅណាទៅ មាស ១២តោនជាង និងពេជ្រ ២គីឡូ តើយកទៅឯណា ? គេថា : គេបានចែកគ្នាអស់ទៅហើយ តាំងពីឆ្នាំ១៩៨៧ គេប្រាប់ខ្ញុំជាសម្ងាត់ ខ្ញុំក៏មិនប្រាប់ឈ្មោះគេដែរ ។ ហេតុនេះបានជាគេថា : បើអីចឹង កុំឱ្យរំលឹក កុំសួរពីរឿងមាស ឬគាស់កកាយពីរឿងមាស និងលក្ខណៈទី ២ កុំប្រឆាំងវៀតណាម និគមជនវៀតណាមមកតាំងលំនៅដ្ឋានក្នុងស្រុកខ្មែរ កុំរិះគន់ទៀត ។ បើធ្វើអីចឹងបានបក្សប្រជាជនកម្ពុជា គេឱ្យចូលរួមចំណែកក្នុងសកម្មភាពនយោបាយរបស់បក្សប្រជាជនកម្ពុជាវិញ អាហ្នឹងលក្ខណៈរបស់គេច្បាស់លាស់អីចឹង ខ្ញុំជំរាបបញ្ជាក់លោកអីចឹងដែរ ។

សំនួរ : ជុំវិញបញ្ហាដែលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បច្ចុប្បន្នហ្នឹង មិនចង់ឱ្យលោកទៅកាន់តំណែងណាមួយក្នុងគណបក្សប្រជាជនកម្ពុជាហ្នឹង ដោយសារលោកមានប្រជាប្រិយភាព ហើយជាមេចាស់ ពិបាកលោក ហ៊ុន សែន

(តទៅទំព័រទី០៦)

ប្តូរបរិយាកាស
សូមពិសាភេសជ្ជៈមួយកែវ
នៅបារ៍ TIPSY
BAR & LOUNGE
ជាហាងកូនខ្មែរធំធេងបំផុត នៅតំបន់ហ្វីឡាខាងជើង
ធីបស៊ី មាន "បារ៍" មាន "ឡោនជ៍"
ទទួលភ្ញៀវនិងរាំកំសាន្តយ៉ាងសប្បាយរីករាយ
ធីបស៊ី នឹងនាំឱ្យលោកអ្នកចង់រាំកំសាន្ត
Live D.J. every Fri & Sat night from 9 p.m. – 2 p.m.
(pool table)
មានក្រុមតន្ត្រីសម័យ ឬ DJ ចាក់ចម្រៀងពិរោះៗឱ្យស្តាប់
រៀងរាល់រាត្រី ថ្ងៃសុក្រ-ថ្ងៃសៅរ៍ ពីម៉ោង ៩ យប់ ដល់ម៉ោង ២ ភ្លឺ
មានតុបុកប៊ីយ៉ាទៀតផង

Ralph Rinn
Tel: 215.305.3763
Cell: 267.968.3413
Michael Lay (General Manager)
215.409.4772
Email: tipsybar@gmail.com

Sun-Thu: 10 – 12 a.m.
Fri & Sat: 10 – 2 a.m.
Kitchen Open Daily
Sun-Sat: 10 – 11 p.m.
3904 Frankford Ave.
Philadelphia, Pa 19124

ផ្កាយព្រឹក វីដេអូ
PKAY PREK VIDEO
(215) 455-2762
4935 OLD YORK RD. PHILADELPHIA, PA 19141
ជួលកុន_លក់ឌីវីឌី និង ស៊ីឌី
MOVIE RENTAL
DVD & CD SALES
លក់សំពត់អាវទៅបុណ្យទានសំរាប់ស្ត្រី និងសំពត់អាវ
ឬខោអាវដើរលេងធម្មតា សំរាប់ស្ត្រី និងកុមារ ។
CAMBODIAN FORMAL DRESSES.
WOMEN & BABY CASUAL WEARS

Since 1997
ក្រុមហ៊ុនទេសចរណ៍ខ្មែរ
ក្នុង និងក្រៅប្រទេស
LOW FARE TRAVEL, INC.
Domestic & International
OFFICE IN THE UNITED STATES
CALIFORNIA-FLORIA-ILLINIOS-N.COROLINA-MASSACHUSET
1800 s. 15TH Street. Philadelphia, Pa 19145 USA
មានសេវាបំរើ
-លក់សំបុត្រក្នុង/ក្រៅស្រុក
-ធ្វើ Passport
-ប្តូរ Passport
-បកប្រែឯកសារ
- Lawyer referrals
តម្លៃចុះថោក ពិសេសទៅស្រុកខ្មែរ,ឡាវ និងវៀតណាម
Special offers to Cambodia/Lao, Thai, & Vietnam:
- China
- Eva
- All Nippon
- Korean
- Singapore
- Thai
- Northwest
- Cathay
- Asiana
- Japan

ទៅលេងស្រុកខ្មែរ...
មានតម្លៃពិសេសជូនលោក លោកស្រី លោកយាយលោកតា បងប្អូន មីងមា ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ បុណ្យទូក អកអំបុក និងសំពះព្រះខែ ។ សូមជ្រើសរើសយន្តហោះ ដែលលោក លោកស្រី លោកយាយ លោកតា បងប្អូន មីងមា ចង់ជិះធ្វើដំណើរតាមចំណង់...
To book a reservation call @
PHONE 215-462-0886/CELL 215-833-3669
OFFICE HOURS
Monday-Friday 4-8 PM/EST
Saturday-Sunday 10-4 PM/EST
We're accepted all methods of payment. We're very proud to serve you for the last 11 years, and your business with is highly appreciated.

ឃោសនាបោះឆ្នោតនៅសហរដ្ឋអាមេរិក

ដោយ : លិនស៊ីដឺរីង

លោក លិស៊ីដឺរេង

●●●ការបោះឆ្នោតប្រធានាធិបតីអាមេរិកាំង កំពុងតែបន្តរវាងបារ៉ាក់ អូបាម៉ា បេក្ខជនស្បែកខ្មៅ និង ចន ម៉ាក់កេនបេក្ខជនស្បែកស ដោយម្នាក់ៗខិតខំបញ្ចេញស្នាដៃ និងសមត្ថភាពយ៉ាងអស្ចារ្យ ។

ពេលនេះ **លិនស៊ីដឺរីង** បានរំលឹកពីការបង្ហាញសមត្ថភាពរបស់បេក្ខជននីមួយៗ នៅក្នុងការឃោសនាថ្មីៗនេះ ស្តីអំពីកិច្ចការបរទេស និងសេដ្ឋកិច្ច ។ ពលរដ្ឋដែលជាម្ចាស់ឆ្នោត មានការប្រុងប្រយ័ត្នយ៉ាងខ្លាំង ដោយគេបង្ហាញ នៅក្នុងការស្ទង់មតិរបស់ប្រព័ន្ធផ្សព្វផ្សាយ ។

Campaign update
By Lindsay Doering

What goes up must come down. The Obama campaign has been living out this reality in the last couple of weeks. Sen. Obama's stunning tour of Europe and the Middle East, culminating in a stunning address to 200,000 people in Berlin, was meant to boost his foreign policy credentials here in the U.S. The tour may have made him appear more international, but it did not boost his standing in the polls. During this time, Sen. McCain was able to narrow gap in several key states.

The McCain campaign continues to be steady, unglamorous, competent and, possibly, dull. He has focused on key domestic issues including reducing U.S. reliance on foreign oil through creating incentives for alternate fuels as well as expanded exploration and production of domestic oil. He has emphasized issues over style; and, in advertisements, the campaign has criticized Obama for being an aloof celebrity, along the lines of Britney Spears and Paris Hilton.

How the Obama campaign responds to the inevitable down-tick in polls could determine the outcome of the race. If the campaign changes its message in response to polling data, Obama becomes less believable as a "new" kind of politician. Case in point: he recently indicated that he is open to the possibility of domestic offshore drilling. Many see this as a reversal of his prior position. Not good. However, if the campaign sticks to its original positions, as set forth in the primary, it will show him to be more statesman that celebrity.

Score the last couple of weeks in favor of McCain; however, the race is far from over.

បក្សប្រឆាំងខ្វះឱកាសក្នុងប្រព័ន្ធផ្សព្វផ្សាយអំឡុងការឃោសនាបោះឆ្នោត

ឡុងប៊ិច ,ខ្មែរប៉ុស្តិ៍ : សុភាឫទ្ធិ

ប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាមានលក្ខណៈលំអៀងទៅរកគណបក្ស CCP

●●●នៅប្រទេសដែលប្រកាន់លទ្ធិប្រជាធិបតេយ្យពិតប្រាកដ គណបក្សនយោបាយ និងបេក្ខជនតំណាងរាស្ត្រត្រូវបានគេផ្តល់សិទ្ធិឱ្យយ៉ាងពេញទំហឹងនូវប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសំរាប់បញ្ជូនសារដល់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតគ្រប់ទិសទី ។

ដោយឡែកនៅប្រទេសកម្ពុជាប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងរបស់រដ្ឋ និងឯកជនមួយភាគធំត្រូវគ្រប់គ្រងដោយគណបក្សកាន់អំណាច និងធ្វើការផ្សព្វផ្សាយពីសកម្មភាពរបស់មន្ត្រីជាន់ខ្ពស់របស់គណបក្សប្រជាជនកម្ពុជា ។ រីឯគណបក្សប្រឆាំងមិនត្រូវគេអនុញ្ញាតឱ្យបើកវិទ្យុ និងទូរទស្សន៍នោះទេ គឺពួកគេត្រូវបង្ខំចិត្តជួលម៉ោងសំរាប់ផ្សាយពីគោលនយោបាយក្នុង១ថ្ងៃ២ម៉ោងប៉ុណ្ណោះ ។ សំរាប់អ្នកកាសែតដែលមានមនសិការ ចំពោះវិជ្ជាជីវៈមិនព្រមចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា ហើយដកស្រង់នូវឯកសារ ឬសំដីអ្នកនយោបាយណាដែលរិះគន់មន្ត្រីជាន់ខ្ពស់ក្នុងរដ្ឋាភិបាលមកផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋបានដឹងនោះ គឺត្រូវគេបំបិទមាត់តាមរយៈការបាញ់ប្រហារ និងចាប់ដាក់គុកបំបាក់ស្មារតីយ៉ាងសាហាវឃោរឃៅខ្លាំងណាស់ ។

នៅប្រទេសកម្ពុជាសព្វថ្ងៃមានស្ថានីយវិទ្យុ និងទូរទស្សន៍៣៩កន្លែង និងកាសែតទស្សនាវដ្តីជាភាសាខ្មែរ និងបរទេសជាង២០០ ដែលភាគច្រើនសរសេរគាំទ្រមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជា (តទៅទំព័រទី០៥)

ទូរស័ព្ទពាណិជ្ជកម្មខ្មែរប៉ុស្តិ៍ហ្វីឡាដែលហ្វីយ៉ា
❖សុបិន : (២៦៧) ២៥៣-៣៩៤៧
❖ទូរស័ព្ទ នៅរ៉ូដអាយឡិន
❖សេរី : (៤០១) ៩១៩-៩៩៥៤
ទូរស័ព្ទវិទ្យុសម្លេងខ្មែរអាមេរិកាំង
❖ស៊ីជន : (២១៥) ២៨៤-១៣៤៣
Email : khmerpostec@gmail.com

ការិយាល័យនិពន្ធ
កាសែត " ខ្មែរប៉ុស្តិ៍ " ប្រចាំសហរដ្ឋអាមេរិក
ខ្សែខាងលិច
❖ មាជ សុវណ្ណារ៉ា
❖ គីម សារឿន
❖ ម៉ៅ ចិត្រា
❖ រ៉ា នាថ
❖ សុភា ឫទ្ធិ
❖ ម៉ី សម្ផស្ស
❖ ចាន់ កុសល
❖ សុវណ្ណារិទ្ធ
ខ្សែខាងកើត
❖ ពិន សំខុន
❖ សួន សេរី
❖ ម៉ម យិន
❖ គីម ភឿន
❖ ឆន យ៉ុង

HIGH TECH AUTO REPAIR
Foreign and Domestic
"ហាយតិច"
ជួសជុលរថយន្ត
មានជំនាញដូចខាងក្រោមៈ
- ធ្វើម៉ាស៊ីនឡាន
- ធ្វើភ្លើង "អេឡិចទ្រិច"
- ធ្វើបំពុងផ្សែង
- ធ្វើហ្វ្រាំង (BRAKE)
- ប្តូរប្រេង
- ធ្វើ "ការថ្លឹងភ្លើង" (TUNE UP)
- ត្រួតពិនិត្យ សុវត្ថិភាព នឹងផ្សែង (INSPECTION & EMISSION)

1601 Belfield Ave. Philadelphia, Pa 19141
Tel: 215-455-1344 Fax: 215-455-2085

គណបក្សនយោបាយចំនួន១០
ប្តេជ្ញាចិត្តប្រយុទ្ធប្រឆាំងអំពើពុករលួយ

ភ្នំពេញ ,ខ្មែរប៉ុស្តិ៍ : គីម សារឿន

•••ប្រធាន និងអ្នកតំណាងគណបក្សនយោបាយ ចំនួន១០ ក្នុងចំណោមគណបក្សនយោបាយ ១១ ដែលបានចុះបញ្ជីប្រកួតប្រជែងជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៤ ថ្ងៃទី២៧ កក្កដា ខាងមុខនេះ បានធ្វើការប្តេជ្ញាចិត្តយ៉ាងមុតមាំថានឹងបង្កើតច្បាប់ប្រឆាំងអំពើពុករលួយឱ្យខានតែបាន បន្ទាប់ពីបង្កើតរដ្ឋាភិបាលថ្មីរួច ។

ការជួបជុំគ្នានៃគណបក្សទាំង១០ ដែលរៀបចំឡើងដោយអង្គការ ខុមហ្វ្រែល កាលពីថ្ងៃទី៨ កក្កដា នោះ រួមមានគណបក្ស សម រង្ស៊ី, ហ្វ៊ុនស៊ិនប៉ិច, សិទ្ធិមនុស្ស, សង្គមយុត្តិធម៌, ខ្មែរសាធារណរដ្ឋ, ប្រជាធិបតេយ្យខ្មែរ, ខ្មែរឈប់ក្រ, ហង្សជារ៉ាចលនាប្រជាធិបតេយ្យ, នរោត្តម រណឫទ្ធិ និងសម្ព័ន្ធដើម្បីលទ្ធិប្រជាធិបតេយ្យ ។

គណបក្សនីមួយៗ បានប្រកាសយ៉ាងឧឡារិក នៅចំពោះអង្គការសង្គមស៊ីវិល និងម្ចាស់ឆ្នោតថា ប្រសិនបើគណបក្សរបស់ខ្លួនជាប់ឆ្នោត និងរៀបចំតាក់តែងច្បាប់ប្រឆាំងនឹងអំពើពុករលួយឱ្យចេញគឺយ៉ាងយូរបំផុតរយៈពេល៦ខែ បន្ទាប់ពីជាប់ឆ្នោតនៅថ្ងៃទី២៧ កក្កដា ។

វេទិកាពិភាក្សានយោបាយ
ស្តីពី
បញ្ហាអាទិភាពចំនួន ៣ របស់គណបក្សនយោបាយ
១៨ កក្កដា ២០០៨
សណ្ឋាគារ សាន់វេ
សហការរៀបចំដោយ :
Political Debate
on
Three Priorities of Political Platform
July 18, 2008
SUNWAY HOTEL
Co-organized by : COMFREL, NGO FORUM, DPA, CHRAC, ADHOC, PDP, KYA, YRDP, CPWP and YCC

គណបក្សនយោបាយទាំង១០ ប្តេជ្ញាចិត្តប្រយុទ្ធប្រឆាំងអំពើពុករលួយ

ប្រធាន និងអ្នកតំណាងគណបក្សនីមួយៗបានអះអាងថា ច្បាប់ប្រឆាំងនឹងអំពើពុករលួយដែលនឹងបង្កើតឡើងស្របតាមមាត្រដ្ឋានស្តង់ដាអន្តរជាតិ និងបំបាត់អំពើពុករលួយឱ្យអស់ ដើម្បីរៀបចំ

(តទៅទំព័រទី០៥)

ទៅណាទៀត ?

បន្ទាប់ពីជួបវេជ្ជបណ្ឌិតរួចហើយ

WASHINGTON AVENUE PHARMACY

នឹងជួយដល់តម្លៃទិញថ្នាំពេទ្យ ជាពិសេសចំពោះគ្រួសារ ដែលមានប្រាក់ចំណូលតិចតួច

កុំភ្លេចយក

ខ្ទាន់ដោយឥតគិតថ្លៃ

ខ្ទាន់នេះកំណត់បញ្ចប់ថ្ងៃ ៣០ កក្កដា ២០០៨

Travel Bag

នៅមានរង្វាន់ទីពីរទៀត



ជបវីតាមីនមួយ
វីតាមីន D
វីតាមីន C
វីតាមីនសំរាប់ស្ត្រី
វីតាមីនសំរាប់បុរស

ពិសេសសំរាប់អ្នកមានជំងឺទឹកនោមផ្អែម

FREE GLUCOMETER

* ស្រួលប្រើ
* លឿន
* ត្រឹមត្រូវ
* ឥតឈឺ

Washington Ave
PHARMACY
215-755-5100

* សំរាប់តែគ្នៀវជំបូងតែប៉ុណ្ណោះ

600 Washington ave, Unit 18E Phila, PA - phone: 215-755-5100

ម្ចាស់បេះដូងថ្មីទៅដល់ខ្ទមកំសត់

បាត់ដំបង ,ខ្មែរប៉ុស្តិ៍ : ម៉ី សមួស្ស

•••ក្បួនរថយន្តបានធ្វើដំណើរអស់រយៈពេលជាច្រើនម៉ោងទំរាំដល់ទឹកដីខេត្តបាត់ដំបង ដោយឆ្លងកាត់ព្រៃតូចធំ ផ្ទះសំបែងអ្នកស្រុករាប់មិនអស់ ទើបដល់ខ្ទមកំសត់របស់កុមារី ដាវិក ដែល ស្ថិតនៅកណ្តាលវាលស្រែក្នុងភូមិស្វាយជ្រុំ ឃុំជ្រៃ ស្រុកថ្មគោល ។

ទិដ្ឋភាពនៃខ្ទមកំសត់នៅពេលនេះខុសប្លែកពីធម្មតាមានមនុស្សគ្រប់វ័យបានមកសំដែងនូវការស្វាគមន៍ ក្នុងទឹកមុខស្រស់ប្រិមប្រិយចំពោះកុមារីបេះដូងប្រហោង ដែលទើបវិលត្រឡប់មកពីសហរដ្ឋអាមេរិក បន្ទាប់ពីបានព្យាបាលជាសះស្បើយថ្មីៗកន្លងទៅនេះ ។

ក្នុងពេលជាមួយគ្នានោះដែរ ក្រុមអង្គការបេះដូងគ្មានព្រំដែន និងក្រុមសាស្ត្រាចារ្យមកពីសហរដ្ឋអាមេរិកជាច្រើននាក់បានជូនដំណើរកុមារី ដាវិក ដល់លំនៅឋានដ៏កំសត់ថែមទៀត ។

ក្រុមគ្រួសាររបស់កុមារី ដាវិក មិនត្រឹមតែសំដែងនូវការសប្បាយរីករាយ និងដឹងគុណ ចំពោះអង្គការបេះដូងគ្មានព្រំដែនប៉ុណ្ណោះទេ ថែមទាំងបានរៀបចំពិធីសែនព្រេនហៅព្រលឹងតាមទំនៀមទំលាប់ប្រពៃណីព្រះពុទ្ធសាសនាថែមទៀតផង ។

ក្រុមគ្រួសារ និងអ្នកភូមិមានការអស់សង្ឃឹមចំពោះជំងឺរបស់ដាវិកថា គ្មានអ្នកណាអាចព្យាបាលបានទេ ហើយពួកគាត់គ្មានជំនឿថា អាចជួយសង្គ្រោះជីវិតមនុស្សឱ្យរស់រានមានជីវិតបានឡើយ ។

ប៉ុន្តែការគិតរបស់ពួកគាត់វាផ្ទុយស្រឡះទៅវិញ បន្ទាប់ពីអង្គការបេះដូងគ្មានព្រំដែនធ្វើការធានាកុមារី ដាវិក យកទៅព្យាបាលរយៈពេលជាង៥ខែ កាលពីដើមឆ្នាំ២០០៨នេះ នៅថ្ងៃទី១៨ ខែកក្កដា ដាវិក បានត្រឡប់មកដល់ផ្ទះសំបែងវិញ នាំមកនូវបេះដូងថ្មី និងសប្បុរសជនជាច្រើននាក់ថែមទៀត ធ្វើឱ្យអ្នកស្រុកមានការស្ងើចសរសើរយ៉ាងខ្លាំង ។

ក្នុងពិធីជួបជុំគ្នានៅឯខ្ទមកំសត់របស់ ដាវិក នេះអ្នកស្រុកក៏ដូចជាសមាជិកគ្រួសារ បានសំដែងនូវក្តីទីករលីកដាក់គ្នា និងបានលួចសរសើរពីភ័ព្វសំណាងរបស់ ដាវិក ដែលមានវាសនាប្តូរបាននូវបេះដូងថ្មី រួចផុតពីសេចក្តីស្លាប់ និងបានស្គាល់ពីទិដ្ឋភាពនានានៅឯសហរដ្ឋអាមេរិក ដែលមនុស្សគ្រប់គ្នាប្រាថ្នាចង់ឃើញចង់ទៅរស់នៅតែមិនមានភ័ព្វវាសនា ។

ប្រជាពលរដ្ឋ និងអង្គការបេះដូងគ្មានព្រំដែន នៅខ្ទមកំសត់កុមារី ដាវិក

អ្នកស្រុកសុំមើលស្លាកទះបេះដូងរបស់ ដាវិក

លោក ឆាង យួម អាយុ៥៨ឆ្នាំ រស់នៅភូមិស្វាយជ្រុំ ដែលបានមកចូលរួមអបអរសាទរនោះ បានឱ្យដឹងថា លោកពិតជាមានសេចក្តីរីករាយយ៉ាងខ្លាំងណាស់ចំពោះអង្គការបេះដូងគ្មានព្រំដែន ដែលបានជួយសង្គ្រោះ ដាវិក ឱ្យរួចផុតពីសេចក្តីស្លាប់ ។ ជាពិសេសជួយឱ្យអស់ពីពោះពីពុងមិនទាមទារបានគុណស្រែអ្វីទាំងអស់ ដែលធ្វើឱ្យខ្ញុំជាអ្នកភូមិមានការរំភើបក្នុងចិត្តរកអ្វីមកថ្លែងពុំបានឡើយ ។

ចំណែកលោក ឃិន ពុង អាយុ៦៦ឆ្នាំ ជាមេជាងរបស់អ្នកស្រី ឈន ស៊ិន បានឱ្យដឹងថា ម្តាយរបស់ ដាវិក នេះក្រខ្លាំងណាស់ ហើយនាងធ្វើជាកម្មករសំណង់ជាមួយគាត់បានកំរៃតិចតួចណាស់ សំរាប់ដោះស្រាយជីវភាពរស់នៅ និងព្យាបាលជំងឺកូនច្រើនឆ្នាំមកហើយតែមិនជាសោះ ។

លោក ឃិន ពុង បន្តថា មួយរយៈនេះស្រាប់តែឃើញអង្គការបេះដូងគ្មានព្រំដែនយកទៅព្យាបាលនៅសហរដ្ឋអាមេរិក ហើយពេលនេះឃើញត្រឡប់មកវិញថា បានជាសះស្បើយនោះលោកសប្បាយខ្លាំងណាស់ ពីព្រោះ ដាវិក អ្នកភូមិយើងគ្មានសង្ឃឹមថា មានជីវិតរស់រាននោះទេ ។

(តទៅទំព័រទី២១)

បក្សប្រឆាំងឧបសគ្គក្នុង...

និងមានកាសែតក្នុងស្រុកតិចតួចបំផុត ដែលមាននិន្នាការគាំទ្រគណបក្សប្រឆាំង ដែលផ្សព្វផ្សាយក្នុងស្រុកតិចតួចបំផុត ដែលមាននិន្នាការគាំទ្រគណបក្សប្រឆាំង ដែលផ្សព្វផ្សាយបានតែនៅទីប្រជុំជនប៉ុណ្ណោះ ។

យោងតាមរបាយការណ៍នៃវិទ្យាស្ថានជាតិ ដែលបានធ្វើការវាយតំលៃពីស្ថានភាពមុនការបោះឆ្នោត បានឱ្យដឹងថា សារព័ត៌មានជាភាសាខ្មែរមួយភាគធំពាក់ព័ន្ធនឹងគណបក្សនយោបាយរួមទាំងគណបក្សប្រឆាំង និងការរិះគន់រដ្ឋាភិបាលជាញឹកញាប់ ហើយទោះជាយ៉ាងណាសារព័ត៌មានទាំងនោះទៅដល់ដៃប្រជាជនតិចតួចណាស់ ។

របាយការណ៍នោះបន្តថា ក្នុងចំណោមស្ថានីយវិទ្យុជាង៣០ មានតែស្ថានីយវិទ្យុសំបុកឃ្មុំ FM- 105 បានផ្តល់ឱកាសឱ្យមហាជនបញ្ចេញមតិរិះគន់រដ្ឋាភិបាល និងធ្វើការជួលម៉ោងផ្សាយឱ្យគណបក្ស សម រង្ស៊ី គណបក្សនរោត្តម រណឫទ្ធិ និងគណបក្សសិទ្ធិមនុស្ស ។

គណបក្សប្រឆាំងបានដាក់ពាក្យជាច្រើនលើក ដើម្បីសុំអាជ្ញាប័ណ្ណបើកវិទ្យុ ប៉ុន្តែត្រូវគេច្រានចោល ហើយខាងគណបក្សប្រជាជនកម្ពុជា គេអនុញ្ញាតឱ្យ ។ ស្ថានីយទូរទស្សន៍៧ គឺរបស់រដ្ឋ១ និងឯកជន៦ ត្រូវគ្រប់គ្រងដោយផ្ទាល់ និងប្រយោលដោយរដ្ឋាភិបាល ។

ចំណែកកម្មវិធីសមធមិ ដែលឧបត្ថម្ភដោយ UNDP នៅទូរទស្សន៍ជាតិកម្ពុជានោះ គឺផ្តល់រយៈពេល១ម៉ោងរៀងរាល់សប្តាហ៍សំរាប់រិះគន់រដ្ឋាភិបាល និងរយៈពេល២០នាទីរៀងរាល់ថ្ងៃមុនពេលបោះឆ្នោតសំរាប់គណបក្សនយោបាយទាំងអស់ ។

ជាភស្តុតាងនៃការបិទវិទ្យុរវដ្តា FM-105. 25 MHz ខេត្តក្រចេះ កាលពីថ្ងៃទី២៨ ខែ ឧសភា ឆ្នាំ ២០០៨ ដោយលោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រី ក្រសួងព័ត៌មាន ដោយយកលេសថា វិទ្យុនេះ មិនបានសុំច្បាប់អនុញ្ញាតសំរាប់ការផ្សព្វផ្សាយ ម៉ោងជួលឱ្យគណបក្ស សម រង្ស៊ី គណបក្សនរោត្តម រណឫទ្ធិ និងគណបក្សសិទ្ធិមនុស្សគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសម្ព័ន្ធដើម្បីលទ្ធិប្រជាធិបតេយ្យ ។

ការបិទវិទ្យុអង្គរដ្ឋាខេត្តក្រចេះនេះ ធ្វើឱ្យគណបក្សដែលជួលម៉ោងផ្សាយពីកម្មវិធីនយោបាយ និងអង្គការសង្គមស៊ីវិលមានប្រតិកម្ម ហើយស្នើទៅលោករដ្ឋមន្ត្រីក្រសួងព័ត៌មានធ្វើការពិចារណាបញ្ហានេះឡើងវិញ ។

លោក សុន ឆ័យ សមាជិកសភាមកពីគណបក្ស សម រង្ស៊ី បានបញ្ជាក់ក្នុងលិខិតរបស់លោកថា ក្រសួងព័ត៌មានគួរតែធ្វើការពិចារណាអនុញ្ញាតឱ្យវិទ្យុអង្គរដ្ឋាធ្វើការផ្សព្វផ្សាយឡើងវិញ ។ តាមគោលការណ៍ច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់សារព័ត៌មានមិនមានការផ្តល់ឱ្យរដ្ឋមន្ត្រីក្រសួងព័ត៌មាននូវសិទ្ធិបិទការផ្សព្វផ្សាយដោយសារការខកខានមិនបានស្វែងរកការអនុញ្ញាតមុនពេលលក់ម៉ោងផ្សាយនោះទេ ។

លោកបញ្ជាក់ថា "ការបិទវិទ្យុនេះ គឺជាការរើសអើងនយោបាយ និងរំលោភច្បាប់" ។

ចំណែកលោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មានដែលដកស្រង់សំដីដោយ The Cambodia Daily បានឱ្យដឹងថា ការបិទវិទ្យុ FM-105.25 ដោយសារផ្សាយបន្តពីបរទេសគ្មានការអនុញ្ញាត ហើយលោកមិនខ្វល់ពីការលក់ម៉ោងផ្សព្វផ្សាយឱ្យគណបក្សណាទេ ។ លោក ខៀវ កាញារីទ្ធ បន្តថា បើសិនជាក្រុមអាល់កៃដាមកជួលម៉ោងផ្សព្វផ្សាយវានឹងទៅជាយ៉ាងណា? ដូច្នេះពួកគេត្រូវតែស្នើសុំទៅក្រសួងជាមុនសិន ។

ចំណែកលោក កែវ ចាន់រដ្ឋា ម្ចាស់ស្ថានីយវិទ្យុ FM-105.25MHz ខេត្តក្រចេះ បានឱ្យដឹងថា វិទ្យុរបស់លោក ទើបដំណើរការផ្សព្វផ្សាយលក់ម៉ោងចាប់ពីថ្ងៃទី១៥ ខែ ឧសភា ឱ្យគណបក្សនយោបាយនានា ហើយត្រូវបិទទៅវិញ នៅថ្ងៃទី២៨ ខែឧសភាកន្លងមកនេះ ។

លោក កែវ ចាន់រដ្ឋា បញ្ជាក់ថា រហូតមកដល់ពេលនេះ លោកមិនទាន់យល់ព្រមលក់ម៉ោងផ្សាយឱ្យវិទ្យុបរទេសនោះទេ ទោះបីខាងវិទ្យុអាស៊ីសេរី និងវិទ្យុសំលេងសហរដ្ឋអាមេរិក នៅដើម ខែ កញ្ញា នេះយ៉ាងណាក៏ដោយ ។

ជាមួយគ្នានេះដែរ លោកស្រី ពុង ឈីវកេក ប្រធានអង្គការសិទ្ធិមនុស្សលីកាដូ បានប្រាប់អ្នកកាសែតថា ការបិទស្ថានីយវិទ្យុយ៉ាងតក់ក្រហល់បែបនេះ គឺឆ្លុះបញ្ចាំងពីការខ្វះឆន្ទៈប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ក្នុងការអនុញ្ញាតឱ្យមានលទ្ធិប្រជាធិបតេយ្យការពិភាក្សានៅមុនពេលបោះឆ្នោត ។

លោកស្រី ពុង ឈីវកេក បន្តថា ទង្វើនេះ បង្ហាញឱ្យឃើញថា សេរីភាពនៃសារព័ត៌មានការបញ្ចេញមតិត្រូវបានគ្រប់គ្រងតឹងតែង នៅតាមស្ថានីយវិទ្យុ និងទូរទស្សន៍នៅកម្ពុជា ។

ថ្មីៗនេះលោក ដាំ សិទ្ធិ និពន្ធនាយកកាសែតមនសិការ ដែលគ្រាន់ តែដកស្រង់សំដីរបស់លោក សម រង្ស៊ី មកចុះផ្សាយត្រូវតុលាការក្រុងភ្នំពេញ ចោទប្រកាន់ពីបទបរិហាកេរ្តិ៍ ហើយចេញដីការឱ្យប៉េអឹមចាប់ដាក់គុកព្រៃស ។

គួរបញ្ជាក់ថា កន្លងមកគណបក្សប្រឆាំង និងអង្គការសង្គមស៊ីវិល បានធ្វើការស្នើសុំបើកស្ថានីយវិទ្យុ និងទូរទស្សន៍ជាច្រើនលើកច្រើនសារ ប៉ុន្តែក្រសួងព័ត៌មានមិនអនុញ្ញាតច្បាប់ឱ្យទំនងខ្លាចអ្នកស្រុក ដែលរស់នៅតាមជនបទយល់ដឹងពីគោលនយោបាយរបស់គណបក្សប្រឆាំង ។

ជាមួយគ្នានេះដែរ បើសិនជាឧកញ៉ា និងអ្នកតំណាងរាស្ត្រដែលជាអ្នកមាននិន្នាការទៅរកគណបក្សប្រជាជនកម្ពុជា ក្រសួងព័ត៌មានអនុញ្ញាតឱ្យភ្លាម និងនិយាយថាប្រេកង់នៅរលកធាតុអាកាសទូលាយណាស់ ។ សព្វថ្ងៃនេះស្ថានីយវិទ្យុ និងទូរទស្សន៍ មាន៣៥កាសែត ដែលចុះ ក្នុងបញ្ជីជាង៣០០តែរស់រានមានជីវិតប្រមាណ១០ប៉ុណ្ណោះ ។ ចំណែកទស្សនាវដ្តីមានជាង១០០ ដែលក្នុងនោះ កំពុងដំណើរការងារលើទីផ្សារប្រមាណ២០ប៉ុណ្ណោះ ៕

គណបក្សនយោបាយចំនួន១០...

ប្រទេសឱ្យមានការរីកចំរើនឆាប់រហ័ស ។ ដោយបង្កើតស្ថាប័នឯករាជ្យផ្តល់សិទ្ធិអំណាចឱ្យស្ថាប័ននីតិបញ្ញត្តិការពារសាក្សី និងប្រកាសទ្រព្យសម្បត្តិផ្ទាល់ខ្លួន ។

លោក គល់ បញ្ញា នាយកគណៈកម្មាធិការ ដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ហៅកាត់ថា (ខុមហ្វ្រែល) បានថ្លែងក្នុងវេទិកានោះថា ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយត្រូវការឆន្ទៈនយោបាយក្នុងការធ្វើច្បាប់អនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព ។

លោក គល់ បញ្ញា បន្តថា អំពើពុករលួយនៅកម្ពុជានរណាក៏ទទួលស្គាល់ថាមានការរីកដុះដាល ខ្លាំងលើគ្រប់វិស័យ ទាំងវប្បធម៌ សង្គមកិច្ច សេដ្ឋកិច្ច និងនយោបាយ គឺចាប់តាំងពីលើដល់ក្រោម ។ ចំណែកឯប្រព័ន្ធតុលាការ, សុខាភិបាល, អប់រំ ការគ្រប់គ្រង ធនធានធម្មជាតិ ក៏គ្របដណ្តប់ ដោយអំពើពុករលួយ ខ្លាំងដែរ ដែលធ្វើឱ្យរាំងស្ទះដល់ការអភិវឌ្ឍន៍សង្គមជាតិ ។

លោក គល់ បញ្ញា បញ្ជាក់ថា ការពិភាក្សាគ្នា ពេលនេះ ក្នុងគោលបំណងបង្កើតច្បាប់ប្រឆាំងនឹងអំពើពុករលួយ ដោយរិះរកវិធានការណ៍ការពារឱ្យមានប្រសិទ្ធភាព ដើម្បីឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតមើលឃើញពីឆន្ទៈរបស់គណបក្សនីមួយៗឱ្យកាន់តែច្បាស់ ។

លោក លន់ ឫទ្ធី គណបក្សខ្មែរសាធារណរដ្ឋបានឱ្យដឹងថា គណបក្សរបស់លោក ប្តេជ្ញាចិត្តប្រយុទ្ធប្រឆាំងឱ្យខានតែបាន ចំពោះអំពើពុករលួយ គឺត្រូវលុបបំបាត់ចោល និងធ្វើវិន័យទោសទណ្ឌតាមកំរិតរបស់បុគ្គលដែលបានប្រព្រឹត្ត ។

ចំណែកលោក មុត ចន្ថា អ្នកនាំពាក្យគណបក្ស នរោត្តម រណឫទ្ធិ បានឱ្យដឹងថា លោកសូមសំដែងនូវការគាំទ្រយ៉ាងពេញទំហឹង ពីព្រោះវេទិកានោះ ស្របទៅតាមកម្មវិធីនយោបាយរបស់គណបក្សលោក ។ អំពើពុករលួយនេះបានប៉ះពាល់ដល់ជីវភាពរស់នៅប្រជាពលរដ្ឋយ៉ាងខ្លាំង ពីព្រោះដោយសារតែគ្មានច្បាប់ប្រឆាំងនឹងអំពើពុករលួយនេះ ហើយធ្វើឱ្យអ្នកកាន់អំណាចសព្វថ្ងៃមួយចំនួនធំប្រព្រឹត្តអំពើផ្តេសផ្តាស ។

រីឯលោក យឹម សុវណ្ណ តំណាងគណបក្ស សម រង្ស៊ី បានបញ្ជាក់ថា គណបក្ស សម រង្ស៊ី បានប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយអស់រយៈពេលជាង ៣អាណត្តិមកហើយ ។ នៅពេលគណបក្សលោកជាប់ឆ្នោតនឹងជំរុញឱ្យច្បាប់ប្រឆាំងអំពើពុករលួយចេញមុខគេ និងអនុវត្តប្រកបដោយប្រសិទ្ធភាពបំផុត ។

ក្នុងចំណោមគណបក្សទាំង១១ ដែលបានចុះក្នុងបញ្ជីបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រមានតែគណបក្សប្រជាជនកម្ពុជាទេ ដែលអវត្តមាន ហើយលោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងជាអ្នកនាំពាក្យរបស់រដ្ឋាភិបាលបានប្រាប់អ្នកកាសែតថា គណបក្សប្រជាជនមិនមានពេល និងមិនចាប់អារម្មណ៍ក្នុងវេទិកានោះទេ ។

លោកស្រី ពុង ឈីវកេក ប្រធានអង្គការសិទ្ធិមនុស្សលីកាដូ បានសំដែងនូវការសោកស្តាយ ចំពោះគណបក្សប្រជាជនកម្ពុជា ដែលខកខានមិនបានចូលរួមពិភាក្សាពីច្បាប់ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនោះ ។

យោងតាមរបាយការណ៍របស់អង្គការ usaid សហរដ្ឋអាមេរិក បានបញ្ចេញរបាយការណ៍ស្តីពី អំពើពុករលួយ ដែលប្រព្រឹត្តដោយមន្ត្រីរដ្ឋាភិបាលកម្ពុជា ក្នុង១ឆ្នាំប្រមាណពី ៣០០ ទៅ ៥០០ លានដុល្លារ ។

គួរបញ្ជាក់ថា កាលពីថ្ងៃទី១៦ ឧសភា កន្លងមកនេះ អង្គការសមាគមជាង ៤០ បាននាំយកមេដៃជាង១លាននាក់របស់ប្រជាពលរដ្ឋ និងមន្ត្រីរាជការ ដែលសុំឱ្យអនុម័តច្បាប់ប្រឆាំងនឹងអំពើពុករលួយឱ្យបានឆាប់ទៅមុខរដ្ឋសភា ប៉ុន្តែស្នាមមេដៃទាំងនោះ ត្រូវសភាមិនទទួលយក ដោយយកលេសថា ចង្អៀតគ្មានកន្លែងទុក ៕

ខ្មែរប៉ុស្តិ៍មានសេចក្តីរីករាយ និងណែនាំដល់សហគមន៍ខ្មែរ

ឱសថស្ថានយើងនឹងជួយលោកអ្នកអំពីតម្លៃថ្នាំ ជាពិសេសដល់គ្រួសារដែលមានប្រាក់ចំណូលតិច

ឱសថស្ថានយើងខ្ញុំនឹងទូរស័ព្ទ ហើយធ្វើការជាមួយវេជ្ជបណ្ឌិត នឹងក្រុមហ៊ុនធានារ៉ាប់រងសុខភាព លោកអ្នកនឹងទទួលបានថ្នាំរបស់លោកអ្នកជាប្រាកដ

Washinton Pharmacy បានជួយអ្នកជំងឺរាប់ពាន់នាក់ នៅក្នុងសហគមន៍ ស្រាយបញ្ហាស្មុគស្មាញ ដើម្បីឱ្យបានឱសថដែលអ្នកទាំងនោះត្រូវការ ។

និយាយនឹងពន្យល់អំពីថ្នាំ ជាភាសាខ្មែរ

លឿនរហ័ស :
១០ នាទី ឬយកទៅឱ្យដល់ផ្ទះ

600 Washington ave, Unit 18E Phila, PA - phone: 215-755-5100

បទសម្ភាសន៍របស់វិទ្យុ...

ផ្ទះសពាផ្ទៃរបស់លោក ប៉ែន សុវណ្ណ នៅខេត្តតាកែវ

គ្រប់គ្រង់ ឬក៏ចាត់ចែង និងសហការជាមួយ ដោយសារតែបញ្ហានេះ វាទាក់ទងទៅនឹងឯកសារមួយដែលវិទ្យុខ្មែរប៉ុស្តិ៍ទទួលបាន គឺឯកសារ ដែលនិយាយពីកំណត់ហេតុស្តីពីសន្និបាតលើកទី១នៃសហជីព នៅក្រសួងការបរទេស នៅថ្ងៃទី០៦-០៧-០៨ ខែតុលា ឆ្នាំ១៩៨១ ដែលសម័យនោះ លោក ហ៊ុន សែន នៅជាអនុប្រធានក្រុមប្រឹក្សាគណរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបទេស ហើយលោកបានសំណូមពរ នៅក្នុងសន្និបាតប្រជុំថា : សូមឱ្យសមមិត្តទាំងអស់គ្នាពិចារណាឱ្យបានហ្មត់ចត់ជុំវិញថា : "បើអ្នកណាប្រឆាំងនឹងវត្តមានរបស់វៀតណាម គឺប្រឆាំងនឹងអាយុខ្លួនផ្ទាល់" ដែលកាលនោះ លោកជានាយករដ្ឋមន្ត្រី ហើយតាមកិច្ចសម្ភាសន៍មុខប៉ុន្មានទាទីសំនួរដែលខ្ញុំ បានសួរលោកៗថាហើយ ថាដោយសារតែលោកត្រូវបានវៀតណាមចាប់យកទៅដាក់គុកពន្ធនាគារ ប្រទេសវៀតណាម ដោយសារតែមានកត្តា ដែលលោកប្រឆាំងជាមួយវៀតណាម ដែលមានការរំលោភបំពានបញ្ហាខ្លះៗមកលើប្រទេសកម្ពុជា ដែលករណីនេះហើយ ធ្វើឱ្យមានការចាប់ចងរូបលោក តើប្រសាសន៍លោក ហ៊ុន សែន ពីអតីតកាលនោះ ជាការមួយដែលចង់តទល់ជាមួយលោកឬទេ ក្នុងន័យដែលលោក ហ៊ុន សែន បានអះអាងកន្លងមកក្នុងអតីតកាលប្រវត្តិសាស្ត្រនោះបាទ ?

ចម្លើយលោក ប៉ែន សុវណ្ណ : ខ្ញុំឃើញថាបញ្ហាហ្នឹង នៅលើវិជ្ជមានហើយ បើខ្ញុំមិននិយាយទៅ គឺថាខ្ញុំមានប្រជាប្រិយ៍ភាពនឹងប្រជាពលរដ្ឋទូទៅទាំងប្រទេសទាំងកងកម្លាំងប្រដាប់អាវុធហើយ បើអីចឹង លោក ហ៊ុន សែន អ្វីដែល ខ្ញុំប្រឆាំងវៀតណាម គាត់មានមហិច្ឆិតាដាក់នឹងត្រួតត្រានៅស្រុកខ្មែរហ្នឹង រូបលោក ហ៊ុន សែន ត្រូវតែប្រឆាំងនឹងខ្ញុំដាច់ខាត ហើយអាហ្នឹងលើកច្បាស់ណាស់ គេថាខ្ញុំជាប្រធានបក្សជាប្រមុខបក្សជាប្រមុខរដ្ឋាភិបាលដឹកនាំប្រជាជាតិអ៊ីចឹង យើងប្រឆាំងនឹងវៀតណាមនិគមន៍វៀតណាម គឺថា ចោទថាវៀតណាមមកបំពានដល់អធិបតេយ្យភាពខ្មែរ ថាអាហ្នឹងហើយ ដែលខ្ញុំមិនដឹកគុណវៀតណាម ។ យើងគួរតែដឹកគុកវៀតណាមអាហ្នឹងច្បាស់ណាស់អាហ្នឹង ជំនាន់ហ្នឹងពីខែណា លោក ហ៊ុន សែន គាត់បានតែងតាំងជាឧបនាយករដ្ឋមន្ត្រី ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ១៩៨១ ជាឧបនាយករដ្ឋមន្ត្រី សមាជិកការិយាល័យនយោបាយមជ្ឈឹមបក្សឧបនាយករដ្ឋមន្ត្រីនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

ខ្ញុំតែងតាំងគាត់ជាឧបនាយករដ្ឋមន្ត្រី បានបញ្ជាពីណាមក ?

វៀតណាមបានបញ្ជាខ្ញុំថា : ឱ្យខ្ញុំតែងតាំងលោក ហ៊ុន សែន ជាឧបនាយករដ្ឋមន្ត្រីវៀតណាម គេសម្រេចអីចឹងថា : សមមិត្តកុំប្រែប្រួលសមមិត្តចង់ឱ្យខ្ញុំជួយអាហ្នឹងមិត្តត្រូវតែជួយយើងខ្ញុំមិត្តត្រូវតែតែងតាំងសមមិត្ត ហ៊ុន សែន ជាឧបនាយករដ្ឋមន្ត្រី មិត្តត្រូវតែធ្វើអ៊ីចឹងតែម្តងអត់មានសត្រូវជាមួយសមមិត្តទៀតទេ ។

អាហ្នឹងគេគម្រាមខ្ញុំទៀតណា៎ អ៊ីចឹងបានជាខ្ញុំត្រូវបង្ខំចិត្ត នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ១៩៨១ នោះ ខ្ញុំស្តាប់តាមបទបញ្ជាពីវៀតណាម បើខ្ញុំមិនស្តាប់បទបញ្ជាពីវៀតណាមទេ វៀតណាមអាចរករឿងខ្ញុំមួយដ៏មានគ្រោះថ្នាក់បំផុត ខ្ញុំមិននិយាយទេបាទ ។

សំនួរ : តើលោកមានទំនាក់ទំនងយ៉ាងណាដែរ ជាមួយលោក កែវ ចិន្តា ?

លោក ចាន់ ស៊ី ក្នុងសម័យមុន លោក ហ៊ុន សែន ឡើងជាឧបនាយករដ្ឋមន្ត្រី រហូតដល់ឡើងជានាយឧបនាយករដ្ឋមន្ត្រី រហូតដល់ឡើងជានាយក បន្ទាប់ពីលោកត្រូវបានខាងវៀតណាមដកទំលាក់លោក ហើយនឹងចាប់រូបលោក យកទៅឃុំឃាំងនៅប្រទេសយៀតណាមហ្នឹងបាទ ព្រោះកាលដែលគេចាំបាននោះ តាមបញ្ជារបស់យួន ត្រូវឱ្យទៅចាប់រូបលោក នៅឯគេហដ្ឋានរបស់លោកហ្នឹងក្នុងឆ្នាំណា ហើយលោកបញ្ជាក់ឱ្យមិត្តអ្នកស្តាប់វិទ្យុខ្មែរប៉ុស្តិ៍ ដើម្បីឱ្យស្តាប់ ដឹងហើយដើម្បីផ្តល់កំលាំងទឹកចិត្ត និងផ្តល់សម្លេងឆ្នោតសំរាប់លោក ប៉ែន សុវណ្ណ នៅក្នុងនាមជាអនុប្រធានគណបក្សសិទ្ធិមនុស្ស ដែលឈានទៅរកការបោះឆ្នោត នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ខាងមុខនេះ បាទ ?

ចម្លើយលោក ប៉ែន សុវណ្ណ : បាទ ខ្ញុំសូមរៀបរាប់ដោយសង្ខេប ជូនលោក អ៊ុចេះ លោក កែវ ចិន្តា លោក ចាន់ ស៊ី ឬអស់លោកមួយចំនួនទៀត ថ្ងៃហ្នឹង គឺបញ្ហាទី១ គាត់បានការលត់ដំក្នុងភ្លើងសង្គ្រាមជំនាន់អាណានិគមបារាំង គាត់ហ៊ានពលិកម្មអ្វីៗទាំងអស់ ។ បញ្ហាទី២ : គាត់បានឆ្លងក្រោយសង្គ្រាម១៨មិនា គាត់មានតួនាទីខុសៗគ្នា ក្នុងការបំរើនយោបាយ អាហ្នឹងជាបញ្ហាទី២ ហើយបញ្ហាទី៣ ចំពោះទស្សនៈរបស់ខ្ញុំ អស់លោកហ្នឹងជាឥស្សរជន គឺមានទឹកចិត្តស្នេហាជាតិពិតប្រាកដ ។ អាហ្នឹងខ្ញុំសូមបញ្ជាក់អ៊ីចឹងហើយ ចំពោះដែលថា វៀតណាមគេមានគំនិតមហិច្ឆិតាចង់យកទឹកដីខ្មែរយើងទៅក្រោមអាណានិគមរបស់គេ គេមានគោលបំណងពីរ : គោលបំណងទី១ : គេដើរទិញទឹកចិត្តឥស្សរជនណាដែលស្មោះត្រង់ជាមួយគេបំរើគេយកកិច្ចការផ្ទៃក្នុងរបស់ ខ្មែរទៅផ្តល់ព័ត៌មានឱ្យវៀតណាមអីចឹងហើយក្នុងហ្នឹងមានការ

នៅមានតទៀត

លោកមានសុខភាពរាល់ថ្ងៃ មិនប្រក្រតី សូមប្រើ RELIV

សក្ខីកម្ម

ខ្ញុំមានជំងឺ Cancer ខួរក្បាល ហើយបានវះក្បាលពីរដង ខ្ញុំស្ថិតក្នុងការព្យាបាល Chemotheraphy ១៨ ខែ ....ពីរឆ្នាំក្រោយមកខ្ញុំមានគ្រោះថ្នាក់រថយន្តទៀត ។

ពេលបានជួប Relive មួយឆ្នាំក្រោយមកការឈឺចុកចាប់ក៏បាត់ទៅអស់ ខ្ញុំប្រែមានកម្លាំង ហើយអាចហាត់ប្រាណវិញបាន មិនតែប៉ុណ្ណោះចុះទម្ងន់ទៀតផង ។

Stephanis
-Emmons **(817) 847-5476**

The Reliv scientists formulate the most recent nutrition research into products that scientifically advance, nutritionally complete, and is proven to restore the boby functions.

របៀបប្រើ : រៀងរាល់ព្រឹក ដួស RELIV មួយស្លាបព្រាវង្វាល់ពីកំប៉ុង A មួយស្លាបព្រាវង្វាល់ទៀត ពីកំប៉ុង B ដាក់ទៅក្នុងកែវមានទឹកធម្មតា ឬទឹកផ្លែ ឈើកូរលាយគ្នា រួចពិសារព្រឹកម្តង ល្ងាចម្តងទទួលលទ្ធផលទាន់ចិត្ត

● **ទូរស័ព្ទសំរាប់ជាវ** (636) 537-9715

ជាវ ① RELIV CLASSIC : A
② RELIV INNERGIZE : B

កុំភ្លេចឱ្យលេខ Reliv Distributor :
(RNC.# 7070 438001)

● **ទូរស័ព្ទ** : (267) 253-3947 **សំរាប់ហៅ**
បើលោកចង់ចែកចាយជូនមិត្តភក្តិបងប្អូនបន្ត
ទៅទៀតជា Relive Distributor

RCN# 7070438001 **www.reliv.com**

នៅ VIRGINIA CALL VANNDY 1-703 415- 6257

Please Call : (267) 253-3947

ថៃនាំមន្ត្រីយោធាអមស្ថានទូត...

វេលាម៉ោងប្រមាណ១១:៣០នាទី កងទ័ពថៃបានដឹកនាំមន្ត្រីយោធាអមស្ថានទូតមកពី១១ប្រទេសប្រចាំទីក្រុងបាងកក មកកាន់តំបន់ជម្លោះខ្សែត្រៀមទី១ក្នុងទឹកដីថៃ នៃបរិវេណប្រាសាទព្រះវិហារ ដើម្បីពិនិត្យមើលស្ថានភាពប្រឈមមុខដាក់គ្នាដោយយោធាខ្មែរ និងថៃ ។

មន្ត្រីយោធាអមស្ថានទូតទាំងនោះ មកពីប្រទេសកាណាដា អាល្លឺម៉ង់ វៀតណាម សិង្ហបុរី លាវ ឥណ្ឌូនេស៊ី ឥណ្ឌា និងមន្ត្រីមួយចំនួនទៀត មន្ត្រីយោធាថៃបានបញ្ជាឱ្យមន្ត្រីយោធាទាំងនោះ វិលត្រឡប់ចេញទៅវិញជាប្រញាប់ ដោយមិនចង់ឱ្យជួបធ្វើសម្ភាសន៍ជាមួយអ្នកកាសែតខ្មែរ ។

អ្នកនាំពាក្យរដ្ឋាភិបាលកម្ពុជាបានឱ្យដឹងថា វាជាការប្រសើរ ដែលមន្ត្រីយោធាថៃ បាននាំមន្ត្រីយោធាអមស្ថានទូតបរទេសទៅពិនិត្យស្ថានការណ៍ជាក់ស្ដែងក្នុងតំបន់ប្រឈមមុខដាក់គ្នារវាងកងទាហានខ្មែរ និងថៃនោះ ។

ជណ្ដើរឡើងប្រាសាទព្រះវិហារ

លោកវរសេនីយ៍ឯក ហ្វ័របាត ជាមន្ត្រីយោធាអមស្ថានទូតអាល្លឺម៉ង់ បានស្ដែងឱ្យដឹងថា រូបលោក និងមន្ត្រីយោធាអមស្ថានទូតចំនួន១០ប្រទេសផ្សេងទៀត បានមកកាន់តំបន់ប្រឈមមុខយ៉ាងតានតឹងដាក់គ្នារវាងកងទាហានខ្មែរ និងថៃ នៃប្រាសាទព្រះវិហារនេះ ដោយសារតែមានការសំណូមពរយ៉ាងទទូចពីក្រុមមន្ត្រីយោធាថៃតែប៉ុណ្ណោះ ។

ស្ថានភាពប្រឈមមុខដាក់គ្នាដ៏តានតឹងនៃកងទាហានខ្មែរ និងថៃ នៅតំបន់ប្រាសាទព្រះវិហារ នៅមិនទាន់ធូរស្រាលទេ រហូតមកដល់ថ្ងៃច័ន្ទនេះ ដោយគេរង់ចាំស្ដាប់លទ្ធផលការចរចាររវាងមន្ត្រីការបរទេសនៃប្រទេសទាំងពីរ ដែលកំពុងជួបគ្នានៅខេត្តសៀមរាបប៉ុណ្ណោះ ។

ទាហានខ្មែរម្នាក់ កំពុងត្រៀមប្រយុទ្ធនៅខ្សែត្រៀមជួរមុខបាននិយាយថា គេបានត្រៀមលះបង់ជីវិតជាស្រេចសម្រាប់ការការពារទឹកដីខ្មែរ ប្រសិនបើមានសង្គ្រាមកើតឡើង ។

ប៉ុន្តែចំពោះទាហានថៃមួយរូបបាននិយាយថា គេមិនចង់ធ្វើសង្គ្រាមទេ បើសិនស្ថានការណ៍ឱ្យពួកគេវិលត្រឡប់ គេនឹងត្រឡប់ទៅជួបប្រពន្ធកូននឹងបានទៅធ្វើស្រែចំការវិញ ។

ស្របពេលជាមួយគ្នា នៅឯព្រំដែនខ្មែរ-ថៃ តំបន់ជាំស្រងាំ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ឯណោះវិញ កងតម្រួតព្រំដែនខ្មែរ បានរាយការណ៍ថា ទាហានឈុតខ្មៅ និងទាហានប៉ារ៉ាថៃចំនួន១៦ នាក់ប្រដាប់ដោយអាវុធបានចូលមកព្រំដែនខ្មែរ ចម្ងាយប្រមាណ៧០ម៉ែត្រ កាលពីវេលាម៉ោង១ រសៀល ថ្ងៃច័ន្ទ នេះ ប៉ុន្តែត្រូវកងរក្សាព្រំដែនខ្មែរ រុញច្រានត្រឡប់ទៅវិញ បន្ទាប់ពី១ម៉ោងក្រោយមក ។

លទ្ធផលនៃកិច្ចប្រជុំរបស់រដ្ឋមន្ត្រីការបរទេស ខ្មែរ-ថៃ នៅខេត្តសៀមរាប បានឱ្យដឹងថា ថ្វីបើកិច្ចប្រជុំរវាងមន្ត្រីជាន់ខ្ពស់ខ្មែរ និងថៃ ត្រូវគេមើលឃើញថា មិនទាន់អាចដោះស្រាយបញ្ហាអ្វីចេញ នៅឡើយក្ដី ប៉ុន្តែអ្នកយកការណ៍វិទ្យុអាមេរិកាំង បានឱ្យដឹងថា តំណាងប្រទេសទាំងពីរបានពណ៌នា លទ្ធផលនៃកិច្ចប្រជុំនោះថា បានទទួលជោគជ័យក្រៃលែង ។

អ្នកយកព័ត៌មានវិទ្យុអាមេរិកាំង បានបន្តថា កិច្ចប្រជុំរវាងរដ្ឋមន្ត្រីការបរទេសប្រទេសទាំងពីរ ខ្មែរ-ថៃ អស់រយៈពេល១២ម៉ោង ភាគីទាំងពីរបានសម្រេចចំណុចជាច្រើន គឺបានចាត់ទុកជាលទ្ធផលនៃការជួបនោះ ជាជោគជ័យក្រៃលែង ។

ជោគជ័យត្រង់ចំណុចដែលបានឯកភាពជាមួយគ្នារក្សាភាពអត់ធ្មត់ជាអតិបរមាក្នុងការប្រើកម្លាំងទ័ព មិនត្រូវឱ្យមាន ហើយត្រូវដោះស្រាយបញ្ហា ចំពោះមុខដោយសន្តិវិធី ដូចជាប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេសទាំងពីរ និងគណៈកម្មាធិការព្រំដែន កម្ពុជា-ថៃ ហ្នឹង នឹងបន្តទៅទៀត ។ ហើយចំណុច ពិសេស និងសំខាន់បំផុតនៅក្នុងការពិភាក្សាហ្នឹង គឺភាគីទាំងពីរបានឯកភាពថា សូមឱ្យដកកងទ័ពទាំងខ្មែរ ទាំងថៃចេញពីវត្ត "កែវសិក្ខាគីរីស្វារៈ" ជាវត្តដែលកំពុងមានជម្លោះហ្នឹង ហើយនិងក្បែរបរិវេណប្រាសាទព្រះវិហារ ក៏ឱ្យដកទ័ពចេញដែរ ។

នៅត្រង់ចំណុចពិសេសស្ដីពីការដកកងទ័ពនៃភាគីទាំងពីរចេញពីវត្តបរិវេណប្រាសាទព្រះវិហារនេះ មិនទាន់យល់ថា តើរដ្ឋាភិបាលខ្មែរ ព្រមទទួលស្គាល់ថា តំបន់ហ្នឹងជាតំបន់ត្រួតស៊ីគ្នា ហើយតើថៃ គិតថាអ៊ីចឹងដែរឬទេ ? លោក ហោ ណាំហុង មិនបានឆ្លើយប្រាប់អ្នកកាសែតឱ្យចំនឹងសំនួរនេះទេ គ្រាន់តែថា ដោះស្រាយដោយសន្តិវិធី និងមានការពិភាក្សាបន្តទៅទៀត គឺអត់ទាន់មានពេលបច្ចេទត្រឹមត្រូវនឹងដកកងទ័ពពេលណានោះទេ ។

អ្នកយកព័ត៌មានវិទ្យុអាមេរិកាំងម្នាក់ បានបញ្ជាក់ហើយថា ក្នុងសន្ធិសញ្ញាទាំងឡាយទាំងពួងរវាងកម្ពុជា-ថៃ កន្លងផុតមកមានភាពច្បាស់លាស់ណាស់ ដែលប្រទេសទាំងពីរ បានទទួលស្គាល់គ្នាទៅវិញទៅមក ហើយតាមសន្ធិសញ្ញាឆ្នាំ ១៩០៤, ១៩០៧ និង១៩៦២ ដែលថាព្រំដែន គឺមានភាពច្បាស់លាស់ទៅហើយ ។ តើចំណុចអ្វីដែលថៃលើកយកមកជាមូលដ្ឋាននៃការបញ្ជូនកងទ័ពចូលមកគ្រប់គ្រងវត្តកែវសិក្ខាគីរីស្វារៈ និងតំបន់ប្រាសាទព្រះវិហារនេះ ? និងចំណុចមួយទៀតសួរថា ចុះហេតុអ្វីបានជាចាំបាច់ត្រូវដកកងទ័ពចេញពីតំបន់ ដែលប្រទេសខ្មែរគិតថា ជាដីរបស់ខ្លួនទៅហើយនោះ តើនេះ មិនមែនមានន័យថា ខ្មែរទទួលស្គាល់តំបន់ត្រួតស៊ីគ្នាទៅហើយមែន ឬទេ ?

មន្ត្រីក្រសួងការបរទេសខ្មែរ បានឆ្លើយអះអាងថា អ្វីដែលជជែកគ្នា គឺមិនបានជជែកស៊ីជម្រៅទេ គឺគ្រាន់តែសុំឱ្យមានការដកកងទ័ពចេញតែប៉ុណ្ណឹង ដោយភាគីខ្មែរប្រកាន់ខ្ជាប់នូវការដោះស្រាយព្រំដែនដោយផ្អែកទៅតាមសន្ធិសញ្ញា និងផែនទី ដែលអន្តរជាតិទទួលស្គាល់ឆ្នាំ១៩០៤, ១៩០៧ និងការឈ្នះក្ដីឆ្នាំ១៩៦២ ទុកជាការត្រឹមត្រូវ ។

តាមការយល់ឃើញ និងការបញ្ចេញមតិរបស់ជាតិខ្មែរ និងអន្តរជាតិ ដែលប្រកបដោយគតិយុត្តិធម៌ និងស្រឡាញ់សន្តិភាពបានសំដែងចេញឱ្យដឹងថា មិនត្រូវឱ្យរដ្ឋាភិបាលខ្មែរប្រឹងប្រែងដោះស្រាយបញ្ហានេះ តែត្រឹមលំដាប់ទ្វេភាគីរវាងខ្មែរ និងថៃ ខ្លួនឯងប៉ុណ្ណឹងទេ គឺត្រូវតែប្រឹងប្រែងនៅថ្នាក់តំបន់លំដាប់អន្តរជាតិ រហូតទៅដល់អង្គការសហប្រជាជាតិទៀតដែរ ។

ការចរចារធ្វើឡើងតែក្នុងរបៀបទ្វេភាគី

(តទៅទំព័រទី១០)

បណ្ដាំប្រាជ្ញព្រឹទ្ធពីក្រីក្រ

ដោយ : ម៉ម យិន

មនុស្សម្នាសព្វថ្ងៃមានច្រើនណាស់
រស់រានពេញពាសលើផែនដី
ខ្លះមានខ្លះក្រក្រៀមក្រំក្រៃ
គ្រប់គ្រាសម័យដូចស្រមោច ។

អ្នកខ្លះខ្លួនខ្លាចចិត្តតឹងត្លោង
ខ្លួនសែនសោកសោងក្តួលក្តៅក្តោច
មិនហ៊ានហក់លោតស៊ូហត់ហោច
មិនប្រឹងប្រែងបោចខ្លាចខ្លួនខុស ។

ដោយសារតែខ្លួនល្ងីល្ងង់ល្ងិត
មិនចេះចងចិត្តចាំកំហុស
ប្រព្រឹត្តិព្រេងព្រាតគ្មានកែសោះ
គ្រប់គ្រាទាំងអស់ឥតប្រែប្រួល ។

នេះហើយជាហេតុត្រូវតែហាត់
កំចាយកំចាត់ក្ដីក្ដៅក្តួល
ដោយប្រឹងប្រុងប្រៀបព្រមដាក់ព្រួល
ព្រោងព្រាតផ្ដេកផ្ដួលតាមប្រាជ្ញព្រឹទ្ធ ។

លោកបានប្រៀនប្រាប់ឱ្យប្រុងប្រាណ
ពុះពារក្លាហានស្ម័គ្រស្នេហ៍សិទ្ធិ
ដោយចិត្តខ្លាំងក្លាខ្លួនមានពិត
ល្អល្អះល្អន់ល្អិតដូចល្អាងល្អ ។

ប្រាជ្ញប្រឹងប្រាប់ប្រាមឱ្យព្រមព្រៀង
រូបរួមរៀបរៀងកុំរ៉េរ៉ៃ
រៀនរាល់រឿងរ៉ាវមានកុះករ
ឈានឈោងកុំឈរកុំឈប់ឆើយ ។

ពាក្យប្រាជ្ញមានមកមិនមែនហ្មង
ជួយជាតិមនុស្សផងល្អល្អះហើយ
លោកតែងតែចង់ចែកចាយឱ្យ
ដល់ជនជាន់ក្រោយគ្រប់គ្រាក្រ ។

ពាក្យថាក្រីក្រគ្រោតគ្រាតគ្រប់
ពេលក្រគ្រប់ស៊ុបសាយសុះស
ទុក្ខទោសកើតកម្មកាចបន្ត
ជាប់ជិតពេញពោរពូនពេកពិត ។

ក្ដីក្រនាំឱ្យក្រៀមក្រំក្រៃ
ខ្យត់ខ្យោយស្ទើរក្ស័យក្សីកក្សួលចិត្ត
ក្រក្រាស់គ្រប់ក្រាញនៅងាប់ជិត
គ្រប់គ្រងជីវិតជិតដាមនៅ ។

ជីវិតជនក្រក្រោមក្រិត្យក្រម
មានទាល់ទុក្ខធំគ្រប់គ្រាក្រៅ
លំបាកលំបិនដូចក្បាលត្រូវ
បីបួនថ្ងៃព្រៅធ្លាក់ត្រូវទ្រូត ។

ក្រអើយសែនក្រព្រោះគ្រុនគ្រប
ឈឺខ្លាំងព្រោះខ្លាចខ្លៅស្ទើរឆ្កួត
ឈឺមកពីណានាំគ្នាព្រួត
មនុស្សប្រឹងប្រែងអួតអាងមិនអន់ ។

ក្រអើយសែនក្រព្រោះព្រាត់ប្រាស់
គ្រួសារសូន្យសោះសែនភ័យភន់
ស្ទើរឆ្កួតដូចឆ្កែវត់អាសន្ន
អាសូរសែនពន់ពេកពិតណាស់ ។

ក្រអើយសែនក្រព្រោះក្ដីល្ងង់
ដោយពិតពូជពង្សពីចាស់ៗ
ពូជក្រនៅក្រជាប់ក្រៃក្រាស់
ប្រឹងប្រែងប្រែផ្លាស់តែភ្លេចភ្លាត់ ។

ពូជក្រខិតខំខាត់ខួរក្បាល
អាចបានស្រួលស្រាលស្រាកចាកផុត
បានខ្លះលែងខ្លាចដូចខ្លាព័ទ្ធ
ចោមចាំខាំមាត់មុខហ្មត់ហ្មង ។

ប្រាជ្ញបានប្រៀនប្រាប់ប្រដៅ
ដឹកដៃដើរទៅជួយចម្លង
ឱ្យដឹងពីក្រក្រៃកន្លង
គ្រាំគ្រាគ្រប់គ្រងដូចគ្រោះគ្រុន ។

សូមមនុស្សក្របានគ្រាន់គ្រប់
លែងមានគ្រប់ជប់ដូចដានមុន
បានស្រាកស្រាន្តស្រាលលែងធូរធូន់
ជួយជាតិជាជនបានជួបជូន ។

ជួបហើយជួបជាប់ជិតជានិច្ច
ទឹកនៅស្របស្រេចស្រួលស្រាន្តខ្លួន
រីករាយ និងរិតវែងគ្រប់ធូន
បានរស់សមសួនសុខសុវត្ថិអើយ ។

Rathe's Auto Service
2153292418 · ហាងជួសជុលរថយន្ត · CELL 2154316376
5105 N. 2ND ST. PHILA.,PA 19120

From :Philadelphia

ហាងខ្មែរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

Rathe`s Auto Service

State and Emission
Inspection General
Repairs and Maintenance

MON-SAT, 8:30AM -5:30PM
SUN. EMERGENCY ONLY

-ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
-មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
-មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ -មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : -ដូរប្រេងកិរិត ៥ ក្វាត $22. - INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ ពាក់-មានជូនប័ណ្ណពិសេស សំរាប់ដូរប្រេង ចុះថ្លៃពាក់កណ្ដាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
-តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត
- ប្តេជ្ញាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ ។

ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL: (215) 329-2418
Fax: (215) 329-2419.Rath CELL: (215) 431-6376

រួមគ្នាការពារកេរដំណែលដូនតា

ភ្នំពេញ . ខ្មែរប៉ុស្តិ៍ : គឹម សារឿន

•••ប្រាសាទព្រះវិហារដែលស្ថិតនៅលើកំពូលភ្នំដងរែកជាប់ព្រំដែនកម្ពុជា-សៀមភាគខាងលិច ត្រូវបានអង្គការយូណេស្កូ សំរេចជាឯកច្ឆ័ន្ទ ចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក កាលពីថ្ងៃទី៨ ខែ កក្កដា នៅទីក្រុងកេបិច ប្រទេសកាណាដា ។

ការគាំទ្ររបស់អង្គការយូណេស្កូចំពោះប្រាសាទព្រះវិហារនេះ បានធ្វើឱ្យអ្នកប្រវត្តិសាស្ត្រ និងអ្នកនយោបាយសៀមយកប្រាសាទព្រះវិហារជាចំណុចស៊ើបអង្កេតឱ្យមានបាតុកម្មប្រឆាំងតវ៉ាមិនចេះចប់ ហើយលើកគ្នាមកតវ៉ាដល់ប្រាសាទព្រះវិហារ រហូតឈានដល់ការរេកាណុង និងចល័តកងទ័ពតាមខ្សែក្រវ៉ាត់កាន់តែច្រើនចាប់ តាំងពីថ្ងៃទី១៥ ខែកក្កដា មកម្លេះ ។

ប្រាសាទព្រះវិហារជាសម្បត្តិមរតកវប្បធមិរបស់ខ្មែរតាំងពីមហានគរ និងស្របតាមផ្លូវច្បាប់ ប៉ុន្តែជំលោះចាស់នេះក៏រើឡើងវិញ មិនអាចព្យាបាលបាន ដោយសារនៅប្រទេសសៀមមានវិបត្តិនយោបាយក្រោមការញុះញង់របស់គណបក្សប្រឆាំង ។

ក្រុមប្រឆាំងមួយដំបរស្វានោះបានស្រែកទាមទារឱ្យរដ្ឋាភិបាល សាម៉ាក់ ស៊ុនដារ៉ាវេត បដិសេធមិនទទួលស្គាល់ប្រាសាទព្រះវិហារ រហូតដល់ក្រុមបាតុករមកស្រែកទាមទារលើកបដាមុខប្រាសាទព្រះវិហារបង្កការអុកឡុកផ្លោះចូលទឹកដីខ្មែរខុសច្បាប់ ។

គូសត្រូវប្រវត្តិសាស្ត្រនៅភាគខាងលិច ប្រទេសខ្មែរដ៏ក្រោចក្រាតមួយនេះ បានយកលេសនេះ លើកទ័ពឈ្លានពានបូរណភាពទឹកដីកម្ពុជា នៅចំណុចវត្តប្រាសាទព្រះវិហារ ដោយមានកាំភ្លើងតូចធំរេកាណុងចុងឡើងសម្លឹង សំឡុតគំរាមកំហែងព្រះសង្ឃ និងទាហានខ្មែរ ។

ពួកសៀមបានលើកហេតុផលថា ជំលោះនេះ ផ្តើមចេញមកពីកម្ពុជាចុះបញ្ជីជាទីសក្ការៈនេះតែម្នាក់ឯង ធ្វើឱ្យក្រុមប្រឆាំងមិនសប្បាយចិត្ត ហើយការចល័តទាហាននេះក៏ដាក់នៅលើទឹកដីរបស់ខ្លួនដែរ គឺសំអាងលើផែនទីដែលគូសតែម្នាក់ឯង គ្មានការយល់ព្រមពីអ្នកណាទាំងអស់ ។

សារព័ត៌មានសៀមជាច្រើនបានចោទប្រកាន់ថា កម្ពុជាមិនមានភាពស្មោះត្រង់ឆ្លៀតកេងចំណេញ ហើយកម្ពុជាកំពុងលាបពណ៌មកលើសៀមថែមទៀត ។ ការពិតនោះកម្ពុជាមិនទាន់បានចំណេញអ្វីនោះទេក្នុងរឿងនេះ តែសៀមខ្លួនឯងបានបញ្ជូនទាហានចូលទឹកដីកម្ពុជាយ៉ាងកំរោល គួរឱ្យខ្មាសអៀន ។

ការរំលោភបំពានលើបូរណភាពខ្មែរនេះ ធ្វើឱ្យពលរដ្ឋខ្មែរគ្រប់ទិសទី អង្គការសង្គមស៊ីវិល គណបក្សនយោបាយបានធ្វើការអំពាវនាវដល់រដ្ឋាភិបាលឱ្យចាត់ការតាមផ្លូវច្បាប់កាទូតប្តឹងទៅអង្គការសហប្រជាជាតិតាមកិច្ចព្រមព្រៀងបារាំង- សៀម ឆ្នាំ១៩០៤. ១៩០៧ សាលក្រមតុលាការក្រុងឡាអេ ឆ្នាំ១៩៦២ និងកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ។

ចំណែករដ្ឋាភិបាលកម្ពុជាហាក់ដូចជាមិនអស់

(តទៅទំព័រទី១៩)

ឡៅ ម៉ុងហៃ : សម្តេចនរោត្តម សីហនុ អាចបញ្ចប់ទំនាស់វិវាទព្រំដែនប្រាសាទព្រះវិហារ

ឡុងប៊ិច ,ខ្មែរប៉ុស្តិ៍ : មាជ សុវណ្ណារ៉ា

•••ក្នុងជំលោះព្រំដែនប្រវត្តិសាស្ត្រតំបន់ប្រាសាទព្រះវិហាររវាងខ្មែរ-សៀម ដែលបានចល័តកងទ័ពតំរង់កាណុងដាក់គ្នារកកលតែផ្ទុះអាវុធម្តង១នោះ បានធ្វើឱ្យមតិជាតិ-អន្តរជាតិមានការព្រួយបារម្ភយ៉ាងខ្លាំង ។

ប៉ុន្តែសំរាប់លោក ឡៅ ម៉ុងហៃ អ្នកស្រាវជ្រាវជាន់ខ្ពស់សិទ្ធិមនុស្សអាស៊ីយល់ថា មានតែប្តឹងទៅអង្គការសហប្រជាជាតិ ហើយផ្តល់តួនាទីនេះឱ្យទៅអតីតព្រះមហាវរក្សត្រ ដែលព្រះអង្គធ្លាប់មានកិត្តិនាមល្បីល្បាញក្នុងឆាកអន្តរជាតិ ទើបអាចដោះស្រាយទំនាស់នេះបាន ។

នេះជាបទសំភាសន៍រវាងលោក ឡៅ ម៉ុង ហៃ ជាមួយខ្មែរប៉ុស្តិ៍ ដែលមានខ្លឹមសារដូចខាងក្រោម :

⁎តើការប្រឈមមុខដាក់គ្នារវាងខ្មែរ-សៀម នៅតំបន់ប្រាសាទព្រះវិហារបណ្តាលមកពីអ្វី ?

សៀមកំពុងតែលុកលុយចូលកាន់កាប់បរិវេណប្រាសាទព្រះវិហារដោយខុសច្បាប់ ហើយពួកគេកំពុងតែធ្វើឱ្យមហាជនគេជឿជាក់បានក្លាយជារឿងចំរូងចំរាស់រវាងខ្មែរ-សៀម ចំពោះមុខច្បាប់ ។ ចំណែកខ្មែរយើងសុំឱ្យសៀមធ្វើការចរចាដកកងទ័ពចេញទៅវិញពីតំបន់នេះ រដ្ឋាភិបាលត្រូវតែមានយុទ្ធសាស្ត្រច្បាស់លាស់ក្នុងរឿងនេះ ។

រឿងប្រាកដនេះ ទឹកដី, វត្តអារាម, ព្រះសង្ឃ និងប្រជាពលរដ្ឋ ធ្លាប់រស់នៅទីនោះច្រើនឆ្នាំមកហើយ ជាពិសេសយើងមានឆ្មាំការពារព្រំដែននៅទីនោះ មុនពេលកងទ័ពសៀមចូលមកលុកលុយ កាលពីថ្ងៃទី១៥ កក្កដា ។

ពីមួយថ្ងៃទៅមួយថ្ងៃ ទាហានឈុតខ្មៅថៃបានកើនឡើងជាលំដាប់ និងមានជីកលានដ្ឋានសំរាប់ត្រៀមក្បួនសឹក ហើយជីកលានដ្ឋាននេះអាចក្លាយជាព្រំដែនថ្មី ដែលគេទាមទារក៏ថាបាន ។ ការជីកលានដ្ឋាននេះ យើងត្រូវមានការប្រុងប្រយ័ត្នឱ្យមែនទែន គឺយើងពិបាកក្នុងការរុញច្រានឱ្យគេដកថយទៅវិញខ្លាំងណាស់ ។


លោកបណ្ឌិត ឡៅ ម៉ុងហៃ

យើងត្រូវបង្ហាញពីចំណុចព្រំប្រទល់ ផែនទីឱ្យបានច្បាស់លាស់ ហើយការចរចាតោភាគីវាអាចបរាជ័យ ពីព្រោះការចរចាជាមួយសៀមអាចអូសបន្លាយពេលវេលាយូរ ។ ការដោះស្រាយនេះ អាចជាលក្ខណៈតំបន់ វាងាយស្រួលពីព្រោះសមាគមអាស៊ាន ប៉ុន្តែសៀមបានបដិសេធរួចហើយ ។ ទោះជាយ៉ាងនោះក្តី យើងក៏ត្រូវមានការប្រជុំបែបពហុភាគី ដើម្បីឱ្យភាគីពាក់ព័ន្ធចូលរួមដោះស្រាយ ឬដឹងឮ ជាពិសេស

(តទៅទំព័រទី១៦)

Washington Wellness Care **មន្ទីរថែរក្សាខ្លួនប្រាណ "វ៉ាស៊ីនតុន"**

Medical & Rehab.

ដោយវិជ្ជាពេទ្យ និងការបង្ហាត់រាងកាយឱ្យដើរឡើងវិញ

Medical & Rehab.
500 Washington Ave., 1st Fl.
Philadelphia, Pa 19147
Phone: 215.551.6838. Fax: 215.551.6718

Dr. Scott C. Tran, D.C. **Dr. Michael Barno, D.C.** **Dr. Zohar Stark, M.D.**

We are specialized in treating:

- Auto Accident Injuries - Work Related Injuries - Slip & Fall Injuries

យើងមានជំនាញក្នុងការព្យាបាល :

☞ របួសដោយគ្រោះថ្នាក់រថយន្ត ☞ របួសដោយទាក់ទងនឹងកន្លែងធ្វើការ ☞ របួសដោយរអិល ឬដួល

We have staffs who speaks Vietnamese, Chinese, and Cambodian
For Cambodian and Vietnamese Speaking Staff, please call Ricky Son at 215.380.1350
For English Speaking Staff, please call 215.551.6838

យើងមានបុគ្គលិកដែលនិយាយភាសា វៀតណាម, ភាសាចិន , និងភាសាខ្មែរ
ទាក់ទងជាមួយបុគ្គលិកខ្មែរ និងវៀតណាម សូមទូរស័ព្ទទៅ **រីគី សុន (215) 380-1350**
ទាក់ទងទៅបុគ្គលិកនិយាយភាសាអង់គ្លេស សូមទូរស័ព្ទទៅ **(215) 551-6838**

ក្រុមគ្រូបង្រៀនសហរដ្ឋអាមេរិក ចុះជួយជនក្រីក្រខ្មែរតាមជនបទ

ភ្នំពេញ .ខ្មែរប៉ុស្ដិ៍ ៖ ម៉ី សម្ផស្ស

•••ក្រុមគ្រូបង្រៀន និងនិស្សិតមកពីសហរដ្ឋអាមេរិក ដែលមានគ្នាប្រមាណជាង១០នាក់ បានចំណាយពេលវេលាដ៏មានតំលៃ ប្រាជ្ញា ស្មារតី កំលាំងកាយចិត្ត និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនយកទៅចែកជូនប្រជាពលរដ្ឋខ្មែរនៅតាមខេត្តមួយចំនួននៅឯជនបទ ។

ក្រុមគ្រូបង្រៀន និងនិស្សិតទាំងនោះមកពីទីក្រុងឡុងប៊ិច រដ្ឋកាលីហ្វ័រនីញ៉ា សហរដ្ឋអាមេរិក បានធ្វើដំណើរមកដល់ព្រលានយន្តហោះអន្តរជាតិក្រុងភ្នំពេញ កាលពីថ្ងៃទី១១ ខែកក្កដា រយៈពេល២សប្តាហ៍ក្នុងទឹកមុខស្រស់ស្រាយ និងក្តីសង្ឃឹមចង់ជួយដល់ប្រជាពលរដ្ឋក្រីក្រខ្មែរនៅតាមសហគមន៍ ។

ក្រុមគ្រូបង្រៀនអាមេរិកចែកសម្ភារៈសិក្សាសិស្ស

CLMER
Center for Language Minority Education and Research

លើសពីនេះទៀត ពួកគាត់បានពាំនាំនូវសៀវភៅ ប៊ិច ខ្មៅដៃ ថ្នាំពេទ្យ សំលៀកបំពាក់ ម្ហូបអាហារ ទៅចែកជូនក្រុមក្រីក្រ និងដើរបង្រៀនភាសាអង់គ្លេសដល់គ្រូ និងសិស្សនៅតាមមូលដ្ឋាននៅខេត្តសៀមរាប បាត់ដំបង ក្រុងភ្នំពេញ ។

លោក Alex Morales Director, School Improvement Initiative បានឱ្យដឹងថា ពួកយើងមកស្រុកខ្មែរពេលនេះរយៈពេល២សប្តាហ៍ដោយពាំនាំមកនូវសំភារៈ សំលៀកបំពាក់ អង្ករ ត្រីសាច់ សំរាប់ចែកជូនជនក្រីក្រ ។ ជាពិសេសយើងនឹងទៅពិនិត្យមើលពីស្ថានភាព រស់នៅរបស់កុមារី ដាវិក នៅស្រុកកំណើតក្នុងភូមិ ស្វាយជ្រំ ឃុំជ្រៃ ស្រុកថ្ម គោល ខេត្តបាត់ដំបង និងខេត្តកំពង់ស្ពឺ ។

លោក Alex Morales បន្តថា គោលបំណងសំខាន់របស់យើងដែលមកកម្ពុជានៅពេលនេះ គឺទៅធ្វើការសំណេះសំណាលជួយកុមារក្រីក្រ តាមមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីសិក្សាស្វែងយល់ពីតំរូវការ ព្រមទាំងភាពចាំបាច់នៅចំពោះមុខ ។ ក្នុងពេលនេះយើងនឹងធ្វើការពង្រឹងចំណេះដឹងផ្នែកភាសាអង់គ្លេសដល់សិស្សានុសិស្ស និងគ្រូៗនៅតាមសហគមន៍មួយចំនួនផងដែរ ។

ជាមួយគ្នានេះដែរ លោកសាស្ត្រាចារ្យ អ៊ឹង ដារិទ្ធ មកពីមហាវិទ្យាល័យទីក្រុងឡុងប៊ិច បានឱ្យដឹងថា ក្នុងដំណើរចុះជួយជនក្រីក្រតាមសហគមន៍ យើងមានជួបការលំបាកមួយចំនួន ដោយសារមេភូមិមួយចំនួនមិនឱ្យចូលទៅជួបអ្នកស្រុក និងក្មេងៗ ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី នៅតាមតំបន់មួយចំនួនយើងបានចុះទៅជួបជនក្រីក្រ និងចែកអំណោយ តាមគំរោងរបស់យើងតាមបែបមនុស្សធម៌ ។

លោក អ៊ឹង ដារិទ្ធ បន្តថា នៅពេលដែលយើងមកដល់ភូមិស្វាយជ្រំ ឃុំរលំជ្រៃនេះ យើងមានអារម្មណ៍ក្តុកក្តួលស្រងូតស្រងាត់ខ្លាំងណាស់ ពីព្រោះឃើញផ្ទះអ្នកស្រុកតូចៗ និងជីវភាពខ្វះខាត ហើយពិសេសនោះ គឺគ្រួសារកុមារីបេះដូងប្រហោងដែលរស់នៅក្នុងខ្ទមរយីករយាក ។

លោកបានបញ្ជាក់ថា ពេលក្រុមរបស់លោកត្រឡប់ទៅអាមេរិកវិញ នឹងធ្វើការអំពាវនាវដល់សប្បុរសជន និងអង្គការនានា ដើម្បីមកជួយរួមចំណែកអភិវឌ្ឍន៍ប្រទេសកម្ពុជាតាមតែអាចធ្វើទៅបាន ។

សំរាប់អ្នកស្រុកទាំងក្មេងចាស់ ដែលរស់នៅក្នុងភូមិស្វាយជ្រំនោះ ម្នាក់ៗបានសំដែងនូវទឹកចិត្តសប្បាយរីករាយយ៉ាងខ្លាំងចំពោះក្រុមអង្គការបេះដូងគ្មានព្រំដែន ដែលបានជួយសង្គ្រោះជីវិតកុមារី ដាវិក និងពាំនាំអំណោយមកចែកជូនដល់ពួកគាត់ថែមទៀត ។

លោក បួម សំបួរ អាយុ៥៥ឆ្នាំ តំណាងឱ្យអ្នកស្រុករស់នៅតំបន់នោះបានសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះសប្បុរសជន ដែលពាំនាំមកនូវអំណោយ និងទឹកចិត្តដ៏ថ្លៃថ្លា របស់បងប្អូនខ្មែរ និងជនអាមេរិកចំពោះពួកគាត់ ។

លោក បួម សំបួរ បញ្ជាក់ថា ទោះបីជាអំណោយនេះតិចតួចស្តួចស្តើងមិនអាចទ្រទ្រង់ជីវភាពរស់នៅរបស់លោកបានក្តី តែវាជាទឹកចិត្តដ៏ជ្រាលជ្រៅ និងស្មោះសបំផុត ដែលក្រុមគ្រូបង្រៀន និងអង្គការបេះដូងគ្មានព្រំដែនបានជួយដល់អ្នកស្រុកភូមិគាត់ឱ្យរស់រានមានជីវិត និងក្តីសង្ឃឹមឡើងវិញ ។

ចំណែកលោក Alex Morales នៅពេលដែលធ្វើដំណើរទៅដល់ភូមិរបស់កុមារី ដាវិក គាត់ ហាក់ដូចជាមានអារម្មណ៍ស្រងូតស្រងាត់ក្នុងចិត្តខ្លាំងណាស់ បន្ទាប់ពីបានឃើញនូវទិដ្ឋភាពក្រៀមក្រំរបស់អ្នកស្រុក ។ ប៉ុន្តែយើងខ្ញុំនឹងធ្វើការលើកទឹកចិត្តដល់ពួកគាត់ឱ្យមានក្តីសង្ឃឹមនៅពេលក្រោយ ហើយលោកមិនត្រឹមតែផ្តល់ជាអំណោយបន្តិចបន្តួចទុកជាអនុស្សាវរីយ៍នោះទេ គឺមានគំរោងជួយកសាងសាលារៀន សំរាប់កូនចៅអ្នកស្រុកនៅទីនេះថែមទៀត ។

លោក Alex Morales បញ្ជាក់ថា យើងមានគំរោងជួយកសាងសាលារៀននៅតាមបឋមសិក្សា និងអនុវិទ្យាល័យ ។ ជាពិសេសចង់បង្កើតសាលារៀនថ្មី ដើម្បីបង្រៀនភាសាអង់គ្លេស ដើម្បីឱ្យកូនចៅអ្នកស្រុកអាចរកការងារបានធ្វើនៅខេត្តសៀមរាប ក៏ដូចជាយកចំណេះដឹងទៅប្រកបរបរចិញ្ចឹមជីវិតបានដោយងាយស្រួល ៕

អតីតព្រះមហាក្សត្រអភ័យទោសឱ្យ អៀង សារី ប៉ុន្តែមិនបានលើកលែងទោសឱ្យទេ !

ភ្នំពេញ .ខ្មែរប៉ុស្ដិ៍ ៖ គីម សារឿន

•••អតីតឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេសសម័យខ្មែរក្រហម អៀង សារី បានឡើងមុខរង្វង់ក្រចកសេះនៃអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជាហៅថា (សាលាក្តីខ្មែរក្រហម) កាលពីដើមខែ កក្កដា កន្លងមកនេះ ។

លោក អៀង សារី ពេលឡើងតុលាការ នៅសាលាក្តីខ្មែរក្រហម

អៀង សារី ក្នុងវ័យ៨២ឆ្នាំ មានសុខភាពទន់ខ្សោយត្រូវបានមេធាវីរបស់ខ្លួនធ្វើការទាមទារឱ្យនៅក្រៅឃុំ ដើម្បីងាយស្រួលថែទាំសុខភាពជាលក្ខណៈគ្រួសារ ។ ជាពិសេសនោះ មេធាវីរបស់គាត់បានអះអាងថា កូនក្តីរបស់គាត់ត្រូវបានអតីតព្រះមហាក្សត្រលើកលែងទោសឱ្យរួចផុតពីការផ្តន្ទាទោសរួចហើយ ។

ការទាមទាររបស់មេធាវី អៀង សារី នោះត្រូវបានលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា អះអាងថា អៀង សារី នៅតែមានទោស ពីព្រោះអតីតព្រះមហាក្សត្រ ពុំទាន់បានលើកលែងទោសទេ គឺត្រឹមតែអភ័យទោសឱ្យរួចផុតពីការប្រហារជីវិតជាថ្នូរដឹកនាំកំលាំងខ្មែរក្រហមចុះចូលនឹងរដ្ឋាភិបាល ។

នេះជាលើកទី១ហើយ ដែល អៀង សារី ត្រូវបានសាលាក្តីខ្មែរក្រហមហៅមកសួរចំលើយនៅមុខមហាជន បន្ទាប់ពីចាប់ខ្លួនកាលពីចុងឆ្នាំ២០០៧ ជាមួយភរិយារបស់គាត់ អៀង ធារិទ្ធ ។ អៀង សារី ត្រូវបានគេកាត់ទោសនៅឆ្នាំ១៩៧៩ កំបាំងមុខពីបទប្រល័យពូជសាសន៍ដែលគាត់មានតួនាទី ក្នុងរបបនោះ ដោយត្រូវប្រហារជីវិត ។

ក្នុងពេលជជែកពិភាក្សាករណី អៀង សារី នេះ មេធាវីរបស់គាត់បានលើកឡើងថា កាលពីឆ្នាំ១៩៩៦ កូនក្តីរបស់គាត់ត្រូវបានផ្តល់ការលើកលែងទោស ចំពោះការកាត់ទោសឆ្នាំ១៩៧៩ ពីអតីតព្រះមហាក្សត្រ ហើយគាត់មិនខ្វល់នឹងសាលាក្តីខ្មែរក្រហមកាត់ទោសយ៉ាងណានោះទេ ។ ប៉ុន្តែពេលនេះ គាត់ចង់ឱ្យសាលាក្តីខ្មែរក្រហមដោះលែង អៀង សារី ឱ្យនៅក្រៅឃុំ ដើម្បីថែរក្សាសុខភាព ពីព្រោះពេលនេះ គាត់មានសុខភាពទន់ខ្សោយខ្លាំងណាស់ ។

លោក មីសែល កាណាវ៉ាស មេធាវីកាត់ក្តី អៀង សារី បានធ្វើការតវ៉ាចំពោះសាលាក្តីខ្មែរក្រហមថា គេមិនដែលយករឿងតែមួយមកធ្វើការពិភាក្សាពីរលើកនោះទេ គឺគ្មានករណីលើកលែងក្រោមច្បាប់កម្ពុជានោះឡើយ ។

លោក មីសែល កាណាវ៉ាស បន្តថា គោលការណ៍មិនអាចចៀសវាងតាមរយៈការយោងដល់ច្បាប់អន្តរជាតិឡើយ ។ អ្វីទៅជាចរិតនៃស្ថាប័ននេះ ? វាជាកម្ពុជា ឬវាជាអន្តរជាតិ ?

លោក វីល្លៀម ស្មីត សហព្រះរាជអាជ្ញារងបានមានប្រសាសន៍ថា អៀង សារី មានកំហុសត្រូវបានគេកាត់ទោស និងដាក់ទោសពេលអវត្តមានរបស់លោកក្នុងរយៈពេល៥ថ្ងៃប៉ុណ្ណោះ ចំពោះបទល្មើសឧក្រិដ្ឋកម្ម ដែល កើតមានក្នុងរបប៣ឆ្នាំ ៨ខែ និង២០ថ្ងៃ ។

ករណី អៀង សារី នេះ កំពុងក្លាយជារឿងចំរូងចំរាសពិបាកនឹងដោះស្រាយមានការទាមទារយ៉ាងខ្លាំងពីសំណាក់មេធាវីរបស់ខ្លួន ដែលជាប្រធានបទដ៏សំខាន់របស់អង្គ ជំនុំជំរះក្តី ក្នុងតុលាការកម្ពុជា ។

ការទាមទាររបស់មេធាវី អៀង សារី នេះត្រូវបានមតិមួយចំនួន ធ្វើការជំទាស់ថា អៀង សារី មិនទាន់ទទួលការលើកលែងទោសនោះទេ គឺមានន័យថា គ្រាន់តែអភ័យទោសរួចផុតពីការប្រហារជីវិតប៉ុណ្ណោះ ។

ពាក់ព័ន្ធនឹងរឿងនេះ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការអះអាងថា សាលាក្តីខ្មែរក្រហមនេះ មានការកាត់ទោសច្បាស់លាស់ ដោយមានអន្តរជាតិចូលរួមច្រើនចំណែកតុលាការកាលពីឆ្នាំ១៩៧៩ គឺពុំមានអន្តរជាតិចូលរួមទេ គឺធ្វើក្នុងក្របខណ្ឌកម្ពុជាប៉ុណ្ណោះ ។ កាលពីឆ្នាំ១៩៧៩ អៀង សារី ត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍សំលាប់ជាតិសាសន៍ឯង ដោយកាត់ទោសប្រហារជីវិតកំបាំងមុខ ។

លោក ឆាំង យុ បន្តថា ពេលបច្ចុប្បន្នសាលាក្តីខ្មែរក្រហម បានចោទប្រកាន់ អៀង សារី ពីបទប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។ ចំពោះការប្រទានអភ័យទោស និងការលើកលែងទោសមានការខុសគ្នា ហើយករណី អៀង សារី គឺជាការអភ័យទោសពីការប្រហារជីវិតឱ្យរស់រានមានជីវិតប៉ុណ្ណោះ ។

លោកប្រធានមជ្ឈមណ្ឌលបានបន្តថា ក្នុងការអភ័យទោសនោះ ពុំបានធ្វើការរារាំងសកម្មភាពទាំងឡាយណា ដែលតុលាការរកឃើញថា មានទោសក្នុងការចូលរួមពីអន្តរជាតិឡើយ ។ ចំណុចនេះហើយដែលបញ្ជាក់ថា ព្រះអង្គមានការឈ្លាសវៃខ្លាំងណាស់ ហើយបានស្វែងយល់អំពីបញ្ហានេះច្បាស់ ។

លោកប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាបញ្ជាក់ថា ការអភ័យទោសនេះ បានជួយទាំងសងខាងគឺបង្កឱ្យមានសន្តិភាពក្នុងស្រុក ក៏ដូចជាបើកចំហសំរាប់តុលាការមួយក្នុងការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះផងដែរ ។

លោក ឆាំង យុ បានបញ្ជាក់ទៀតថា អៀង សារី ដែលកាត់ទោសដោយតុលាការ នៅឆ្នាំ

(តនៅទំព័រទី២១)

ស្ថានភាពនៅកម្ពុជាក្រោយ...

ជាពលរដ្ឋខ្មែរ ដែលត្រូវតែមានសិទ្ធិបំពេញកតព្វកិច្ចជាខ្មែរ ដើម្បីបោះឆ្នោតជ្រើសរើសមេដឹកនាំប្រទេសទៅតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យពិតប្រាកដ និងត្រឹមត្រូវទៅតាមបទដ្ឋានជាតិ និងអន្តរជាតិ ។

ប្រតិកម្មដ៏ពុះពារប្រឆាំងជំទាស់នឹងលទ្ធផលការបោះឆ្នោតនេះ បានកើតចេញមកពីមេគណបក្សចំនួន៤ គឺប្រធានគណបក្ស សម រង្ស៊ី ប្រធានគណបក្សសិទ្ធិមនុស្សប្រធានគណបក្សហ៊្វុនស៊ិនប៉ិច និងប្រធានគណបក្សនរោត្តម រណឫទ្ធិ ដែលបានប្រកាសថ្លែងការណ៍មួយរួមគ្នា ធ្វើការជំទាស់ទៅនឹងលទ្ធផលនៃការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៤ ហើយទាមទារឱ្យមានការបោះឆ្នោតឡើងវិញ ។

សូមរំលឹកបញ្ជាក់ជូនប្រិយមិត្តអ្នកអានសារព័ត៌មានខ្មែរប៉ុស្តិ៍ថា កាលពីឆ្នាំ១៩៩៣ មានការបោះឆ្នោតសកលជាលើកដំបូង ក្រោយពីព្រឹត្តការណ៍កងទ័ពយួនសង្គមនិយមវៀតណាមចូលវាយឈ្លានពានប្រទេសខ្មែរបានសម្រេចជោគជ័យ កាលពីថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ រួចហើយមានការតែងតាំងមេដឹកនាំថ្មីមួយក្រុម ដែលមាននិន្នាការទៅខាងយួននិយមវៀតណាមនោះផង ។

ការបោះឆ្នោតសកលឆ្នាំ១៩៩៣ នោះ គឺជាម្រោងការសន្តិភាពនៃអង្គការសហប្រជាជាតិក្នុងកិច្ចប្រជុំសន្និសីទអន្តរជាតិ នៅទីក្រុងប៉ារីស ប្រទេសបារាំង ហើយបានសម្រេចចេញសន្និសញ្ញាសម្រាប់រៀបចំការបោះឆ្នោតសកលប្រជាធិបតេយ្យក្រោមការរៀបចំដោយផ្ទាល់ពីអង្គការអ៊ុនតាក់ ដោយចំណាយថវិការបស់អង្គការសហប្រជាជាតិចំនួនជាងពីរពាន់លាន ។

លទ្ធផលនៃការបោះឆ្នោតសកលនេះ អ៊ុនតាក់បានប្រកាសថា គណបក្សហ៊្វុនស៊ិចប៉ិច បានទទួលជ័យជំនះ គ្រាន់តែឮការប្រកាសនេះភ្លាម មេគណបក្សប្រជាជនកម្ពុជាបានមានប្រតិកម្ម ដោយមានកំហឹងយ៉ាងខ្លាំងក្លា ហើយហ៊ឹងហ្ញាត់ថា មិនព្រមទទួលយកលទ្ធផលនេះជាដាច់ខាត ពីព្រោះការបោះឆ្នោតគ្មានយុត្តិធម៌ត្រូវតែធ្វើការរាប់សន្លឹកឆ្នោតឡើងវិញ បើមិនដូច្នេះទេ គណបក្សប្រជាជននឹងធ្វើការប្រឆាំងតស៊ូលុះត្រាបានដណ្តើមអំណាចមកកាន់សារជាថ្មីឡើងវិញជាដាច់ខាត ។

ប្រតិកម្មដ៏ពុះពារដោយកំហឹងរបស់គណបក្សប្រជាជនកម្ពុជាពេលនោះ បានបង្ហាញឱ្យឃើញជាក់ស្តែងច្បាស់លាស់ខ្លាំងណាស់ នាឆ្នាំ១៩៩៧ ថាដើម្បីជោគជ័យរបស់គណបក្សប្រជាជន គឺវិធីមានតែមួយគត់ គឺការធ្វើរដ្ឋប្រហារទំលាក់នាយករដ្ឋមន្ត្រីលំដាប់ថ្នាក់ទី១ ខាងគណបក្សហ៊្វុនស៊ិនប៉ិចឱ្យធ្លាក់ចេញពីអំណាច ក្នុងគោលបំណងឱ្យបានក្លាយខ្លួនទៅជាមេដឹកនាំកាន់អំណាចតែម្នាក់ឯង ដោយត្រូវបោះឆ្នោតអាណត្តិទី២ ឆ្នាំ១៩៩៨ ហើយ និងអាណត្តិបន្តៗមកទៀត ហូតដល់អាណត្តិទី៤ នាឆ្នាំ២០០៨នេះ គណបក្សប្រជាជនកម្ពុជាមិនគ្រាន់តែជាគណបក្សនយោបាយធម្មតាដូចជាប្រទេសនានានោះទេ គឺឥឡូវនេះ គណបក្សនេះ បានក្លាយទៅជាគណបក្សដ៏មហាប្រជាប្រិយខ្ពង់ខ្ពស់បំផុតទទួលបានជោគជ័យមហាអស្ចារ្យ ហើយមានមេដឹកនាំគណបក្សដ៏មានមហាគតិបណ្ឌិតមានឫទ្ធិខ្លាំងណាស់ មានមាត់ទិព្វបានជប់ហេដ្ឋារចនាសម្ព័ន្ធឱ្យមានពាសពេញលើព្រះរាជាណាចក្រកម្ពុជាទាំងមូលទុកជាភស្តុតាងបង្ហាញជនជាតិខ្មែរ និងពិភពលោកនេះ ជាពាក្យសំដីនិយាយអះអាងរបស់ស្ថានីយទូរទស្សន៍ ស៊ី ធី អិន (CTN) កាលពីថ្ងៃ២៨ កក្កដាកន្លងទៅនេះ ។

នៅក្នុងលទ្ធផលមហាជោគជ័យរបស់មេដឹកនាំគណបក្សប្រជាជនកម្ពុជា នៅអាណត្តិទី៤ ក៏ដូចគ្នាក្នុងអាណត្តិមុនៗដែរ បានបណ្តាលឱ្យមន្ត្រីថ្នាក់កំពូលជាច្រើនរូបបានថ្លែងប្រកាសឱ្យពលរដ្ឋខ្មែរ និងប្រជាពលរដ្ឋលោកទាំងអស់ដឹងថា ប្រទេសកម្ពុជាទៅអនាគត ត្រូវតែនៅក្នុងកណ្តាប់ដៃកាន់កាប់អំណាចនៃគណបក្សប្រជាជន ហើយនាយករដ្ឋមន្ត្រី នៅតែស្ថិតលើសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជារៀងរហូតគ្រប់ៗតែអាណត្តិសម្តេចមានជន្មាយុជាង៩០ឆ្នាំ ជាពិតប្រាកដ ៕

ថៃនាំមន្ត្រីយោធាអមស្ថានទូត...

ខ្មែរ-ថៃ នេះ គឺភាគីថៃ មិនចង់ឱ្យរឿងនេះឡើងទៅកាន់ថ្នាក់តំបន់ ឬថ្នាក់អន្តរជាតិទេ ។ ពីព្រោះរដ្ឋាភិបាលថៃ ខំព្យាយាមរាំងខ្ទប់ទាំងអស់មិនចង់ឱ្យមានការជជែកនៅថ្នាក់តំបន់ និងទៅដល់អង្គការសហប្រជាជាតិទេ ដោយគិតថាបើបង្ហាញទៅវានឹងមានភាពអាម៉ាស់មួយរបស់ថៃតែប៉ុណ្ណោះ ។

ទស្សនៈមតិរបស់សារព័ត៌មានខ្មែរប៉ុស្តិ៍ ដែលបាន តាមដានពីហេតុការណ៍ផ្សេងៗ ចំពោះបញ្ហាប្រាសាទព្រះវិហារ និងព្រំដែនបរិវេណតំបន់ប្រាសាទព្រះវិហារ ក្រោយថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៧ នេះមក នៅឯខាងក្នុងប្រទេសថៃ មានសកម្មភាពនៃក្រុមប្រឆាំងរដ្ឋាភិបាលថៃ បានចាប់ផ្តើមងើប ក្រោកឈរឡើងថ្លែងប្រកាសការទាមទារតវ៉ាជំទាស់ទៅនឹងសេចក្តីសម្រេចបញ្ចូលប្រាសាទព្រះវិហារខ្មែរទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ។

ច្រកចេញចូលពីប្រាសាទព្រះវិហារនៅថៃ

ការថ្លែងប្រកាសការទាមទារតវ៉ា និងជំទាស់នេះ មានចេញមកពីគ្រប់មជ្ឈដ្ឋាននៃប្រទេសថៃ ទាំងទូរទស្សន៍ ទាំងវិទ្យុ ទាំងសារព័ត៌មានរួមទាំងបាតុកម្មមហាជន ដោយប្រើគ្រប់យុទ្ធវិធីទាំងអស់ សូម្បីក្រុមសិល្បករចម្រៀងក៏គេបានបញ្ចូល ទៅក្នុងបណ្តាញអ៊ីនធឺណែតផ្សាយចេញលើពិភពលោក ស្រែកច្រៀងទាមទារឱ្យខ្មែរប្រគល់ប្រាសាទព្រះវិហារជារបស់ថៃទៅឱ្យប្រទេសថៃវិញ (SIC) ជាដើម ។

រីឯទូរទស្សន៍ វិទ្យុ សារព័ត៌មានក្នុងមួយថ្ងៃៗ គេផ្សព្វផ្សាយតែពីការទាមទារតវ៉ាថាឱ្យខ្មែរ ប្រគល់ប្រាសាទព្រះវិហារមកឱ្យថៃវិញ ហើយដកកងទ័ពខ្មែរ ដែលមកឈ្លានពានដីថៃចេញពីដីថៃទៅវិញ បើមិនដូច្នោះទេកងទ័ពថៃត្រូវតែវាយដេញកំចាត់កងទ័ពខ្មែរឱ្យចេញទៅវិញជាដាច់ខាត ។

ជាការពិតណាស់ នៅក្នុងស្ថានភាពតានតឹងនៃការប្រឈមមុខរវាងកងទ័ពខ្មែរ និងថៃ ចាប់តាំងពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៨

ទិវាសហគមន៍ខ្មែរ
CAMBODIAN COMMUNITY DAY
A Festival of Cambodian Culture

ទិវាសហគមន៍ខ្មែរ
Cambodian Community Day

A Festival of Cambodian Culture

Sunday, August 24, 2008
12 p.m. - 6 p.m.
Ben Brenman Park
4800 Brenman Park Drive, Alexandria, VA
www.CambodianCommunityDay.org

FREE ADMISSION

- Artistic Performance
- Arts and Crafts Exhibits
- Folk Games and Sports
- Traditional Cambodian Games
- Live Band
- Food and Refreshment for sale



For more information please contact:

Sophia Tep: 571 - 218- 9513
Mony Suong: 571- 234- 7074
Mealy Chhim: 571- 228- 4142

Proceeds will go toward Promoting Cambodian Culture in The United States and Cambodian Higher Educational Program

Co-sponsored by The Alexandria Department of Recreation, Parks and Cultural Activities and Cambodian Community Day Committee. The City of Alexandria complies with the Americans with Disabilities Act for qualified individuals. If reasonable accommodation is needed, please call 703-838-4844, TTY 838-4902, ten days prior to an event. www.alexandriava.gov

ANGKOR AUTO SERVICE, INC.
ហាងជួសជុលរថយន្ត "អង្គរ"

4835 N. 16th Street.
Philadelphia, Pa 19141

Tel : (215) 455-7810
Fax : (215) 455-7811

Specializing in Body Kit and Custom Paint
ជំនាញខាងជួសជុលតួរថយន្ត
និងបាញ់ថ្នាំដាក់ក្បាច់តាមបំណងភ្ញៀវ

RICKY
Hand Ph.: Ricky 215-485-1425

20 Years in Business
I-Care Certified

Free estimate
We can save your
insurance deductible

Complete Auto Services
-State inspection
-Insurance Claims
-Auto Glass Repairs
-Auto Frame Repairs
-Custom Painting
-Auto A/C

បើកពីម៉ោង ៩ ព្រឹក
ដល់ម៉ោង៥ល្ងាច ពីថ្ងៃ
ច័ន្ទ ដល់ ថ្ងៃ សៅរ៍

ជំងឺហឺត (Asthma)

●●●គឺជាជំងឺរ៉ាំរ៉ៃទូទៅមួយក្នុងចំណោមកុមារ និងមនុស្សពេញវ័យ ជំងឺនេះបណ្ដាលមកពីការរលាក ដោយសារវីរុស (Viral infection) និងបរិយាកាសកខ្វក់ (environmental polltants) ដូចជាស្ថិតនៅក្នុងផ្សែងបារី ។ល។ ការប្រើថ្នាំមួយចំនួនក៏អាចបង្កឱ្យកើតមានជំងឺហឺតបានដែរ ដូចជាថ្នាំ Aspirin និង Non-steroidal សំរាប់ប្រឆាំង និងការហើមរលាក (anti-inflammatory) និងជាសាធាតុហាត់ហ្វឹន ខ្លះទៀត ជាពិសេស បរិយាកាសត្រជាក់ ក៏ងាយបង្កឱ្យមានជំងឺហឺតដែរ ។



A- ជំងឺហឺតដូចម្ដេចដែរ ? What is Asthma?

Asthma គឺជាជំងឺរ៉ាំរ៉ៃមួយដែលប៉ះពាល់ផ្លូវដង្ហើមរបស់អ្នក ។ ផ្លូវដង្ហើមគឺជាបំពង់មួយ ដែលដឹកនាំខ្យល់ចេញចូលពីក្នុងសួត ។ នៅពេល អ្នកមានជំងឺហឺត ផ្លូវដង្ហើមរបស់លោកអ្នកគឺរលាកហើម ។ ការរលាកហើមនេះ ធ្វើឱ្យផ្លូវដង្ហើមងាយប្រតិកម្មទៅ និងវត្ថុធាតុផ្សេងៗហើយឆាប់ទទួលការក្រហល់ក្រហាយ (irritation) ។ នៅលើផ្លូវដង្ហើមវាក៏រងទទួលប្រតិកម្ម ហើយវាក៏រួមតូចខ្យល់ដែលចូលទៅក្នុងជាលិកាសួតក៏តិច ដោយហេតុនេះ វាក៏បណ្ដាលឱ្យទៅ

ជាស្ទះដង្ហើម ឬតឹងដង្ហើម (Wheezing) នៅពេលនោះអ្នកលឺសូរសំលេងដូចហួច នៅពេលអ្នកដកដង្ហើម (whistling sound) វាក៏នាំអោយទៅជាក្អកតឹងដើមទ្រូង និងពិបាកដកដង្ហើម ជាពិសេស នៅពេលយប់ និងពេលជិតភ្លឺ ។

- ជំងឺហឺតនេះពុំអាចព្យាបាលជាសះស្បើយទេ ។

-នៅពេលសហសញ្ញារបស់អ្នកក្លាយទៅជាធ្ងន់ធ្ងរជាងធម្មតា គឺគេហៅថា Asthma Episode or attack ជំងឺហឺតស្រួចស្រាវ) ។ ជំងឺហឺតស្រួចស្រាវនេះ បានបង្កើនការរលាក ហើយបំពង់ដង្ហើមក៏ក្លាយទៅជាហើម ហើយរួមកាន់តែតូចកោសិកាផ្លូវដង្ហើមក៏បញ្ចេញទឹកសំបោរ (mucus) ច្រើនជាងធម្មតា ចំនួនដ៏ច្រើននៃទឹករំអិលនេះ បានធ្វើអោយបំពង់ដង្ហើមរឹតតែរួមតឿតថែមទៀត ការផ្លាស់ប្ដូរទាំងនេះបាន ធ្វើអោយការដកដង្ហើមកាន់តែលំបាក ។

ជំងឺហឺតស្រួចស្រាវនេះ គឺមិនដូចគ្នាទាំងអស់នោះទេ ។ មនុស្សអាចស្លាប់ដោយសារជំងឺហឺតដ៏ធ្ងន់ធ្ងរនេះ ។

បើលោកអ្នកមានជំងឺហឺត គឺសូមទៅជួបជាមួយវេជ្ជបណ្ឌិត ឬគ្រូពេទ្យជំនាញរបស់អ្នក ដើម្បីធ្វើការព្យាបាលអ្នកអោយបានទាន់ពេល ។ ការថែរក្សាជំងឺហឺតរបស់លោកអ្នក គឺជាផ្នែកដ៏សំខាន់មួយ សំរាប់ជីវិតរបស់អ្នក ។ ដូច្នេះការត្រួតពិនិត្យសុខភាពរបស់លោកអ្នក គឺមានន័យថា អ្នកត្រូវតែធ្វើការឱ្យបានជិតស្និតជាមួយវេជ្ជបណ្ឌិតរបស់អ្នក ហើយ និងរៀនធ្វើអ្វីដែលគ្រូពេទ្យរបស់អ្នកឱ្យធ្វើ ។ ឧទាហរណ៍ ដូចជាវេជ្ជបណ្ឌិតប្រាប់អ្នកថាឱ្យស្ថិតនៅឆ្ងាយពីសារធាតុរំខានដល់ដង្ហើមរបស់អ្នកជាដើម រឺក៏ការលេបថ្នាំឱ្យបានទៀងទាត់ ។ល។ ប្រសិនបើលោកអ្នកមិនមានការត្រួតពិនិត្យសុខភាពឱ្យបានល្អទេនោះ ពេលនោះ សហសញ្ញាលេចចេញឡើង បើជាកុមារ គេនឹងខកខានទៅសាលា រឺបើមនុស្សធំ គឺខានធ្វើការងារហើយព្រមទាំងឃ្លាតឆ្ងាយពីបរិយាកាស ដែលអ្នកចង់សប្បាយផងដែរ ។

B- មូលហេតុ (Cause)

វាពុំមានមូលហេតុអ្វីច្បាស់លាស់ ដែលធ្វើឱ្យផ្លូវដង្ហើមចាប់ផ្ដើមរលាកក្នុងដំណាក់កាលដំបូងនោះទេ ។ គេគ្រាន់តែសន្និដ្ឋានថា បើសិនជាសមាជិកគ្រួសាររបស់អ្នកមានជំងឺហឺត នោះអ្នកទំនងជាវិវឌ្ឍន៍ទៅរកជំងឺហឺតនេះ ។ ការស្រាវជ្រាវបានឱ្យដឹងថា ផ្សែងបារី និងការរលាក (Infection) និងប្រតិកម្មខ្លះទៀត (allergens) អាចបង្កើនឱកាសក្នុងការវិវឌ្ឍន៍ជំងឺហឺតនេះ ។

1- ប្រតិកម្ម ឬ ការទាស់ (Allergies) :

- សត្វចតុបាត ដូចជា ស្បែក រោម សក់
- លំអងធូលី ក្នុងផ្ទះជាដើម
- សត្វក្រឡាត -លំអងផ្កា រឺ ស្មៅ -ម៉ូល (Mole) ក្នុងផ្ទះ និងក្រៅផ្ទះ

2- ការរលាក ឬ រោល (Irritants):

- ផ្សែង បារី - ខ្យល់ពុល
- ខ្យល់ត្រជាក់ពេលផ្លាស់ប្ដូររដូវ - ក្លិនឆួលពីការធ្វើម្ហូប រឺថ្នាំលាបជញ្ជាំង
- ផលិតផលក្រអូប - មានអារម្មណ៍រំភើបហួសហេតុ (ដូចជាយំច្រើនពេក សើចហួសហេតុពេក ឬ Stress ជាដើម) ។

3- មូលហេតុផ្សេងទៀត (others)

*ឱសថដូចជា Aspirin និង Beta blockers (ថ្នាំបេះដូង)

*ស្រា និងម្ហូបអាហារដែលមានជាតិ Sulfate

* រលាកដោយវីរុស (viral infection)

C- អ្នកណារងគ្រោះដោយសារជំងឺហឺត (Who is at risk for asthma?)

-មនុស្ស 20លាននាក់ ដែលបានអោយរោគវិនិច្ឆ័យថា មានជំងឺហឺត ក្នុងនោះមាន 9លាននាក់ ជាកុមារ ។

-ថ្វីត្បិតតែជំងឺហឺតប៉ះពាល់ដល់មនុស្សគ្រប់អាយុ ប៉ុន្តែជាញឹកញាប់បំផុតនោះ គឺកើតមានឡើងលើកុមារាច្រើនជាងកុមារី ចំពោះមនុស្សពេញវ័យ គឺវាមានលើស្ត្រីច្រើនជាងបុរស ។ ជំងឺហឺត (Asthma) គឺសំលាប់មនុស្សគ្រប់ជាតិសាសន៍ មិនចំពោះកុមារ រឺមនុស្សពេញវ័យ រឺជាតិសាសន៍ ណាមួយឡើយ ។

D-រោគសញ្ញា និងសហសញ្ញានៃជំងឺហឺត (Sign & symptoms of asthma)

សហសញ្ញាទូទៅ និងជំងឺហឺតរួមមាន :

- ក្អកខ្លាំងនៅពេលយប់ និងជិតភ្លឺ ដែលធ្វើអោយពិបាកដេក

(តទៅទំព័រទី១២)

ជំងឺទឹកនោមផ្អែម (DIABETES)

●●●ពី 8% ទៅ 10% នៃចំនួនប្រជាជនអាស៊ីអគ្នេយ៍ និងកាមេរិកាំងមានជំងឺទឹកនោមផ្អែម ។ ជំងឺទឹកនោមផ្អែម គឺជាជំងឺរ៉ាំរ៉ៃមួយដែលបណ្ដាលឱ្យមនុស្សពេញវ័យ ស្លាប់ឡើងទៅដល់ 70% ។

គេបែងចែកជំងឺទឹកនោមផ្អែមនេះជា ២ ប្រភេទ :

A- Type 1 **ជំងឺទឹកនោមផ្អែម មែលលីតធីស** **(Mellitus)** គឺកើតមានឡើងលើកុមារ និងមនុស្សពេញវ័យ ។ Type 1 នេះ គឺមានខ្វះខាតជាតិ Insulin ក្នុងខ្លួន ឬមកពីលំពែងមិនផលិតជាតិ Insulin ពីកំណើតតែម្ដង ។

B- Type 2 : គឺ 70% មកពី Type 1 មែលលីតធីស (Mellitus)

ជំងឺនេះ គឺកើតឡើងជាញឹកញាប់ទៅតាមអាយុ ឬធាត់ខ្លាំងពេក និងអ្នកមានកាយសម្បទាអសកម្ម ។ បញ្ហាដែលចាប់ផ្ដើមជាដំបូង Type 2 នេះ គឺបណ្ដាលមកពីមានភាពស៊ាំរបស់ Insulin ដល់ឱ្យពីខាងក្រៅយូរៗទៅ ។

នៅក្នុងកូនសៀវភៅតូចនេះ និងលើកយកជំងឺទឹកនោមផ្អែម Type 2 មកជំរាបជូនលោកអ្នកអោយបានជ្រាបខ្លះៗថា Type 2 នេះមានន័យយ៉ាងណា ។

ជំងឺទឹកនោមផ្អែម Type 2 (Type 2 Diabetes) :

1- គោលសំខាន់នៃជំងឺទឹកនោមផ្អែម (Dia-betes basic) :

ជំងឺទឹកនោមផ្អែម Type 2 គឺភាគច្រើនជាទំរង់ធម្មតា ។ កើតជំងឺនេះ គឺមានន័យថាខ្លួនរបស់អ្នកផលិតជាតិ Insulin មិនគ្រប់គ្រាន់ ឬក៏ខ្លួនរបស់អ្នកប្រើប្រាស់ Insulin មិនគ្រប់គ្រាន់ទៅ តាមតម្រូវការរបស់រាងកាយ ។ មុខងារជាតិ Insulin គឺជាអ្នកដឹកនាំជាតិស្ករតាមឈាមទៅឱ្យគ្រប់កោសិកាទាំងអស់ នៅក្នុងរាងកាយរបស់អ្នក ដែលបានត្រូវការជាតិស្ករទាំងនេះ ជាតិស្ករនេះ គឺបានមកពីចំណីអាហារ និងភេសជ្ជៈដែលយើងបរិភោគចូលទៅ ។

ការកើនឡើងជាតិស្ករខ្ពស់ក្នុងឈាម គឺវានាំឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះសុខភាព ។ ដូច្នេះហើយ ការបញ្ចុះជាតិស្ករក្នុងឈាម គឺជាគន្លឹះសំខាន់មួយសំរាប់ត្រួតពិនិត្យជំងឺទឹកនោមផ្អែម Type 2 នេះ ។ ការរក្សាជាតិស្ករក្នុងឈាមរបស់លោកអ្នកឱ្យនៅថេរក្រោមការត្រួតពិនិត្យ គឺវាអាចជួយកាត់បន្ថយនូវគ្រោះថ្នាក់សំរាប់សុខភាពរបស់លោកអ្នកបានយ៉ាងច្រើន ។

2- ការផ្លាស់ប្ដូររបៀបរស់នៅ (Make change for life):

ការគ្រប់គ្រងជំងឺទឹកនោមផ្អែម Type 2 គឺមានន័យថា ធ្វើការផ្លាស់ប្ដូរខ្លះ ចំពោះការរស់នៅរបស់លោកអ្នក ។ សូមនិយាយជាមួយវេជ្ជបណ្ឌិត រឺ គ្រូពេទ្យជំនាញខាងសុខភាពអំពីការផ្លាស់ប្ដូរនេះ អោយបានត្រឹមត្រូវសំរាប លោកអ្នក ។ បើលោកអ្នកសិក្សាឱ្យបានច្រើនអំពីជំងឺទឹកនោមផ្អែមប្រភេទ 2 នេះ លោកអ្នកកាន់តែយល់អំពីការថែរក្សាសុខភាពលោកអ្នកបានកាន់តែប្រសើរផងដែរ ។ ឧទាហរណ៍ដែលអាចជួយដល់លោកអ្នកមានដូចជា :

-បរិភោគចំណីអាហារដែលនាំមានសុខភាពល្អ
- បញ្ចុះទំងន់ប្រសិនបើវេជ្ជបណ្ឌិតប្រាប់
- ស្ថិតនៅជាសកម្ម
-ពិនិត្យជាតិស្ករក្នុងឈាមអោយបានទៀងទាត់
-ត្រូវប្រើប្រាស់ថ្នាំទៅតាមវេជ្ជបញ្ជារបស់គ្រូពេទ្យ
-បញ្ឈប់ការជក់បារី និងសុរា

3- រស់នៅជាមួយ Typ 2 (Life with type2 Diabetes) :

សុខភាពល្អទៅបាន គឺត្រូវតែមានគំរោងការត្រួតពិនិត្យជំងឺនេះ អោយបានត្រឹមត្រូវ ។ ខ្លួន លោកអ្នក និងវេជ្ជបណ្ឌិតរបស់អ្នក គឺត្រូវតែបង្កើតឱ្យមានគំរោងការនេះ ។ គោលបំណងនៃការព្យាបាល គឺថែរក្សាកំរិតជាតិស្ករក្នុងឈាមរបស់អ្នកអោយនៅជាធម្មតា ដូចដែលអ្នកធ្វើទៅបាន ។ ការផ្លាស់ប្ដូរទម្លាប់បរិភោគ និងស្ថិតនៅជាសកម្ម គឺជាជំហានដំបូងយ៉ាងសំខាន់ ។ ការបរិភោគដែលនាំឱ្យមានសុខភាពល្អ និងហាត់ប្រាណ គឺមិនគ្រប់ល្មមក្នុងការបញ្ចុះជាតិស្ករក្នុងឈាមឡើយ គឺសូមអោយលោកអ្នកទទួលទានឱសថផងដែរ ។ ការគ្រប់គ្រងជំងឺទឹកនោមផ្អែម Type 2 នេះគឺត្រូវតែធ្វើការខ្លះដោយព្យាយាម ។

កូនសៀវភៅនេះ គឺជួយអ្នកឱ្យចាប់ផ្ដើមលើ4ចំណុច ជាមូលដ្ឋានគ្រឹះសំរាប់គ្រប់គ្រងជំងឺ Type2 នេះដូចតទៅ :

1- បរិភោគអាហារណាដែលនាំឱ្យមានសុខភាពល្អ

2- រស់នៅក្នុងជីវិតជាសកម្ម

3- ពិនិត្យជាតិស្ករក្នុងឈាមឱ្យបានទៀងទាត់

4-ទទួលទានឱសថតាមវេជ្ជបញ្ជារបស់វេជ្ជបណ្ឌិត

4- សហសញ្ញាគួរដឹង (Know the Symptoms) :

មនុស្សរាប់លាននាក់កើតជំងឺទឹកនោមផ្អែម Type2 នេះ ប៉ុន្តែភាគច្រើនគឺគេពុំស្គាល់សញ្ញារបស់វេ ។ ជំងឺ Type2 នេះ មានសញ្ញា ដូចជា :

- នោមច្រើនដងខុសធម្មតាស្បែកឡើងស្ងួត
-ឃ្លានអាហារ និងស្រេកទឹក-ឈឺចាក់ឆៀបៗ រឺស្ពឹកចុងដៃចុងជើង
-បាត់បង់ទំងន់ -កម្រជាសះស្បើយពីស្នាមរបួស
-ស្រវាំងភ្នែក-ងាយទទួលជំងឺផ្សេងៗ

រោគសញ្ញា និងសហសញ្ញាទាំងនេះគឺបណ្ដាល មកពីការកើនឡើងខ្ពស់នៃជាតិស្ករក្នុងឈាម ។ ហេតុការណ៍នេះយូរទៅ វានាំឱ្យមានបញ្ហាសុខភាពធ្ងន់ធ្ងរ ។ ប៉ុន្តែប្រសិនបើលោកអ្នកគ្រប់គ្រងជាតិស្ករក្នុងឈាមរបស់លោកអ្នកពីពេលនេះទៅលោកអ្នកនឹងអាចកាត់បន្ថយបាននូវបញ្ហាគ្រោះថ្នាក់ដល់សុខភាព ដោយសារជំងឺទឹកនោមផ្អែមនេះ ។

5- ការការពារបញ្ហាគ្រោះថ្នាក់ដល់សុខភាព (Prevent Health Problems) :

ការត្រួតពិនិត្យជាតិស្ករក្នុងឈាមឱ្យបានល្អ គឺអាចកាត់បន្ថយគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពដូចតទៅ :

± ជំងឺបេះដូង និងជំងឺដាច់សរសៃឈាមក្នុងខួរក្បាល (Heart Disease & Stroke): ជំងឺនេះគឺបណ្ដាលឱ្យស្លាប់ដោយសារជំងឺទឹកនោមផ្អែម ។

±ជំងឺលើសឈាម (High Blood Pressure): មនុស្សពេញវ័យកើតជំងឺទឹកនោមផ្អែមជាច្រើនមានជំងឺលើសឈាម ហើយក៏ប្រើថ្នាំសំរាប់ជំងឺលើសឈាមដែរ ។ លោកអ្នកត្រូវប្រាប់វេជ្ជបណ្ឌិតរបស់លោកអ្នក និងសំរួលឱ្យគ្រូពេទ្យរបស់អ្នកពិនិត្យ និងវាស់ឈាមឱ្យអ្នករាល់ពេលជួបជាមួយវេជ្ជបណ្ឌិត រឺគ្រូពេទ្យថែទាំសុខភាពរបស់អ្នក ។ អ្នកមានជំងឺទឹកនោម

(តទៅទំព័រទី១២)

ជំងឺទឹកនោមផ្អែម (DIABETES)

ផ្អែម គួរតែព្យាយាមថែរក្សាសម្ពាធឈាមរបស់អ្នកឱ្យទាបជាង 130/80mmHg ។

- បញ្ហាភ្នែក (Eye Problems)

អ្នកមានជំងឺទឹកនោមផ្អែម អាចមានគ្រោះថ្នាក់ ដល់ភ្នែកដូចជា :

- ភ្នែកឡើងបាយ (Cataract) - ងងឹតភ្នែក (Glaucoma)

- ដោយសារខូចរ៉េទីន (Retina)

សូមលោកអ្នកទៅពិនិត្យភ្នែកយ៉ាងហោចណាស់ឱ្យបានម្តងក្នុងមួយឆ្នាំ ។

- ការប៉ះពាល់តំរងនោម (Kid Roy Damage)

ជំងឺទឹកនោមផ្អែមគឺបណ្តាលឱ្យខូចតំរងនោមធន់ធរ ។ វេជ្ជបណ្ឌិត និងពិនិត្យទឹកនោមរបស់អ្នកមួយឆ្នាំម្តង ដើម្បីរកជាតិ ប្រូតេអ៊ីន ក្នុងទឹកនោម ប្រសិនបើក្នុងទឹកនោមអ្នកមានជាតិ ប្រូតេអ៊ីន (Protein) វិជ្ជមានមានន័យថាតំរងនោមរបស់អ្នកត្រូវបានខូចខ្លះហើយ ដោយសារជំងឺទឹកនោមផ្អែម ឬជំងឺលើសឈាមនេះ ។

- ការខូចសរសៃប្រសាទ (Nerve Damage)

ត្រូវពិនិត្យជើងរបស់លោកអ្នកប្រសិនមានស្នាមរបួសតិចតួចហើម ឬរលាកដោយអ្វីមួយ ឬក៏ឈឺចាប់ខ្លាំង សូមទៅជួបជាមួយវេជ្ជបណ្ឌិត ឬគ្រូពេទ្យថែទាំសុខភាពអ្នកឱ្យបានឆាប់រហ័ស ព្រោះវាជាមូលហេតុដ៏ធំមួយដែលបណ្តាលឱ្យ ទៅជាធ្ងន់ធ្ងរ រហូតដល់កាត់ជើងចេញ ក៏មានដែរ (Amputation) ។

6- សិក្សាអំពីការប្រើឱសថរបស់អ្នក (Learn about your medicine)

វេជ្ជបណ្ឌិតរបស់អ្នក និងឱ្យវេជ្ជបញ្ជាស្របជាមួយ និងតារាងរបបអាហារ ហើយស្ថិតនៅជាសកម្ម ។ ឱសថជាច្រើនអាចជួយត្រួតពិនិត្យជាតិស្ករក្នុងឈាមឱ្យមានស្ថេរភាពដូចធម្មតាបានដែរ គឺវាប្រសើរជាជាងការចាក់ជាតិ Insulin ។ គ្រូពេទ្យអ្នកនិងប្រាប់អ្នកឱ្យប្រើថ្នាំណា ដែលអ្នកត្រូវការ ។ មនុស្សភាគច្រើនគឺចាប់ផ្តើមលេបថ្នាំគ្រាប់ (Pills) នៅពេលមាន Type 2 វេជ្ជបណ្ឌិតរបស់អ្នក និងឱ្យវេជ្ជបញ្ជាថ្នាំគ្រាប់មួយ ឬពីរប្រភេទ សំរាប់ដំណាក់កាលដំបូង ។ លើសពីនេះទៀត វេជ្ជបណ្ឌិតរបស់អ្នក និងជួយធ្វើការផ្លាស់ប្តូរការត្រួតពិនិត្យជាតិស្ករ ក្នុងឈាមដូចជា

- ផ្លាស់ប្តូរកំរិតជាតិថ្នាំ (Change your dose)

- បន្ថែមថ្នាំថ្មី (Add a new pill)

-ប្តូរថ្នាំគ្រាប់ (Switch pill)

-បូករួមទាំង Insulin (Include insulin)

ឱសថនិមួយៗ គឺជួយបញ្ចុះជាតិស្ករក្នុងឈាម តាមរបៀបខុសៗគ្នា ។ ថ្នាំខ្លះបញ្ចូលគ្នា 2 គ្រាប់ ទៅជាមួយគ្រាប់ គឺវាងាយស្រួលដល់អ្នកជំងឺលេបហើយវាមានប្រសិទ្ធិភាពល្អទៀតផង ។ ចូរចងចាំថា : ឱសថគឺគ្រាន់តែជាផ្នែកមួយនៃតារាងការព្យាបាលតែប៉ុណ្ណោះ សូមលោកអ្នកកុំភ្លេចការបរិភោគអាហារដែលនាំឱ្យមានសុខភាពល្អ និងស្ថិតនៅជាសកម្ម ព្រមទាំងពិនិត្យ ឬតេស៍ ជាតិស្ករក្នុងឈាមអោយបានទៀងទាត់ផង ។

៧- វិធីខ្លះ សំរាប់ជួយដល់ការលេបថ្នាំរបស់អ្នក (Tips for taking your medicine)

សូមធ្វើកាលវិភាគ ដូច្នេះអ្នកមិនអាចភ្លេចការលេបថ្នាំរបស់អ្នកឡើយ ។ ត្រូវដាក់វាតាមខ្លួនជានិច្ច ហើយថតចំលងឱ្យទៅមិត្តភ័ក្ត ឬគ្រួសាររបស់អ្នកជួយរំលឹកអ្នក ។ សូមសាកល្បងតាមវិធីនេះ ប្រហែលជាអាចជួយជៀសវាងការភ្លេចលេបថ្នាំរបស់អ្នក :

- ធ្វើវាឱ្យទៅជាទម្លាប់ប្រចាំថ្ងៃ : គឺត្រូវលេបថ្នាំក្រោយពេលដុះធ្មេញរួច ។

-ប្រើនាឡិការោទ៍ : កំណត់ម៉ោងឱ្យវារោទ៍សំរាប់ម៉ោងលេបថ្នាំ

-ប្រើប្រអប់ថ្នាំ : ដោយដាក់វាកន្លែងនាឡិកា ឬជិតទ្វារ

-មានប្រតិទិន : សំរាប់តាមដានថ្ងៃ ត្រូវបន្ថែមថ្នាំ ថ្នាំអ្វីក៏ដោយដែលអ្នកលេបគឺត្រូវតែ :

- ធ្វើតាមវេជ្ជបញ្ជារបស់វេជ្ជបណ្ឌិត

- សូមកុំប្តូរកំរិតជាតិថ្នាំ ត្រូវប្រាប់វេជ្ជបណ្ឌិតប្រសិនបើមានបញ្ហា

-ត្រូវស្គាល់ថ្នាំដែលអ្នកលេប : ហើយត្រូវកត់ វាទុក ដើម្បីបង្ហាញវេជ្ជបណ្ឌិត ឬឱសថការីឱ្យបានដឹងថា ថ្នាំណាមួយមានប្រសិទ្ធិភាពចំពោះអ្នក ។

8- ចំណីអាហារ និងស្ថិតនៅជាសកម្ម (Foods and be more active)

A-បរិភោគត្រឹមត្រូវរស់បានយូរ (Eat well to live well)

ការបរិភោគអាហារដែលនាំអោយមានសុភាពល្អ រួមជាមួយការលេបថ្នាំ និងស្ថិតនៅជាសកម្ម គឺអាចជួយបញ្ចុះជាតិស្ករក្នុងឈាមអ្នក ។ ការបរិភោគត្រឹមត្រូវអាចជួយអោយអ្នកស្រកទំងន់ និងជាតិស្ករក្នុងឈាមចុះថយ ក៏ដូចជា Cholesterol និងសម្ពាធឈាមក៏ចុះថយដែរ ។ វាជាការ ពិបាកអនុវត្តន៍ឱ្យបានត្រឹមត្រូវជារៀងរាល់ថ្ងៃណាស់ តែសូមអោយព្យាយាមធ្វើឱ្យត្រឹមត្រូវខ្លះ ជារៀងរាល់ថៃនោះ វានិងជួយបានយ៉ាងច្រើន ទៅហើយ ។

- របៀបបរិភោគអាហារឱ្យមានសុខភាពល្អ (Healthier eating habits)

-ហូរអាហារដែលមានជាតិខ្លាញ់តិចបំផុត

-បរិភោគ Salad ហើយដាក់ dressing ឱ្យតិច

-ផឹកទឹកមួយកែវ បន្ថយឃ្លាន នៅ១០នាទីមុនពេលបរិភោគអាហារ ។

-ព្យាយាមស្តាប់ភ្លេង ពេលបរិភោគអាហារ

-ហូបយូរហ្គឺត (Yogurt), ឈីស (Cheese) ដែលមានជាតិធាត់តិច

-ទឹកដោះគោ 1%

-ហូបផ្លែឈើ និងបន្លែដូចជា :

-ផ្លែប៉ោម (AppleJ) -ផ្កាខាត់ណាស (Cauliflowers)

- ប្លូប៊ែរី (Blue berries) -ស្ពៃណិច (Spinach)

- ខាន់ថាឡូភ (Cantaloupe) -ប៉េងប៉ោះ (Tomato)

-ស្ត្របឺរី (Strawberries) -ផ្កាខាត់ណាខៀវ (Brocali) -ការ៉ុត

-ចំណីអាហារមិនគួរបរិភោគ :

- អាហារដែលមានជាតិខ្លាញ់ច្រើន ឬក្រែម (Cream)

- កុំបរិភោគផ្អែម ឬប្រៃ និងហិល

- បញ្ឈប់ជាតិស្រវឹង និងបារី

បើលោកអ្នកចង់ជ្រាបព័តិមានបន្ថែមទៀត សូមសួរទៅវេជ្ជបណ្ឌិត ឬគ្រូពេទ្យជំនាញខាងម្ហូបអាហារថែមទៀត ដើម្បីអោយលោកអ្នកមានសុខភាពកាន់តែប្រសើរឡើង ។ កូនសៀវភៅនេះគ្រាន់តែជួយជាព័តិមានខ្លះដល់លោកអ្នកតែប៉ុណ្ណោះ ។

B- ស្ថិតនៅសកម្ម (Be more Active)

ការរស់នៅជាមួយសកម្មភាព គឺអាចជួយកាត់បន្ថយជាតិស្ករក្នុងឈាមបានខ្លះដែរដូចជា :

-ការថែរក្សាទំងន់ឱ្យបានល្អតាមកំណត់

-ដើរជំនួសការបើកបរ

-ឡើងជណ្តើរជំនួសជណ្តើរយាន្ត

-ធ្វើហត្ថកម្ម នៅក្នុងសួនច្បារ ឬ ក្រោមផ្ទះ

-បោសសំអាតផ្ទះ ឬ បោសផ្ទះ ជូតផ្ទះ

-លាងឡាន ឬ ជូតឡាន

-ដុសលាងកញ្ចក់បង្អួច ។ល។

C- ធ្វើតេស៍ឈាមដើម្បីពិនិត្យជាតិស្ករ (Test your blood sugar)

ការពិនិត្យកំរិតជាតិស្ករក្នុងឈាមគឺជាគន្លឹះសំខាន់មួយ សំរាប់អ្នកជំងឺទឹកនោមផ្អែម ។ សូមពិភាក្សាជាមួយវេជ្ជបណ្ឌិត ឬគ្រូពេទ្យថែទាំសុខភាពរបស់អ្នកអំពីការពិនិត្យជាតិស្ករក្នុងឈាមនេះ ។

អត្ថបទនេះគ្រាន់តែជួយលោកអ្នកអោយបានយល់ដឹងខ្លះៗ អំពីសភាពជំងឺ និងវិធីខ្លះគួរជៀសវាង និងគួរប្រតិបត្តិតាម ដើម្បីជួយដល់ការថែទាំសុខភាពរបស់លោកអ្នកតែប៉ុណ្ណោះ ។

សំរាប់ព័តិមានបន្ថែមអំពីសុខភាព សូមទាក់ទងមកលោក Hasven Lim នៅ SEAMAAC តាមទូរសព្ទ័លេខ : ២១៥-៤៦៧-០៦៥០

សូមអរគុណ ។

ជំងឺហឺត (Asthma)

- ដកដង្ហើមឮសូរហ៊ឹតៗ

- តឹងដើមទ្រូង ដូចគេច្របាច់ រឺ អង្គុយលើដើមទ្រូង

-ដកដង្ហើមញាប់ ហើយរំខានដោយឮសំលេង ហ៊ឹតៗ

-ដកដង្ហើមផុតៗ ដូចខ្យល់ចេញចូលមិនគ្រប់

E. ការព្យាបាល (Treatment)

កូនសៀវភៅនេះ ពុំប្រាប់ពីវិធីប្រើប្រាស់ឱសថទេ ប៉ុន្តែវានិងប្រាប់ពីរបៀបដែលអ្នកត្រូវធ្វើ និងជួបជាមួយគ្រូពេទ្យ រឺ វេជ្ជបណ្ឌិតរបសអ្នកដូចខាងក្រោមនេះ :

-ត្រូវទំនាក់ទំនងជិតស្និទ្ធជាមួយវេជ្ជបណ្ឌិត ដើម្បីសំរេចចិត្តលើទិសដៅ និងព្យាបាលរបស់អ្នក និងរៀនយ៉ាងណាអោយបានសំរេចគោលបំណងនៃការព្យាបាលនេះ ។

-ត្រូវជៀសវាងវត្ថុធាតុណា ដែលនាំអោយសហាសញ្ញាជំងឺហឺតនេះ ទៅជាធន់ធរ ។

-ត្រូវលេបថ្នាំ រឺ ចាក់ថ្នាំអោយបានទៀងទាត់ ដើម្បីគ្រប់គ្រងជំងឺហឺតនេះ ចំពោះអ្នកជំងឺហឺតខ្លះ។

-ត្រូវតាមដានសភាពជំងឺរបស់អ្នកជាប់ជានិច្ច ដើម្បីការពារ រឺបញ្ឈប់ជំងឺហឺតស្រួចស្រាវ។

សូមសួរវេជ្ជបណ្ឌិតរបស់អ្នកអោយបានច្បាស់បន្ថែមទៀត អំពីជំងឺនេះ តើអ្នកត្រូវធ្វើយ៉ាងដូចម្តេច ? ដើម្បីថែរក្សា និងការពារជំងឺហឺតរបស់លោកអ្នក ។ កូនសៀវភៅនេះ គ្រាន់តែជាជំនួយដល់អ្នកតែប៉ុណ្ណោះ ។

F- វិធីការពារជំងឺហឺត (Asthma prevention)

វិធីការពារជំងឺហឺត គេពុំទាន់ដឹងធ្វើយ៉ាងម៉េចនៅឡើយទេ ប៉ុន្តែមានរបៀបខ្លះ ដែលអាចជួយកាត់បន្ថយឱកាសដែលនាំអោយមានជំងឺហឺត ស្រួចស្រាវ (Asthma Attack) នោះ ។

- ការការពារសហាសញ្ញានៃជំងឺហឺត :

-ត្រូវសិក្សាអំពីជំងឺហឺតរបស់អ្នក និងធ្វើយ៉ាងណាគ្រប់គ្រងវាឱ្យបាន :

-ប្រើឱសថឱ្យត្រូវតាមវេជ្ជបញ្ជារបស់វេជ្ជបណ្ឌិត

-ជៀសវាងវត្ថុធាតុដែលនាំឱ្យជំងឺហឺតទៅជាធន់ធរ

-ត្រូវឱ្យវេជ្ជបណ្ឌិត ពិនិត្យអោយបានទៀងទាត់

-តាមដានសភាពជំងឺហឺតរបស់អ្នកទូវរាល់ពេលដែលវាប្រែប្រួល (Self management plan)

-ត្រូវស្ថិតនៅឱ្យឆ្ងាយពីផ្សែងបារី

-ត្រូវជៀសវាងបរិភោគម្ហូបអាហារណាដែល ធ្វើឱ្យអ្នកឡើងទំងន់លឿនទៅជាធាត់ហួសហេត (Obesity) ។

Obesity នេះវាបណ្តាលឱ្យមានបញ្ហាដល់សុខភាពរបស់លោកអ្នកកាន់តែខ្លាំង។

សំរាប់ព័តិមានបន្ថែមអំពីសុខភាព សូមទាក់ទងមកលោក Hasven Lim នៅ SEAMAAC តាមទូរសព្ទ័លេខ : ២១៥-៤៦៧-០៦៥០

សូមអរគុណ ។

SOMALIE 1983-2008

•••ហុង សុមាលី បានទទួលមរណភាព នាពេលមានអគ្គីភ័យមួយ ដែលកើតឡើងនៅផ្ទះនាង ផ្លូវ Nedro និងលេខ២ នាតំបន់ខាងជើងហ្វីឡាដែលហ្វីយ៉ា ។

នាងបានលាលោកនេះទៅដោយទុកចោលកូនតូចអាយុ៣ខែ និងមិត្តប្រុសមិនទាន់រៀបការជាទីស្រឡាញ់របស់នាង នៅម៉ោង៦ព្រឹក នាថ្ងៃអាទិត្យ ទី២៧ ខែកក្កដា ឆ្នាំ២០០៨ ក្នុងអាយុ២៥ឆ្នាំ ។

ហុង សុមាលី ក៏ជាទីស្រឡាញ់របស់សមាគមន៍ខ្មែរដែរ ដោយជាមួយបងប្អូនស្រី ៣នាក់ គឺផល្លី និង សាលី ដ៏ឆ្លាតវៃរហ័សរហួន ហើយជាពិសេសរូបសម្ផស្សស្រស់ស្អាតដូចគ្នា បានចូលរួមក្នុងចលនាសិល្បៈវប្បធម៌ក្នុងសមាគមន៍ខ្មែរ យ៉ាងសកម្មជាច្រើនឆ្នាំ ធ្វើឱ្យសមាគមន៍ខ្មែរមួយនេះ មានមុខមាត់ប្រសើរ មិនចាញ់សមាគមន៍ឯទៀតៗឡើយ ។

នាព្រឹកថ្ងៃអាទិត្យនោះ មិត្តប្រុសកូនតូច និង សុមាលី ពុំបានឮសម្រែករបស់ឪពុកម្តាយនាងហៅឱ្យចេញពីផ្ទះយ៉ាងប្រញាប់ប្រញាល់នោះទេ ដល់ពេលឮ ! ផ្សែងបានព័ទ្ធជុំជិតខ្លួនមើលអ្វីលែងឃើញទៅហើយមិត្តប្រុសបីកូនរត់តាមសម្រេចហៅរបស់ឪពុក សុមាលី ទំនងរត់សំដៅបង្អួចដើម្បីលោតតាមនោះ តែពុំឃើញ សុមាលី ហុង ចេញមកទេ... ភ្លើងបានឆាបយកផ្ទះ និង ជីវិត សុមាលី ទៅជាមួយបាត់ទៅហើយ ៕

ទំព័រហ្វីឡាដែលហ្វីយ៉ា

ពីរដ្ឋបាលកុលសម្ព័ន្ធមករដ្ឋាភិបាលសម័យ

ដោយ : ពិនសំខុន ***តពីលេខមុន***

.ថ្ងៃទី២៥-២៦ កញ្ញា ឆ្នាំ១៩៥៥

មហាសន្និសីទរបស់ "សង្គមរាស្ត្រនិយម" លើកទី២ ស្នើច្បាប់ឱ្យសិទ្ធិដល់ស្ត្រីឱ្យអាចចូលបោះឆ្នោតបាន ហើយនឹងគោលការណ៍បង្កើតសភាខេត្ត ។

.ថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៥៥

ផ្តើមដំណើរការណ៍ "សង្គម" ដែលជារបបគណបក្សទោលរដ្ឋាភិបាលទី១ ដឹកនាំដោយសម្តេចនរោត្តមសីហនុ ។

១.រដ្ឋាភិបាលនរោត្តម សីហនុ (៣.១០.១៩៥៥-៥.១.១៩៥៦)

. នាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីការបរទេស : នរោត្តម សីហនុ

. ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-ផែនការ និងអប់រំជាតិ : សម សារី

. រដ្ឋមន្ត្រីការពារជាតិ : លន់ ណុល

. រដ្ឋមន្ត្រីយុត្តិធម៌ និងធម្មការ : ជួប សំឡុត

. រដ្ឋមន្ត្រីសាធារណការ និងដឹកទូរគមនាគមន៍ : គួ រុន

. រដ្ឋមន្ត្រីថវិកា : ម៉ៅ សាយ

. រដ្ឋមន្ត្រីសាធារណសុខាភិបាល និងព័ត៌មាន : ហួត សំអាត

. រដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកការងារ-សង្គមកិច្ច និងបញ្ហាបោសសំអាតទូទៅ : ហឿ ឡាយអ៊ីនំ

. រដ្ឋលេខាធិការកសិកម្ម និងកិច្ចការកសិករ : ញាណ គ្រឿន

. រដ្ឋលេខាធិការពាណិជ្ជកម្ម និងឧស្សាហកម្ម : លី ជិនលី

. រដ្ឋលេខាធិការអប់រំជាតិ : ហួត សម្បត្តិ

ថ្ងៃទី១៨ តុលា : នៅក្នុងអត្ថបទមួយនៃកាសែត "ណាស្យុណាលីស" សម្តេច សីហនុ បានសរសេរពីរបបកុម្មុយនីស្តខ្មែរ ដូចអ្វីដែលនឹងកើតឡើងនៅ២០ក្រោយមក ។

ថ្ងៃទី០១ វិច្ឆិកា : គណបក្សប្រជាជនកម្ពុជាបានបង្កើតសហជីពសេរីកម្មករមួយ ១៥ វិច្ឆិកា សីហនុ សរសេរសៀវភៅមួយ"ដែនដីកូសាំងស៊ីន" ដែលនៅក្នុងនោះ ព្រះអង្គ ធ្វើការចោទប្រកាន់យ៉ាងខ្លាំងក្លា ការដេលវៀតណាមធ្វើខ្មែរក្រោមឱ្យទៅជាយួន ។

. ឆ្នាំ១៩៥៦

ថ្ងៃទី០៥ មករា : រដ្ឋាភិបាល "សង្គម" លើកទី២ ដឹកនាំដោយលោក អ៊ុំ ឈាងស៊ុន

២. រដ្ឋាភិបាល អ៊ុំ ឈាងស៊ុន (៥.១.១៩៥៦-១.៣.១៩៥៦)

. នាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីមហាផ្ទៃ និងបោសសំអាត : អ៊ុំ ឈាងស៊ុន

. រដ្ឋមន្ត្រីការពារជាតិ និផងការពារលើផ្ទៃប្រទេស : ស៊ីសុវត្ថិ ស៊ីរិមតៈ

. រដ្ឋមន្ត្រីការបរទេស : ខៀវ វ៉ាន

. រដ្ឋមន្ត្រីហិរញ្ញវត្ថុ : ប្រាក់ សារិន

. រដ្ឋមន្ត្រីផែនការ-កសិកម្ម និងចិញ្ចឹមសត្វ : ផ្លែក ភីន

(តទៅលេខក្រោយ)

អត្ថបទស្តីអំពីខន្ធ៥ និងសមាធិវិបស្សនា

តពីលេខមុខ

ពេលអរមកដល់ ក៏អរតាមនោះទៅ ... នោះហើយមនុស្សយើងម្នាក់ៗរស់នៅកើតទុក្ខក្រៀមក្រំក្រោមឥទ្ធិពលនៃគំនរកម្ម (សញ្ញាយន្ទ សង្ខារខន្ធ) ចេញពីខាងក្នុងខ្លួនមក ។

អ្នកប្រតិបត្តិធម៌ ប្រតិបត្តិសមាធិ ឃើញពិតអំពីមូលហេតុនៃការកើតទុក្ខ ហើយផ្តាច់ខ្លួនលែងដើរតួដូចមុនៗទៀត ។ ពិសេស សមាធិ ផ្តល់ឧទាហរណ៍ សំរាប់ផ្តាច់ខ្លួននោះឯង ។ អ្នកប្រតិបត្តិសមាធិ បានរួចរំដោះអំពើការតំរាមកំហែងរបស់ប្រពន្ធប្រតិកម្ម (សញ្ញាខន្ធ សង្ខារខន្ធ) ទៀត ។ ចិត្តរបស់គេត្រូវបានបោសសំអាតជាប្រចាំ ហើយកាន់តែបរិសុទ្ធឡើងៗ ។ ជីវិតរបស់គេក្លាយទៅជាមានន័យ មានពន្លឺ សន្តិភាព សុភមង្គល ។ សុភមង្គលនេះ ពុំមែន កើតឡើងឯងៗនោះទេ គឺមនុស្សជាអ្នកកើតវាឡើងតាមមាគ៌ាព្រះពុទ្ធ ។ ដូចនេះ អ្នកប្រាជ្ញក្នុងលោក បានចាត់ទុកវិធីសមាធិ វិប្បសនា ជាសិល្បៈនៃជីវិត ។ (ART OF LIVING) ។

អ្នកប្រាជ្ញខ្លះក៏បង្ហាញហេតុផលជាច្រើនទៀតថា វិធីសមាធិ ពុំមែនត្រឹមតែជួយឱ្យមនុស្សសរស់នៅក្នុងសេចក្តីសុខសាន្តប៉ុណ្ណោះទេ ។ វិធីនេះ ជួយសំរួលនៅពេលមនុស្សស្លាប់ទៀតផង ។ លោកទាំងអស់នោះ បាននិយាយថា វិធីនៃសមាធិ ជាសិល្បៈនៃការស្លាប់ (ART OF DYING) ។ យើងម្នាក់ៗពុំដែលធ្លាប់បានស្លាប់ទេ ដូច្នេះ ពុំដឹងថា តើមានហេតុអ្វីខ្លះ កើតឡើងនៅពេលនោះ ? យើងស្តាប់អ្នកប្រាជ្ញ បណ្ឌិត

និយាយអំពីរឿងនេះ :

មុនពេលមនុស្សដាច់ខ្យល់ស្លាប់ រូបកាយទាំងមូលស្លាប់ រូបកាយទាំងមូលចុះងន់ខ្សោយណាស់ហើយ ។ **សញ្ញាខន្ធ** ដែលជាស្តុបពិសោធន៍របស់មនុស្សមួយជីវិត បានកក្រើករំពើកយ៉ាងខ្លាំងក្លា មនុស្សយើងជាម្ចាស់ពុំមានសិទ្ធិទេ រចនាជីវិតមានទេ ព្យុះកម្មបោកបក់មហិមា សង្ខារខន្ធក៏ប្រតិកម្មទៅរកជាភ័យខ្លាច ទុក្ខ... រូបភាពនៃចិត្តកករល្អក់ដូចភក់ បង្កើតបានជាគ្រាប់ពូជដ៏ខ្មៅសំរាប់អនាគតជាតិ ។

សំរាប់អ្នកវិជ្ជាខាងសមាធិ ដោយកន្លងមកជននោះ បានបន្តបោសសំអាតចិត្តជារឿយៗ ចិត្តរបស់គេពុំសូវមានពណ៌សម្បុរខ្មៅ គេទំលាប់គ្រប់គ្រងចរន្តរលកចិត្តបានពីមុនមកហើយ ។ មុនពេលដាច់ខ្យល់ស្លាប់ជននេះ បន្តបោសសំអាតចិត្តគេ គេម្ចាស់លើចរន្តចិត្តទាំងស្រុង ម្លោះហើយចិត្តរបស់គេល្អផូរផង់ នេះជាគ្រាប់ពូជដ៏ល្អបំផុតសំរាប់អនាគតជាតិ ។

ព្រះពុទ្ធទ្រង់ត្រាស់ថា កើតជាមនុស្សជាការកំរណាស់ ។ កើតជាមនុស្សហើយ កំរនឹងបានស្គាល់ព្រះធម៌ណាស់ (មានន័យថា កំរនឹងយល់ដឹងអំពីរអាចិកំបាំង ក្រិតក្រំផ្លូវចិត្ត) ។

សូមព្រះធម៌ជ្រួតជ្រាបដល់មនុស្សគ្រប់រូបសំរាប់ជាកុសលដល់ខ្លួនផ្ទាល់ និងសង្គមទាំងមូល ។

ដោយឧទ្ទវក្តិមេត្តា
ម៉ៅ ចាន់សំណុំ

នេះ **(តទៅទំព័រទី១៣)**

ថៃនាំមន្ត្រីយោធាអមស្ថានទូត...

គឺកងទ័ពប្រដាប់អាវុធរបស់ថៃ បានចាប់ផ្តើមបញ្ជូនចូលមកកាន់កាប់គ្រប់គ្រងប៉ុនប៉ងរឹបអូសយកប្រាសាទព្រះវិហារ ដែលថៃប្រកាសទាមទារថា ជារបស់ថៃនោះវិញ ។

សន្ធិសញ្ញាទាំងអស់ សាលក្រមកាត់ក្តីនៃតុលាការអន្តរជាតិក្រុងឡាអេ ប្រទេសហុល្លង់ រួមទាំងឯកសារប្រវត្តិសាស្ត្រប្រទេសខ្មែរ តាំងពីសម័យមុនអង្គរមកនោះ វាជាការគ្រប់គ្រាន់ និងច្បាស់លាស់ណាស់ថា ប្រាសាទព្រះវិហារ និងតំបន់ជុំវិញប្រាសាទព្រះវិហារ ដែលមានកំណត់តាមរយៈផែនទីទទួលស្គាល់ពីប្រទេសទាំងពីរ តាមសន្ធិសញ្ញាអន្តរជាតិ ពុំមានអ្វីដែលប្រទេសថៃត្រូវតែលើកទ័ពចូលមកឈ្លានពានបង្កជម្លោះនៃថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៨ នេះទេ ។

ចំណែកការចរចារដោះស្រាយ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ នេះទៀតសោតភាគីប្រទេសខ្មែរ ពុំត្រូវទៅស្រុះស្រួលដកទ័ពចេញពីតំបន់ក្នុងព្រំដែនដ៏ត្រឹមត្រូវរបស់ខ្មែរនេះទេ គឺមានតែភាគីថៃទេ ដែលត្រូវតែដកទ័ពចេញឱ្យអស់ពីទឹកដីខ្មែរ ។

បញ្ហាដាក់បញ្ចូលប្រាសាទព្រះវិហារ រួមនឹងព្រំដែនតំបន់ប្រាសាទព្រះវិហារ បើថៃពុំព្រមគោរព និងពុំព្រមទទួលស្គាល់ទេ ប្រទេសថៃ និងរដ្ឋាភិបាលថៃ ត្រូវតែដាក់ពាក្យបណ្តឹងតវ៉ាទាមទារឱ្យតុលាការអន្តរជាតិនៃអង្គការសហប្រជាជាតិ សើររើលើបញ្ហានេះ យកមកជំនុំជំរះសារជាថ្មីម្តងទៀត ហើយត្រូវរង់ចាំសេចក្តីសម្រេចនៃតុលាការនេះ ។ ពេលនោះ បើប្រទេសថៃឈ្នះក្តី រដ្ឋាភិបាលថៃ និងប្រទេសថៃ មានអំណាចបញ្ជូលកងទ័ពមកដេញកំចាត់កងទ័ពខ្មែរបាន បើសិនជាខ្មែរនៅក្រាញពុំព្រមដកចេញពី

នាទី អរិយធម៌ខ្មែរ

វប្បធម៌ខ្មែរ

កង្កែប ជាឈ្មោះសត្វទឹកមួយប្រភេទមានជើងបួន ចេះហែលទឹក មុជទឹក លោតឡើងលើគោកក៏បាន ច្រើននៅអាស្រ័យនឹងទីក្បែរមាត់ទឹក ឬនឹងរទ្ធដីក៏នៅបាន ។

កង្កែបមានបីប្រភេទ :

-កង្កែបកួប (មាឌរូបធំ យំឮសូរកួបៗ)

-កង្កែបប្រុយ (មាឌតូច ដងខ្លួនវែង ជើងវែងៗ អ្នកខ្លះហៅថា កូនស្ទើន)

-កង្កែបអាចម៍គោ (មាឌប៉ុនគ្នានិងកង្កែបប្រុយ ប៉ុន្តែដងខ្លួនខ្លី ជើងក៏ខ្លីដែរ សម្បុរស្ទើលឿង នៅតែក្នុងកំពាយអាចម៍គោលើគោក) ។

ពាក្យប្រៀនប្រដៅ :

+បើម៉ែ្វនឹងចេះ ឱ្យគេកោត
-បើម៉ែ្វនឹងឆោត ឱ្យគេរាណិត
-បើម៉ែ្វនឹងហ៊ាន ឱ្យមានចិត្ត
-បើម៉ែ្វនឹងគិត ឱ្យបានការ ។
+បើម៉ែ្វនឹងកាច ឱ្យពេញវង់
-បើម៉ែ្វនឹងល្ងង់ ឱ្យផុតថា
-បើម៉ែ្វនឹងប្រាជ្ញ ឱ្យបានការ
-បើម៉ែ្វនឹងគេថាឱ្យបានខ្នាត ។

ប្រវត្តិឈ្មោះភ្នំឧដុង្គ :

បើគេធ្វើដំណើរតាមផ្លូវជាតិលេខ៥ ចេញពីទីក្រុងភ្នំពេញឆ្ពោះទៅខេត្តបាត់ដំបង បានចម្ងាយ ៣៧គីឡូម៉ែត្រ នៅខាងត្បូងផ្លូវប្រហែល៣គីឡូម៉ែត្រ គេនឹងឃើញភ្នំចម្លែកមួយប្រកបដោយកំពូលខ្ពស់ត្រដែតជាងគេពាកន្លែង សណ្តុកទទឹងថ្ងៃ ពីខាងជើងទៅខាងត្បូង ដែលមានរាងដូចសត្វមករវាត់កន្ទុយពីក្រោយមកមុខ ។ នៅលើភ្នំមានចេតិយធំៗជាច្រើន ដែលស្តេចខ្មែរពីដើមបានសាងសង់ដោយចំណាយព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ ។ ភ្នំមួយនេះ អាចហៅបានបីយ៉ាង គឺភ្នំឧដុង្គ ភ្នំព្រះរាជទ្រព្យ ភ្នំអដ្ឋារស ។

ភ្នំឧដុង្គ :

ឧដុង្គ គឺជាឈ្មោះរាជធានីចាស់មួយរបស់កម្ពុជរដ្ឋ ស្ថិតនៅត្រង់ចន្លោះទិសពាយ័ព្យ និងទិសឧត្តរនៃក្រុងភ្នំពេញសព្វថ្ងៃនេះ ។ ដោយភ្នំនេះស្ថិតនៅក្នុងស្រុកឧដុង្គ ទើបគេហៅថា ភ្នំឧដុង្គ ។

ភ្នំព្រះរាជទ្រព្យ :

ហេតុដូចម្តេចបានជាគេហៅថា ភ្នំព្រះរាជទ្រព្យ ? ដោយភ្នំនេះមិនខ្ពស់ពេក ហើយស្ថិតនៅក្បែរព្រះរាជវាំងស្រាប់នោះ ព្រះរាជាសម័យឧដុង្គបានទ្រង់ចាត់ឱ្យសាងចេតិយធំៗជាច្រើនប្រកបដោយក្បាច់ចម្លាក់ឆើតឆាយសំរាប់បញ្ចុះធាតុព្រះមហាក្សត្រ និងព្រះរាជវង្សានុវង្ស ដោយចំណាយព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ ។ រហូតមកដល់សព្វថ្ងៃនេះ ក៏នៅតែមានការស្ថាបនាបន្ថែម និងការថែរក្សាទីកន្លែងនេះយ៉ាងខ្ជាប់ខ្ជួន ដោយសារកម្លាំងព្រះរាជទ្រព្យដែរ ។ អាស្រ័យបុព្វហេតុនេះហើយ ទើបគេហៅភ្នំនេះថា ភ្នំព្រះរាជទ្រព្យ ។

ភ្នំអដ្ឋារស :

នៅលើខ្នងភ្នំផ្អែកខាងត្បូងត្រង់កន្លែងសត្វមកបត់កន្ទុយ មានព្រះវិហារមួយធំស្កឹមស្កៃ ខ្ពស់ត្រដែតលេចចេញពីចុងឈើខ្ពាន់ខ្ពាប់ បែរមុខឆ្ពោះមកទិសខាងជើង ។ នៅខាងក្នុងព្រះ វិហារមានព្រះពុទ្ធរូបមួយព្រះអង្គធំសម្បើមដែលមានកំពស់១៨ហត្ថ ។ អាស្រ័យហេតុនេះ ទើបអ្នកស្រុកនាំគ្នាហៅថា ភ្នំអដ្ឋារស មានន័យ ថា ភ្នំដប់ប្រាំបី គឺសំដៅដល់ព្រះពុទ្ធរូបដែលមាន កំពស់១៨ហត្ថ ។

អក្សរសិល្ប៍ :

រឿងទុំទាវមានតម្លៃរៀងរហូតក្នុងសង្គមខ្មែរ តាំងពីសម័យលង្វែក មកដល់សម័យសព្វថ្ងៃ ដោយមូលហេតុបីយ៉ាងគឺ សរសេរជាពាក្យកាព្យ ពិរោះក្បោះក្បាយ ជូនរណ្តំ អាចទាក់ទាញអ្នកអានឱ្យមានចិត្តរំភើបសប្បាយរីករាយ ជក់ចិត្ត ជិតអារម្មណ៍ បានឆ្លុះបញ្ចាំងឱ្យឃើញជាក់ស្តែងពីជីវភាពរស់នៅ និងទំនៀមទំលាប់ប្រពៃណី របស់ប្រជាពលរដ្ឋខ្មែរនៅសម័យលង្វែក និងការលើកយកបញ្ហាស្នេហារវាងទុំ និងទាវមក ចោទ និងដោះស្រាយតាមរបៀបលោកិយសច្ចៈ ដូចជា តស៊ូ ប្តូរផ្តាច់ ស្មោះត្រង់ មានះយកឈ្នះ ទូវតំនិតនំមិនធំជាងនាឡិ ។

តទៅលេខក្រោយ

សិក្សាកម្មវិធីបង្កើនថាមពល...

ត្រូវបានគេទទួលស្គាល់ថា ជាទីក្រុងដែលសម្បូរទៅដោយអំពើឧក្រិដ្ឋកម្មជាច្រើនជាងគេនៅសហរដ្ឋអាមេរិកនេះ ។ ក្រុមគ្រួសារខ្មែរប្រមាណបីម៉ឺននាក់ ដែលបានមកតាំងទីលំនៅ នៅទីក្រុងនេះ ក៏មានវាសនាដូចអ្នកឯទៀត ដែលភាគច្រើនជាអម្បូរស្បែកខ្មៅនោះដែរ ។ មាតាបិតា និងអ្នកអាណាព្យាបាលកូនចៅមានការលំបាក នឹងអប់រំកូនចៅទៅតាមច្បាប់នៃសហរដ្ឋអាមេរិក ដែលគេការពារកុមារ និងយុវជនយ៉ាងជ្រាលជ្រៅរកទីបំផុតគ្មាន ។ ការលំបាកនោះបាននាំឱ្យមាតាបិតាខ្លះបោះបង់កូនចោលឱ្យនៅផ្ទះអ្នកដទៃ ឱ្យទៅរស់នៅខ្លួនឯង ហើយខ្លះទៀតយល់ថា "ឱ្យវានៅក្នុងគុក" ប្រសើរជាងនៅក្រៅ ។

នៅលើជីវិតអវិជ្ជមានទាំងនេះ មាតាបិតាមួយចំនួនបានខិតខំយល់អំពីប្រព័ន្ធជួយការពារកុមារទាំងឡាយដែលមាននៅហ្វីឡាដែលហ្វីយ៉ានេះ ក៏ប៉ុន្តែប្រព័ន្ធដ៏ច្រើននោះពុំអាចឱ្យខ្លួន អាចយល់បានយ៉ាងងាយនោះទេ ។

នាថ្ងៃ ព្រហស្បតិ៍ កន្លងទៅនេះ នៅសមាគម ព្រឹទ្ធាចារ្យ ផ្លូវលេខ៧ ខាងត្បូង មេគ្រួសារខ្មែរ ១១ នាក់បានបញ្ចប់សិក្ខាសាលាចំនួន៨សប្តាហ៍ ដែលមួយសប្តាហ៍រៀន២ម៉ោង ជាមួយនឹងសមាគមមួយឈ្មោះ MHASP ក្នុងកម្មវិធីបង្កើនថាមពលមាតាបិតា ដើម្បីអប់រំកូនចៅ ដែលមានឈ្មោះកាត់ថា " PEAK " ។

កម្មវិធីនោះ មានសារៈសំខាន់ណាស់ សំរាប់គ្រួសារខ្មែរ ដែលខ្លួនរកចម្លើយមិនដែលបានត្រឹមត្រូវ ដើម្បីដោះស្រាយបញ្ហាស្មុគស្មាញក្នុងគ្រួសារបាន ។

សំនួរដូចជា "បើកូនខ្ញុំមិនទៅរៀន ឬរៀនមិនសូវពូកែ តើត្រូវធ្វើយ៉ាងណា "? ឬថា "កូនខ្ញុំប្រដៅវាមិនស្តាប់ ខ្ញុំវាយប្រដៅវា វាប្តឹងខ្ញុំឱ្យឡើងតុលាការ តើខ្ញុំត្រូវធ្វើយ៉ាងណា" ? ឬក៏ "កូនខ្ញុំចូលរួមកម្លាំងជាមួយពួកក្រុមពាលលក់កញ្ឆា និងគ្រឿងញៀន តើទប់ស្កាត់វាយ៉ាងម៉េច " ? "កូនខ្ញុំ និងខ្លួន ខ្ញុំពុំមានប័ណ្ណការពារជំងឺ HEALTH INSURANCE ទេ តើខ្ញុំត្រូវទៅសុំនៅទីណា" ? ឬក៏ថា "បើអង្គការធនធានមនុស្ស DHS យកកូនចេញពីខ្ញុំទៅ តើត្រូវធ្វើយ៉ាងណា ដើម្បីយកកូនមកវិញ " នៅលើសំនួរ ដែលគ្មានចម្លើយ ហើយដែលបណ្តាលឱ្យសហគមន៍ខ្មែរនៅហ្វីឡាដែលហ្វីយ៉ានេះ ចេះតែអាប់អោនទៅៗ ។

PEAK បាននាំយកកម្មវិធីរបស់ខ្លួនមកធ្វើការណែនាំក្នុងសហគមន៍ខ្មែរ តែជាទូទៅពុំមាននរណាចាប់អារម្មណ៍ខ្លាំងក្លានោះទេ ផ្ទុយពីសហគមន៍ស្បែកខ្មៅ ដែលគេចងក្រងគ្នាជាក្រុមជាពួកជួយគ្នាយ៉ាងសកម្ម ដើម្បីកែរសង្គមរបស់គេ ទោះជាយល់ថាត្រូវប្រើពេលវែងក៏ដោយ ។

លើកនេះ កម្មសិក្សាការីខ្មែរបានសំដែងការសប្បាយចិត្ត ហើយសុំឱ្យកម្មវិធីដដែលនេះ ត្រឡប់មកវិញឱ្យបានឆាប់ ដើម្បីជាជំនួយដល់ពួកគាត់ ។ លោកស្រី ដៃក៏ Ms Dykes ដែលជាអ្នកដឹកនាំកម្មវិធីបានថ្លែងថា "កម្មវិធីបន្ទាប់នឹងប្រព្រឹត្តទៅនៅសាលា E_3 CENTER លេខ 5201 OLD YORK Road. Philadelphia. PA 19120 ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០៨ ហើយគាត់បន្ថែមថា PEAK អាចនឹងត្រឡប់មកវិញនៅឆ្នាំក្រោយ ប្រសិនបើអ្នកទាំងអស់សន្យាថា មនុស្សម្នាក់ត្រូវនាំអ្នកថ្មី មកម្នាក់ទៀត ដើម្បីឱ្យអ្នកឯទៀតបានទទួលព័ត៌មានដ៏សំខាន់នេះ ដូចគាត់ផង ៕

សូមអញ្ជើញមកចូលរួម ទស្សនាខ្សែរភាពយន្តរបស់នាង សុជាតា

រឿង "ទារកនាកើត ក្នុងឱកាសចូលឆ្នាំថ្មី " ដែល នឹងបង្ហាញជូនជាមួយនិង កម្មវិធី:

PEAK
Being Your Childs Best Advocate

បង្កើនថាមពល មាតាបិតា ដើម្បីណែនាំ តាមរយៈចំណេះដឹង សិក្ខាសាលាដោយឥត យកថ្លៃ ចំនួន ៨សប្តាហ៍ សំរាប់ មាតាបិតា/អនាព្យាបាល ដែលចង់សិក្សា ពីវិធី ណែនាំកូនចៅ អោយបានប្រសើរបំផុត ដោយប្រើប្រពន្ធ័បំរើ កុមារ និង យុវជននៅហ្វីឡាដែលហ្វីហ្យ

- អ្នកចូលរួម លោកអ្នក នឹងបានរៀនអំពីប្រធានបទ ដូចតទៅ៖
- ប្រពន្ធ័ព្យាបាលសសៃបសាទ
- ប្រពន្ធ័របស់គ្រឿងញៀន និង សុរា
- ប្រពន្ធ័សិក្សាធិការ ពិសេស
- ប្រពន្ធ័តុលាការ កុមារ
- ប្រពន្ធ័កុមារភាព និង យុវជន

តើអ្នកត្រូវដឹងអ្វីខ្លះ សំរាប់ការណែនាំ អោយមានប្រសិទ្ធិភាព?

ផ្តើមនៅ : *ថ្ងៃព្រហស្បតិ៍ ទី០៤ ខែកញ្ញា ឆ្នាំ ២០០៨*
ទីកន្លែង : *នៅ នៅ មជ្ឈមណ្ឌល E-3 អាសយដ្ឋានលេខ ៥២០១ ផ្លូវ* Old York Road
ហ្វីឡាដែលហ្វីហ្យ PA *១៩១៤១*
ពេលវេលា : *ពីម៉ោង ៦ ដល់ ម៉ោង ៨ ល្ងាច*
តំលៃ: *សិក្ខាសាលា ដោយមិនយកកំរៃ និងមាន ជួយចេញថ្លៃអោយគេមើលកូន និងជួយចេញថ្លៃធ្វើដំណើរ ផង*

មានប្រាក់រង្វាន់ ៥០ដុល្លា សំរាប់ផ្តល់អោយសិស្ស ដែលមករៀនទៀងទាត់

MENTAL HEALTH ASSOCIATION OF SOUTHEASTERN PENNSYLVANIA

សូមទាក់ទងទៅលោក ពិន សំអុន ហៅ Roger Pin និង
MARY TILLERY ឬ MARY TILLE, Family Advocate
តាមរយៈ ទូរស័ព្ទលេខ ២៦៧-៧៥១-១៨០០ រួចចុចលេខ
២៨៦១ ៥៥៨១ ២៨៦

ឬអាចទាក់ទងទៅ មជ្ឈមណ្ឌល E-3
តាមរយៈ ទូរស័ព្ទលេខ ២១៥-៣៣៩-០២៨០

ក្រុមគ្រូបង្រៀនសហរដ្ឋអាមេរិក...

ភាសាអង់គ្លេសដល់គ្រូ និងសិស្សនៅតាមមូលដ្ឋាននៅខេត្តសៀមរាប បាត់ដំបង ក្រុងភ្នំពេញ ។

លោក Alex Morales Director, School Improvement Initiative បានឱ្យដឹងថា ពួកយើងមកស្រុកខ្មែរពេលនេះរយៈពេល២សប្តាហ៍ដោយពាំនាំមកនូវសំភារៈ សំលៀកបំពាក់ អង្ករ ត្រីសាច់ សំរាប់ចែកជូនជនក្រីក្រ ។ ជាពិសេសយើងនឹងទៅពិនិត្យមើលពីស្ថានភាព រស់នៅរបស់កុមារី ដារិក នៅស្រុកកំណើតក្នុងភូមិ ស្វាយជ្រំ ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង និងខេត្តកំពង់ស្ពឺ ។

លោក Alex Morales បន្តថា គោលបំណងសំខាន់របស់យើងដែលមកកម្ពុជានៅពេលនេះ គឺទៅធ្វើការសំណេះសំណាលជួយកុមារក្រីក្រតាមមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីសិក្សាស្វែងយល់ពីតំរូវការ ព្រមទាំងភាពចាំបាច់នៅចំពោះមុខ ។ ក្នុងពេលនេះយើងនឹងធ្វើការពង្រឹងចំណេះដឹងផ្នែកភាសាអង់គ្លេសដល់សិស្សានុសិស្ស និងគ្រូៗនៅតាមសហគមន៍មួយចំនួនផងដែរ ។

ជាមួយគ្នានេះដែរ លោកសាស្ត្រាចារ្យ អ៊ឹង ដារិទ្ធ មកពីមហាវិទ្យាល័យទីក្រុងឡុងប៊ិច បានឱ្យដឹងថា ក្នុងដំណើរចុះជួយជនក្រីក្រតាមសហគមន៍ យើងមានជួបការលំបាកមួយចំនួន ដោយសារមេភូមិមួយចំនួនមិនឱ្យចូលទៅជួបអ្នកស្រុក និងក្មេងៗ ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី នៅតាមតំបន់មួយចំនួនយើងបានចុះទៅជួបជនក្រីក្រ និងចែកអំណោយ តាមគំរោងរបស់យើងតាមបែបមនុស្សធម៌ ។

លោក អ៊ឹង ដារិទ្ធ បន្តថា នៅពេលដែលយើងមកដល់ភូមិស្វាយជ្រំ ឃុំរលំជ្រៃនេះ យើងមានអារម្មណ៍ក្តុកក្តួលស្រងូតស្រងាត់ខ្លាំងណាស់ ពីព្រោះឃើញផ្ទះអ្នកស្រុកតូចៗ និងជីវភាពខ្វះខាត ហើយពិសេសនោះ គឺគ្រួសារកុមារីបេះដូងប្រហោងដែលរស់នៅក្នុងខ្ទមរយីករយាក ។

លោកបានបញ្ជាក់ថា ពេលក្រុមរបស់លោកត្រឡប់ទៅអាមេរិកវិញ នឹងធ្វើការអំពាវនាវដល់សប្បុរសជន និងអង្គការនានា ដើម្បីមកជួយរួមចំណែកអភិវឌ្ឍន៍ប្រទេសកម្ពុជាតាមតែអាចធ្វើទៅបាន ។

សំរាប់អ្នកស្រុកទាំងក្មេងចាស់ ដែលរស់នៅក្នុងភូមិស្វាយជ្រំនោះ ម្នាក់ៗបានសំដែងនូវទឹកចិត្តសប្បាយរីករាយយ៉ាងខ្លាំងចំពោះក្រុមអង្គការបេះដូងគ្មានព្រំដែន ដែលបានជួយសង្គ្រោះជីវិតកុមារី ដារិក និងពាំនាំអំណោយមកចែកជូនដល់ពួកគាត់ថែមទៀត ។

លោក បូម សំបូរ អាយុ៥៥ឆ្នាំ តំណាងឱ្យអ្នកស្រុករស់នៅតំបន់នោះបានសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះសប្បុរសជន ដែលពាំនាំមកនូវអំណោយ និងទឹកចិត្តដ៏ថ្លៃថ្លា របស់បងប្អូនខ្មែរ និងជនអាមេរិកចំពោះពួកគាត់ ។

លោក បូម សំបូរ បញ្ជាក់ថា ទោះបីជាអំណោយនេះតិចតួចស្តួចស្តើងមិនអាចទ្រទ្រង់ជីវភាពរស់នៅរបស់លោកបានក្តី តែវាជាទឹកចិត្តដ៏ជ្រាលជ្រៅ និងស្មោះសបំផុត ដែលក្រុមគ្រូបង្រៀន និងអង្គការបេះដូងគ្មានព្រំដែនបានជួយដល់អ្នកស្រុកភូមិគាត់ឱ្យរស់រានមានជីវិត និងក្តីសង្ឃឹមឡើងវិញ ។

ចំណែកលោក Alex Morales នៅពេលដែលធ្វើដំណើរទៅដល់ភូមិរបស់កុមារី ដារិក គាត់ ហាក់ដូចជាមានអារម្មណ៍ស្រងូតស្រងាត់ក្នុងចិត្តខ្លាំងណាស់ បន្ទាប់ពីបានឃើញនូវទិដ្ឋភាពក្រៀមក្រំរបស់អ្នកស្រុក ។ ប៉ុន្តែយើងខ្ញុំនឹងធ្វើការលើកទឹកចិត្តដល់ពួកគាត់ឱ្យមានក្តីសង្ឃឹមនៅពេលក្រោយ ហើយលោកមិនត្រឹមតែផ្តល់ជាអំណោយបន្តិចបន្តួចទុកជាអនុស្សាវរីយ៍នោះទេ គឺមានគំរោងជួយកសាងសាលារៀន សំរាប់កូនចៅអ្នកស្រុកនៅទីនេះថែមទៀត ។

លោក Alex Morales បញ្ជាក់ថា យើងមានគំរោងជួយកសាងសាលារៀននៅតាមបឋមសិក្សា និងអនុវិទ្យាល័យ ។ ជាពិសេសចង់បង្កើតសាលារៀនថ្មី ដើម្បីបង្រៀនភាសាអង់គ្លេស ដើម្បីឱ្យកូនចៅអ្នកស្រុកអាចរកការងារបានធ្វើនៅ ខេត្តសៀមរាប ក៏ដូចជាយកចំណេះដឹងទៅប្រកបរបរចិញ្ចឹមជីវិតបានដោយងាយស្រួល ៕

AUTOGRAPH
Audio Visual Vehicle Design Specialist
Wimean Hing

Cell: (215) 892-4122

ហាងកូនខ្មែរសំរាប់ដាក់
"អូតូឡាឌីយូ " ដាក់ "
ការពារកុំឱ្យចោរលួចដាក់
ម៉ាស៊ីនសំរាប់ជួយរកផ្លូវ
នឹងគ្រឿងអេឡិចត្រូនិច
ច្រើនទៀត"

- -Audio
- -Video and Navigation Systems
- -Wheels and Tires
- -Satellite Radio
- -GPS Tracking
- -Alarm and Remote Start
- -Custom Fiberglass Enclosures and Accessories

"អូតូក្រាហ្វ" ជាហាងរបស់កូនខ្មែរ
ដែលមានបទពិសោធន៍ខ្ពស់ ក្នុង
ការដាក់សម្ភារៈបន្ថែម ឬ អេឡិច
ត្រូនិចបំរើលោក-អ្នកមិនឱ្យខុស
ចិត្តឡើយ ។
បើចង់បានព័ត៌មានបន្ថែម
សូមរកវិមាន ហ៊ីង

7114 State Road
Philadelphia, Pa 19135

Phone : (215) 333-3723
Fax : (215) 333-3715

vimeanhing@autogrpahcar.com, www.autographcar.com

លោក កឹម សុខា លាសម្បថ ជំនួសអ្នកទទួលអំណោយ

ភ្នំពេញ ,ខ្មែរប៉ុស្តិ៍ : ចាន់ កុសល

●●●មាត់ចាបមាត់ព្រាប និងរាត្រីឆ្អែតព្រុស តែងមានជាហូរហែដែលគណបក្សប្រឆាំង ចោទគណបក្សប្រជាជនកម្ពុជាថា បានយកលុយ កាក់ សារុង ប៊ីចេង ជាថ្នូរនឹងការឱ្យពួកអ្នកស្រុក បោះឆ្នោតឱ្យខ្លួន ហើយថែមទាំងឱ្យស្បថស្បែរ យ៉ាងធ្ងន់ធ្ងរទៀតផង ។

ពិធីបង្ហោះប៉េងប៉ោង លាមាត់.ក ជំនួសអ្នកទទួលអំណោយ

ការគំរាមកំហែងផ្នែកស្មារតីនេះ បានលេចឮស្ទើរគ្រប់តំបន់ចំពោះអ្នកស្រុកគ្រប់ខេត្ត-ក្រុង ដែលធ្វើឱ្យពួកគាត់ពិបាកនឹងធ្វើការសំរេចចិត្តជ្រើសរើសបក្សថ្មី ពីព្រោះខ្លាចខុសពាក្យសម្បថ នាំឱ្យអន្តរាយអាយុជីវិត និងក្រុមគ្រួសារ ។

ដោយមើលឃើញទឹកចិត្តរារែករបស់អ្នកស្រុកបែបនេះហើយ កាលពីថ្ងៃទី២២ ខែកក្កដា លោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្ស បានរៀបចំពិធីលាមាត់លា.កជំនួសប្រជាពលរដ្ឋទូទាំងប្រទេស ដែលទទួលអំណាចទាំងប៉ុន្មានឱ្យមានសេរីភាពឡើងវិញ ហើយអស់ក្តីមន្ទិលសង្ស័យថា មានបាបកម្ម ឬខ្លាចខុសពាក្យសម្បថរបស់ខ្លួនពេលសំរេចចិត្តបោះឆ្នោតឱ្យគណបក្សផ្សេងៗ ។

ខ្មែរយើងមានជំនឿយ៉ាងខ្លាំងចំពោះបារមីវត្ថុស័ក្តិសិទ្ធិ ប្រកាន់ភ្ជាប់នូវពាក្យសម្បថ ពាក្យសច្ចៈដែលខ្លួនបានសន្យាតាំងពីដើមបុរាណរហូតដល់បច្ចុប្បន្ន ហើយជំនឿទាំងនេះបាននឹងកំពុងមានឥទ្ធិពលក្នុងជីវភាពរស់នៅរបស់អ្នកស្រុកថែមទៀតផង ។

ពាក្យសម្បថទាំងនេះវាមានតំលៃតែចំពោះបុគ្គលដែលមានបារមី មានសីលធម៌ប៉ុណ្ណោះ ប៉ុន្តែចំពោះជនលោភអំណាចធ្វើបាបរាស្ត្រនោះ វាគ្មានន័យអ្វីទេ ពីព្រោះបារមីមិនសណ្ឋិតចំពោះជនអសីលធម៌ឡើយ ។

ថ្លែងក្នុងពិធីលាសម្បថនោះ លោក ម៉ៅ វាសនា តំណាងឱ្យយុវជនសិទ្ធិមនុស្ស បានឱ្យដឹងថា អ្នកតំណាងរាស្ត្រ សមាជិករដ្ឋាភិបាល បន្ទាប់ពីជាប់ឆ្នោតហើយ ត្រូវស្បថស្បែរនៅចំពោះមុខវត្ថុស័ក្តិសិទ្ធិ និងព្រះមហាក្សត្រ ។ ពាក្យសម្បថទាំងនេះទោះបីជាគ្មានរូបរាងក្តីតែខ្មែរយើងនៅតែជឿដក់ជាប់ក្នុងក្រអៅបេះដូងជានិច្ច ហើយបានបង្កើតជាពាក្យស្លោកថា "មនុស្សយកសំដី ដំរីយកភ្លុក ឬ រនាបបាក់យករនាបជួស សំដីហួសគ្មានអ្វីជួសទេ" ។

លោក ម៉ៅ វាសនា បន្តថា សព្វថ្ងៃនេះ គណបក្សនយោបាយខ្លះបានឆ្លៀតឱកាសនោះ ឱ្យអ្នកស្រុកស្បថពេលផ្តល់អំណោយម្តងៗ ហើយសម្បថនេះបានធ្វើឱ្យពួកគាត់កាន់តែភ័យ ខ្លាចអត់ហ៊ានងាករេទៅបោះឆ្នោតឱ្យគណបក្សផ្សេងៗ នេះគឺជាការគាបសង្កត់ផ្នែកស្មារតីធ្ងន់ធ្ងរខ្លាំងណាស់ ។

លោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្ស ជំនួសមុខឱ្យប្រជាពលរដ្ឋដែលទទួលអំណោយទាំងអស់បានបញ្ជាក់ថា ការស្បថស្បែណាដែលកើតចេញពីការបង្ខិតបង្ខំ យើងក៏អាចធ្វើពិធីលាមាត់លា.កបានដែរ ហើយសម្បថនោះ ពុំមានឥទ្ធិពលអ្វីនោះទេ ។

លោក កឹម សុខា បញ្ជាក់ថា នៅថ្ងៃទី២៦ ខែកក្កដា គណបក្សមួយចំនួនដែលចែកអំណោយឱ្យបងប្អូន និងបង្ខំឱ្យប្រជាពលរដ្ឋស្បថចុងក្រោយទៀត ។ ដូច្នេះពិធីក្នុងថ្ងៃនោះ គឺជាការជំនួសឱ្យអ្វីដែលបានធ្វើកន្លងមកផង និងថ្ងៃខាងមុខផង ដែលជនខិលខូច និងគណបក្សខិលខូច បានបង្ខំឱ្យស្បថ និងរលាយរលត់ចាប់តាំងពីពេលនេះតទៅ ។

លោកប្រធានគណបក្សសិទ្ធិមនុស្ស ក៏បានអំពាវនាវដល់អ្នកមិនជាប់ពាក្យសម្បថ និងអ្នកជាប់ទាំងអស់ សូមមេត្តាបោះឆ្នោតតាមឆន្ទៈពិតប្រាកដរបស់ខ្លួន កុំឱ្យមានការភ័យខ្លាចឡើយ ពីព្រោះការបោះឆ្នោតជារឿងសំងាត់ គ្មាននរណាដឹងទេ ។

ទាក់ទងទៅនឹងការស្បថស្បែនេះ ប្រជាពលរដ្ឋនៅតាមស្រុកស្រែមួយចំនួនធំ បាននិយាយប្រហាក់ប្រហែលគ្នាថា ពួកគាត់ទទួលអំណោយទាំងទើសទាល់ ហើយត្រូវគណបក្សកាន់អំណាចបង្ខំឱ្យស្បថ ។ បើពួកគាត់មិនទទួលអំណោយខ្លាចគេកត់ចំណាំ និងពិបាកបញ្ជាក់លិខិតស្នាមនៅថ្ងៃក្រោយ ហើយគេចោទថា ចូលដៃជើងជាមួយគណបក្សប្រឆាំង ។

ការរៀបចំពិធីលាមាត់លា.កនេះ ត្រូវបានមនុស្សជាច្រើនស្វាគមន៍ហើយចាត់ទុកជាការលើកទឹកចិត្តរំដោះស្មារតីអ្នកបោះឆ្នោតឱ្យមានសិទ្ធិសេរីភាព ហ៊ានសំរេចបោះឆ្នោតឱ្យគណបក្សដែលខ្លួនស្រឡាញ់ ។

លោក គល់ បញ្ញា នាយកប្រតិបត្តិខុមហ្វ្រែល បានឱ្យដឹងថា ការរៀបចំពិធីលាមាត់លា.កនេះ ជាប្រពៃណីមួយល្អសំរាប់ពលរដ្ឋ និងជាគ្រឿងលើកទឹកចិត្តពួកគាត់ឱ្យមានសេចក្តីក្លាហាន មានសេរីភាពផ្នែកអារម្មណ៍ ។ ចំណុចដែលសំខាន់នោះ ពួកគាត់ត្រូវយល់ពីតំលៃ និងសារៈសំខាន់នៃសន្លឹកឆ្នោត ហើយក្លាយជាពលរដ្ឋឈ្លាសវៃ ចេះយល់ពីហេតុការណ៍អាចទប់ទល់នឹងមជ្ឈដ្ឋានខាងក្រៅបាន ៕

ពន្លកលទ្ធិប្រជាធិបតេយ្យគណបក្សសិទ្ធិមនុស្ស អាចដណ្តើមបានជ័យជំនះដែរឬទេ ?

ភ្នំពេញ ,ខ្មែរប៉ុស្តិ៍ : គីម សារឿន

លោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្ស

●●●គណបក្សរាជានិយម និងគណបក្សប្រជាធិបតេយ្យ ដែលកើតនៅស្រុកខ្មែរជាច្រើនអាណត្តិមកហើយ ប៉ុន្តែនៅតែមិនអាចដណ្តើមបានជោគជ័យទាំងស្រុងពីគណបក្សកាន់អំណាចទៀត ។ ផ្ទុយទៅវិញ គណបក្សទាំងនេះប្រេះស្រាំ និងឈ្លោះប្រកែកគ្នាមិនចេះចប់ ហើយត្រូវគណបក្សប្រជាជនកម្ពុជាធ្វើការអូសទាញស្ទើរអស់ តាមរយៈតួនាទីអំណាចបុណ្យស័ក្តិ ។

សកម្មភាពរបស់គណបក្សសិទ្ធិមនុស្ស

ក្នុងពេលជាមួយគ្នានេះដែរ ក៏លេចចេញគណបក្សសិទ្ធិមនុស្សមួយដែលមានអាយុក្មេងខ្ចីជាងគេ ប៉ុន្តែទទួលបានការគាំទ្រពីសំណាក់ប្រជាពលរដ្ឋយ៉ាងច្រើន ហើយមេដឹកនាំគណបក្សនេះសង្ឃឹមថា នឹងដណ្តើមបានជោគជ័យនៅពេលបោះឆ្នោតថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ។ ខាងក្រោមនេះ គឺជាបទសម្ភាសន៍លោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្សដែលមានខ្លឹមសារដូចខាងក្រោម ។

✦ **អ្នកនយោបាយមួយចំនួនបានចោទគណបក្សសិទ្ធិមនុស្សថា ជាគណបក្សអាយ៉ងរបស់គណបក្សប្រជាជនកម្ពុជា ចំពោះលោកវិញយល់យ៉ាងណាដែរ ?** (តទៅទំព័រទី២០)

Get Connect...Stay inform.

....Subscribe to the Khmer Post!

Please send me 1 year subscription of the Khmer Post newspaper 24 issues for $60.00

Name:_________________________
Address: _________________________

Payment method:
Money order Check Bill me

Please send your payment to US-Asia Media Group.
5730 Rising Sun Ave. Philadelphia, Pa 19120

ឡៅ ម៉ុងហៃ : សម្ដេចនរោត្ដម សីហនុ អាចបញ្ចប់ទំនាស់វិវាទព្រំដែនប្រាសាទ...

អតីតព្រះមហាក្សត្រនរោត្តម សីហនុ

កិច្ចព្រមព្រៀងទីក្រុងប៉ារីស ប្រទេសហត្ថលេខីទាំងអស់ត្រូវតែចូលរួម ដើម្បីឱ្យគេទទួលស្គាល់ពីបូរណភាព អធិបតីភាព និងឯករាជ្យភាពប្រទេសកម្ពុជា ។

ការធ្វើបែបនេះ ក្នុងបំណងបង្ហាញពីអំណាចរបស់ខ្មែរ ដើម្បីឱ្យបរទេសចាប់អារម្មណ៍ ហើយរឿងនេះបានទៅដល់អង្គការសហប្រជាជាតិហើយ ។ រឿងសំខាន់ គឺសៀមរំលោភបូរណភាពធិបតេយ្យ ឯករាជកម្ពុជា ។

តើមានមាត្រាត្រង់ណា ដែលបង្ហាញពីសន្ធិសីទនៅទីក្រុងបារីស ដើម្បីឱ្យមានសន្តិភាពនោះ ?

កិច្ចព្រមព្រៀងនោះ មាន២ គឺការចរចាបញ្ចប់សង្គ្រាមរវាងកងទ័ពយួន ខ្មែរក្រហម និងបង្កើតរដ្ឋាភិបាលថ្មី ដើម្បីដឹកនាំប្រទេស ដែលមានអង្គការសហប្រជាជាតិ ជាអ្នករៀបចំដោះស្រាយតាមរយៈការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រតាក់តែងរដ្ឋធម្មនុញ្ញ សំរាប់គ្រប់គ្រងប្រទេសជាតិ ។ **ទី២ :** កិច្ចព្រមព្រៀងលើអធិបតេយ្យភាព បូរណភាពទឹកដីខ្មែរទៅអនាគត អត់ចូលបក្សសម្ព័ន្ធណាទេ នៅឯករាជ្យ អព្យាក្រឹត រហូតការគោរពសិទ្ធមនុស្ស ដែលស្ថិតនៅក្រោមការឃ្លាំមើលរបស់អង្គការសហប្រជាជាតិ ការពារអធិតេយ្យភាព ហើយបើសិនជាមានការរំលោភត្រូវតែមានដំណោះស្រាយអហិង្សា គឺឆ្ពោះទៅអង្គការសហប្រជាជាតិ ។

ក្នុងកិច្ចព្រមព្រៀងនេះ មានតែប្រទេសបារាំងនិងឥណ្ឌូនេស៊ីទេ ដែលជាសហប្រធានបានដាក់ស្នើប្រទេសកម្ពុជា នៅទីក្រុងប៉ារីស នៅឆ្នាំ១៩៨៩ ហើយដំណើរការនោះ ក៏បានឈានដល់កិច្ចព្រមព្រៀមនៅឆ្នាំ១៩៩១ ។

ដូច្នេះ ការបញ្ចូលទ័ពរបស់សៀម មកលើទឹកដីខ្មែរ ពេលនេះ គឺជាការឈ្លានពានទឹកដី រំលោភបូរណភាព ខ្មែរមានសិទ្ធិប្រើប្រាស់កិច្ចព្រមព្រៀងនេះបាន ដោយតវ៉ាទៅប្រទេសហត្ថលេខីទាំងអស់ឡើងវិញ ឱ្យសៀមដកទ័ពថយ គោរពបូរណភាពទឹកដីខ្មែរជាដាច់ខាត ។ បើពុំដូច្នេះទេ យើងត្រូវទៅពឹងអង្គការអន្តរជាតិ ឬតុលាការ អន្តរជាតិក្រុងឡាអេ ប្រទេសហុល្លង់ ពេលនោះ យើងមានឯកសារភស្តុតាងត្រឹមត្រូវ បង្ហាញគេ ទៅក៏ធ្វើឱ្យសៀមខ្មាសគេអាប់អោនកេរ្តិ៍ឈ្មោះផងដែរ ។ ពេលគេដឹងរឿងនេះ ច្បាស់ជាពិភពលោកអាចនឹងធ្វើការដាក់ទណ្ឌកម្មផ្សេងៗដល់សៀម ។

តើលោកបណ្ឌិត យល់ឃើញយ៉ាងណាចំពោះអតីតព្រះមហាក្សត្រនរោត្តម សីហនុ ចំពោះតួនាទីកន្លងមករបស់ព្រះអង្គ ក្នុងករណីប្រាសាទព្រះវិហារនេះ ?

-ក្នុងប្រទេសកម្ពុជា តាមលោកសង្កេតមិនទាន់មានបុគ្គលណាមួយមានសមត្ថភាពអាចដោះស្រាយជំលោះព្រំដែន ក្រៅពីសម្តេចឪ មហាវីរក្សត្រនរោត្តម សីហនុ ពីព្រោះព្រះអង្គ ត្រូវបានអន្តរជាតិទទួលស្គាល់ គោរពកោតពីភាពឈ្លាសវៃរបស់ព្រះអង្គ ។

កន្លងមកព្រះអង្គបានលះបង់ព្រះកាយពលការពារបូរណភាពទឹកដី ទាមទារឯករាជ្យពីបារាំង ហើយប្រាសាទព្រះវិហារនេះ គឺជាស្នាព្រះហស្តអតីតព្រះមហាក្សត្រ ឃើញច្បាស់លាស់ ។ ចំណែកទឹកដីនៅតាមព្រំប្រទល់គ្រប់ទិស មិនមានការបាត់បង់នោះទេ ហើយធ្វើឱ្យប្រជាពលរដ្ឋគាំទ្រយ៉ាងខ្លាំង ។

លុះសម័យក្រោយមក ទឹកដីរបស់ខ្មែរ បានបាត់បង់ជាបន្តបន្ទាប់ ហើយនៅពេលបច្ចុប្បន្នទឹកដីក៏បន្តបាត់បង់ទៀត ។ ដូច្នេះ តាមទស្សនៈរបស់ខ្ញុំ រដ្ឋាភិបាលគួរតែផ្តល់ភារកិច្ចនេះ ឱ្យសម្តេចឪ ធ្វើការដោះស្រាយជំលោះព្រំដែនប្រកបដោយប្រសិទ្ធភាព ។ ជាពិសេសរដ្ឋាភិបាលត្រូវឱ្យសម្តេចឪ ដឹកនាំទាមទារបូរណភាពទឹកដីដែលបានបាត់បង់ជូនជាតិមាតុភូមិមកវិញ ពីព្រោះព្រះអង្គធ្លាប់ដណ្តើមបានជោគជ័យយ៉ាងត្រចះត្រចង់ជាច្រើន ។

រដ្ឋាភិបាលអាចស្នើទៅព្រះមហាក្សត្រឱ្យតែងតាំងអតីតមហាក្សត្រដឹកនាំគណៈប្រតិភូដឹកនាំកិច្ចការនេះ ហើយយើងសង្ឃឹមថា នឹងទទួលបានជ័យជំនះទៀត ។ ដោយសារព្រះអង្គមិនត្រឹមតែមានប្រាជ្ញាឈ្លាសវៃប៉ុណ្ណោះទេ គឺព្រះអង្គមានបទពិសោធន៍ច្រើនណាស់ក្នុងព្រះរាជកិច្ចដឹកនាំជាតិ ការពារបូរណភាពទឹកដី ។

ក្នុងកាលៈទេសៈនេះទាំងអ្នកគាំទ្រព្រះអង្គនិងអ្នកមិនគាំទ្រសូមមូលមតិគ្នាគាំទ្រព្រះអង្គក្នុងព្រះរាជបេសកកម្មនេះឱ្យពេញទំហឹង ដើម្បីបុព្វហេតុជាតិមាតុភូមិរបស់យើងទាំងអស់គ្នា ។

មានការលើកឡើងថា បើមានការផ្ទុះអាវុធខ្មែរយើងមិនអាចឈ្នះបានទេ ហើយចង់ឈ្នះមានតែពឹងយួនម្តងទៀត តើការលើកឡើងនេះលោកយល់យ៉ាងណាដែរ ?

ការលើកឡើងនេះ បើពីសម័យមុនអាចត្រូវតែក្នុងសម័យនេះមិនត្រូវទេ គឺយើងមិនត្រូវយកកំហឹងទៅទល់នឹងកំហល់នោះទេ គឺយើងត្រូវមានឯកសារភស្តុតាងពីសកម្មភាពឈ្លានពានរបស់សៀមឱ្យឃើញច្បាស់ ។ ជាពិសេសយើងត្រូវគិតថា យើងជាអ្នករងគ្រោះពីអំពើឈ្លានពាន ហើយទស្សនៈខ្មែរជាអ្នកចំបាំង គួរតែបោះចោល វាគ្មានប្រយោជន៍អ្វីទេ មិនត្រូវក្អេងក្អាងខ្លាំងពេក វាមិនល្អទេ ។ សំរាប់ការជួយគាំទ្រផ្លូវចិត្ត ទ្រព្យសម្បត្តិពីមហាជនជារឿងល្អ រឿងនេះត្រូវគិតគូរឱ្យបានល្អិតល្អន់ទើបប្រសើរ ។

អ្វីដែលសំខាន់មានតែប្តឹងទៅអង្គការសហប្រជាជាតិជួយអន្តរាគមន៍តាមផ្លូវច្បាប់ ផ្លូវទូតដើម្បីទាមទារទឹកដីយើងមកវិញ ដូចសម័យបារាំងអឺចិង ។ ចំពោះការទៅពឹងពាក់កងទ័ពបរទេសវាមិនមែនជារឿងល្អសំរាប់កម្ពុជាយើងនោះទេ កាលណាគេមក គេប្រាកដជាទាមទារចំណេញហើយ ។

តាមប្រវត្តិសាស្ត្របានបញ្ជាក់ស្រាប់ហើយ កាលណាយើងពឹង គេប្រាកដជាខាតហើយ ដូចអ្នកតស៊ូខាងលិចត្រូវគេរំកិល ខាងកើតគេរំកិលនោះ ដោយសារតែយើងទៅពឹងគេ ។ ដូច្នេះមធ្យោបាយល្អ គឺការប្រើប្រាស់ការទូត ផ្លូវច្បាប់ និងពឹងពាក់អង្គការសហប្រជាជាតិ ទាមទារទឹកដីយើងមកវិញ ៕

FreeLife
The Himalayan Goji Company®

the World´s Most Powerful Anti-Aging Food

ចំណីដែលទប់ទល់ជរាភាពដ៏ខ្លាំងជាងគេក្នុងលោក
គឺទឹកផ្លែឈើ "គោជី " នៃព្រៃហេមពាន្ត

HIMALYAN GOJI
Juice

ការសម្ងាត់នៃសុខភាពល្អរបស់ពួកអាស៊ីបានត្រូវរកឃើញ នារជ្ជកាលស្តេចតាំងឆ្នាំ ៨00 គ.ស ពលរដ្ឋនៃតំបន់មួយនៅព្រៃហេមពាន្តមិនព្រមចាស់-សក់ក៏មិនស-ធ្មេញក៏មិនបាក់-គេថា អ្នកស្រុកបានផឹកទឹកអណ្តូងមួយដែលមានដើម "គោជី "ដុះជុំវិញ គេស្មានថា មានវត្ថុសក្តិសិទ្ធអ្វីមួយជួយថែរក្សាពួកគេ ។ ទើបតឡូវនេះ គេដឹកថា "គោជី " មានជីវជាតិពិសេសមួយឈ្មោះ POLYSACHARIDES ដែលពុំមាននៅផ្លែឈើឯណាទៀតសោះ ដែលជួយដល់ប្រព័ន្ធការពារខ្លួនរបស់មនុស្សបាន ។

បើចង់បាន Goji មកពិសារសូមជាវតាម www.forever.freelife.com
ឬក៏ទូរស័ព្ទលេខ : (267) 253-3947

SHARE THE SECRET

TIME Magazine wrote :

“ this year´s breakout (Superfruit) was the Himalyan Goji Berry, said to be a source of energy and longevity ”. To order, please visit the website at : www.forever.freelife.com

Or please call (267) 253-3947 to order

គ្រោះថ្នាក់នៃរបបលទ្ធិប្រជាធិបតេយ្យ...

ច្រើនជាង "ស្រឡាញ់ ដោយព្រមព្រៀង" នោះដោយយោងទៅតាមគម្លាតនៃ"អ្នកមាន" ភាគស្តួចស្តើង និង"អ្នកក្រ" ភាគ "ធោម១" នៅដាច់ពីគ្នាឆ្ងាយពេក ដោយយោងទៅតាមចំណេះវិជ្ជានៅជនបទមានកំរិតទាបខ្លាំងពេក ជាពិសេសភាពតំរាមកំហែង និងភាពអាថិកំបាំងនៃអ្នកគ្រប់គ្រងមានទំហំខ្ពស់ហួសហេតុ ។ល។ ជោគជ័យលើសពី២ភាគ៣នៃអាសនៈ របស់សភាបក្សប្រជាជនកម្ពុជា នាពេលនេះខ្មែរយើងក៏ធ្លាប់ភ្លក់រសជាតិតាំងតែពី "សង្គមរាស្ត្រនិយម" ត្រូវបានបញ្ឈរឡើង ដោយសម្តេចនរោត្តមសីហនុ ពីមុនមកដែរ ។ នាអំឡុងពេលនោះភាពផ្តាច់ការនិយមរបស់សម្តេចឪ នរោត្តមសីហនុ ត្រូវបានគេមើលឃើញថា ជាប្រជាធីបតេយ្យឯកបក្សក្តាប់អំណាចបក្ស រហូតដល់រលំដួលគ្រេងខ្មែរងើបលែងរួចតែម្តង មានអំណាចលើសភាជាតិលើរដ្ឋាភិបាល និងតុលាការគ្រប់ជាន់ថ្នាក់ ។

តាំងតែឆ្នាំ១៩៩៣មក គេតែងមិនជឿថា អំណាច ២ភាគ៣ នឹងមិនកើតឡើងបានម្តងទៀតទេ ដោយភ្អែកនៅលើលោកសេរីមានកម្លាំងមហិមា តាមការពារប្រទេសតូចច្រម៉ក់មួយនេះ ឱ្យនៅក្រោមក្បៀកនៃសេរីភាពជារហូតតទៅ ។ តែប្រជាជាតិបានជឿទៅលើសម្តេចសីហនុម្តងរទៀត នាឆ្នាំ ១៩៩១ ថា ជាជើងឯកនៃប្រជាធិបតេយ្យមុខតែនឹងទប់ស្កាត់ដំណើរនៃគណបក្សប្រជាជនកម្ពុជាបាន ម្លោះហើយគ្រប់គណបក្ស ដែលសង្ស័យថា មានមាយាទ នាំគ្នាទៅឈរក្រោមម្លប់នៃ "ល្អងធូលីព្រះបាទ" គ្មានសល់ ។

ប្រវត្តិសាស្ត្រកម្ពុជា បានរំលឹកឡើងជាថ្មីម្តងទៀត នៅពេលដែលគណបក្សហ៊្វុនស៊ិនប៉ិច, គណបក្សលោក សឺន សាន, គណបក្ស សម រង្ស៊ី ឈរក្រោយសម្តេច សីហនុ យ៉ាងត្រង់ជូរដូចគ្នានឹង "សង្គមរាស្ត្រនិយម" កាលពីឆ្នាំ១៩៦០ ដើម្បីប្រឆាំងនឹងបក្សប្រជាជនកុម្មុនីស្តរណប យៀកណាម ដោយពុំបាននឹកចាំថា សម្តេចសីហនុ ខ្លួនព្រះអង្គឯងនៅពីក្រោមម្លប់មហាមិត្តចិន កុម្មុយនីស្ត ម្តងណាសោះ ។ រីឯលទ្ធផលនៅកម្ពុជាមានអ្នកឈ្នះតែពីរនាក់គត់ គឺព្រះបរមរាជវាំង ដែលមិនអាចប៉ះបាន គឺបានទៅសម្តេច សីហនុ ដែលបានប្រគល់សម្បត្តិជាតិនេះ ទៅថ្វាយព្រះមហាក្សត្រថ្មីជាព្រះរាជបុត្រ គឺព្រះនាម សីហមុនី នឹងអ្នកឈ្នះម្នាក់ទៀត ឈរជាន់ពីលើសភាជាតិលើវិមានរដ្ឋាភិបាល និងជាពិសេសលើរដ្ឋធម្មនុញ្ញខ្មែរ គឺលោក ហ៊ុន សែន ។

គេនៅចាំបានថា ឆ្នាំ១៩៩៣ អង្គការសហប្រជាជាតិ បានមកចាក់គ្រឹះប្រជាធិបតេយ្យសេរីនៅកម្ពុជាតែភ្លាមនោះ គ្រឹះនោះ ត្រូវបានជីករំលើង ដោយសេចក្តីសម្រេចទី១ : ទាត់ចោលលទ្ធផលឆ្នោត ហើយបង្កើតរដ្ឋាភិបាលក្បាលពីរ ដែលជាហេតុនាំឱ្យមានរដ្ឋប្រហារច្រើនដង ទី២ : "ការបោះឆ្នោតកញ្ចប់" ដែលជីកគាស់រំលើងឫសគល់ប្រជាធិបតេយ្យសេរីនៅកម្ពុជា ហើយនៅទី៣ : គឺឆ្នោតដែលឱ្យតំណាងរាស្ត្រលើស ២/៣ ទៅគណបក្សប្រជាជន នាខែកក្កដា ឆ្នាំ ២០០៨ នេះ ជាសញ្ញានៅចុងបញ្ចប់នៃរបបប្រជាធិបតេយ្យសេរីពហុបក្សជាស្ថាពរ ។

គេតែងស្វែងរកបុព្វហេតុនៃទង្វើដែលនាំកម្ពុជាឱ្យមកស្ថានភាពដ៏ទន់ខ្សោយបំផុត នាថ្ងៃនេះ ។ កម្ពុជាបំរើប្រយោជន៍បរទេស ដោយសារស្ថាប័ននៃជំនឿប្រជាជន គឺរាជានិយមខ្មែរតំណាងដោយសម្តេចឪនរោត្តម សីហនុ បំរើនយោបាយចិនប៉េកាំងកុម្មុយនិស្ត និងស្ថាប័ននយោបាយខ្មែរស្ថិតនៅក្នុងកណ្តាប់ដៃណែនរបស់គណបក្សប្រជាជន ដែលមានកំណើតដោយសារវៀតណាមកុម្មុយនីស្ត តាំងពីជាង៦០ឆ្នាំ រហូតដល់សព្វថ្ងៃនេះ ។ បុព្វហេតុទាំងពីរនេះហើយដែលពុំអាចឱ្យប្រជាជាតិខ្មែរគិតអ្វីបានជាឯករាជ្យសោះ ដោយសារតែប្រយោជន៍បរទេស ហេតុនេះហើយបានជាខ្មែរគ្រប់រូបចេះ តែឃើញប្រវត្តិប្រទេសខ្លួន នៅចង់ផ្គាប់វាសនាជាមួយប្រទេសទាំងពីរនេះ ហើយផ្តល់ប្រយោជន៍ឱ្យគេគ្មានឈប់ឈរឃើញមេដឹកនាំរបស់ខ្លួន ធ្វើសកម្មភាពគ្មានសុចរិតយុត្តិធម៌យ៉ាងគ្មានខ្មាសអៀន ឃើញចុងក្រោយនេះនូវការបោះឆ្នោតដែលអារម្មណ៍ផ្តោតទៅសង្គ្រាមស្នេហាជាតិប្រឆាំងនឹងថៃ ។

✻ អារម្មណ៍ក្នុងសង្គ្រាម ?

ការដាក់ប្រាសាទព្រះវិហារឱ្យទៅជាបេតិកភណ្ឌពិភពលោក នៅចំពេលដែលខ្មែររៀបចំការបោះឆ្នោត ! សម្បត្តិវប្បធម៌ខ្មែរដែលនៅជាប់នឹងទល់ដែន បានត្រូវលោកឯកអគ្គរាជទូតខ្មែរប្រចាំនៅអង្គការសហប្រជាជាតិ បាននិយាយកាលពីខែមករា ឆ្នាំ២០០៨ថា " ខ្មែរ និងថៃត្រូវចុះហត្ថលេខាប្រគល់ប្រាសាទព្រះវិហារឱ្យទៅអង្គការយូណេស្កូជាមួយគ្នា នេះគឺជាច្បាប់អន្តរជាតិដែលខ្មែរ និងថៃយល់ព្រមព្រៀងគ្នារួចអស់ហើយ " ទោះជាបានចុះហត្ថលេខារួម ហើយក៏ដោយ ក៏អារម្មណ៍ធ្វើសង្គ្រាមនៅតែឆេះនៅកម្ពុជា និងនៅប្រទេសថៃ ដែលចង់ឃើញគណបក្សតែរៀង១ខ្លួន "ចេះស្នេហាជាតិ" លើសអ្នកដទៃដែលនៅពេលដែលរាស្ត្រកំពុងតែធ្វើការសម្រេចចិត្តជ្រើសរើសថ្នាក់ដឹកនាំខ្លួន ។ "កម្ពុជាបោះឆ្នោតនៅក្នុងការត្រៀមធ្វើសង្គ្រាម និងផ្តល់ចំណេញឱ្យអ្នកកាន់អំណាច ឥឡូវយកបាន៩០អាសនៈ ដោយឥតអៀនខ្មាស ។

ឧទាហរណ៍ចុងក្រោយនេះចង់បញ្ជាក់ថា គណបក្សកាន់អំណាត្រូវការជាចាំបាច់នូវសម្លេងសភាលើស២/៣ ដើម្បីអនុវត្តន៍នយោបាយផ្តាច់ការនិយមនៅកម្ពុជា ដោយប្រើស្ថាប័នច្បាប់ ដែលគេមានឥទ្ធិពលគ្រប់គ្រាន់ បើគេមិនច្រឡំទេ អំណាចផ្តាច់ការ គឺជាលទ្ធិកុម្មុយនីស្ត តែគេធ្វើតាមបែបថ្មី ដោយប្រើរបបប្រជាធិបតេយ្យសេរីពហុបក្ស ៕

កាដូដឹកនាំប្រទេសថ្មី...

•••ប្រជាពលរដ្ឋខ្មែរ ដែលមានសិទ្ធិបោះឆ្នោត ប្រមាណ៧០ភាគរយ បានចាកចេញពីផ្ទះ ដើម្បីបំពេញភារកិច្ចក្នុងនាមប្រជាពលរដ្ឋល្អជ្រើសរើសតំណាងរាស្ត្ររបស់ខ្លួនដឹកនាំប្រទេសជាតិនៅអាណត្តិទី៤នេះ ។

លោក សម រង្ស៊ី ចុះពិនិត្យមើលការិយាល័យបោះឆ្នោត ដែលប្រជាពលរដ្ឋមកតវ៉ាគ្មានឈ្មោះក្នុងបញ្ជី

អ្នកមានសិទ្ធិបោះឆ្នោត បានឈរតំរង់ជួរគ្នា នៅតាមមុខការិយាល័យដើម្បីចូលទៅបោះឆ្នោតក្នុងទឹកមុខស្រស់ស្រាយ ប៉ុន្តែទន្ទឹមនឹងនោះគេសង្កេតឃើញមានប្រជាពលរដ្ឋនៅស្ទើរគ្រប់ខេត្ត-ក្រុង បាត់ឈ្មោះពីបញ្ជី ដែលខ្លួនធ្លាប់បោះ និងមានសមត្ថកិច្ចមួយចំនួនថ្នាក់ភូមិ-ឃុំនៅតាមបណ្តាការិយាល័យទាំងនោះ ។

ទិដ្ឋភាពនៅថ្ងៃបោះឆ្នោតនោះ បានបង្កឱ្យគណបក្សធំៗ និងក្រុមអ្នកឃ្លាំមើលការបោះឆ្នោតចោទប្រកាន់ថា មានភាពមិនប្រក្រតី គឺជាច្រើនចំនួនប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោត បានបាត់ឈ្មោះរបស់ខ្លួន ។ លទ្ធផលបណ្តោះអាសន្នដំហានដំបូងសំរាប់ការបោះឆ្នោតលើកទី៤នេះ គឺបានធ្លាក់ទៅលើគណបក្សប្រជាជន កម្ពុជាដឹកនាំអំណាចចាក់ឫសបន្តទៀត ។

កាដូដឹកនាំប្រទេស ដែលកំពុងតែមានភាពចំរូងចំរាស់នេះ ត្រូវបានក្រុមមន្ត្រីឃ្លាំមើលការបោះឆ្នោតសន្និដ្ឋានថា អាចធ្វើឱ្យលទ្ធិប្រជាធិបតេយ្យមានការធ្លាក់ចុះមួយកំរិត ហើយគណបក្សប្រជាជនកម្ពុជាអាចនឹងធ្វើវិសោធនកម្មច្បាប់ដោយប្រការណាមួយ ដែលខ្លួនយល់ឃើញ ។

✻ ទស្សនៈអ្នកបានចូលរួមការបោះឆ្នោត

ពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត បានឈរតំរង់ជួរគ្នាមានទឹកមុខស្រស់ស្រាយ មិនថាចាស់ឬក្មេងនោះទេ ដែលបានតាំងចិត្តជាស្រេចថានឹងជ្រើសរើសយកមេដឹកនាំប្រទេសជាតិឱ្យមានការអភិវឌ្ឍពិតប្រាកដដូចប្រទេសជឿនលឿន ។

ពេលកំពុងឈរតំរង់ជួរ មានស្ត្រីម្នាក់ ឈ្មោះ ហ៊ិន ស៊ីណេត អាយុ៥១ឆ្នាំ ដែលកំពុងឈរតំរង់ជួរក្រោយគេនៅមណ្ឌលឧបសម្ព័ន្ធអន្លង់ក្ងាន ជាយក្រុងភ្នំពេញបានឱ្យដឹងថា គាត់ចង់បានមេដឹកនាំថ្មីណាដែល ចេះការពារទឹកដីមិនឱ្យបរទេសឈ្លានពាន ។

លោក ស៊ិន ចាន់រដ្ឋា អាយុ២៦ឆ្នាំ ឈរតំរង់ជួរបោះឆ្នោតនៅមណ្ឌលខាងលើ បានឱ្យដឹងថា

លោកបានធ្វើការសំរេចចិត្តរួចហើយ គឺត្រូវតែប្តូរមេដឹកនាំថ្មី ដើម្បីឱ្យធ្វើការអភិវឌ្ឍជាតិម្តង

(តទៅទំព័រទី១៨)

ស្ថានីយទូរទស្សន៍សហព័ន្ធខ្មែរ
KFLiveTV.com
Khmer Federation LIVE Television
KFLiveTV is a division of KFNetwork
Broadcasting live Cambodian television and radio stations 24 hours 7 days a week worldwide.
Below are the many quality programming channels we offer:
ចាប់ផ្សាយជូនលោកអ្នក ទូទាំងពិភពលោក ២៤ ម៉ោង ជារៀងរាល់ថ្ងៃ
ស្ថានីយទូរទស្សន៍ សហព័ន្ធខ្មែរ ជាបណ្តាញផ្សព្វផ្សាយថ្មី តាមប្រព័ន្ធ អិនធើណេត មានកម្មវិធីផ្សាយបន្តផ្ទាល់ ពីស្ថានីយទូរទស្សន៍ប្រចាំប្រទេសកម្ពុជា
We offer more Cambodian television and radio channels than any other Cable or Satellite service combined!
Join Now at: www.kflivetv.com
*requires high speed DSL minimum 1.5mbps
Call Now to Subscribe!
Moni 1-866-385-4104
As we continue to expand our services, more channels will be added as they become available.
Please, Call now for commercial, advertisement space or reserve your own IPTV channel.

អាជ្ញាធរមូលដ្ឋាន...

ទោះបីជាយ៉ាងណាក៏ដោយលោកត្រូវតែធ្វើការផ្លាស់ប្តូរដែរ ។

ព្រះតេជគុណ ឈឹម សុភ័ក្រ គង់នៅវត្តស្ទឹងមានជ័យ បានមានសង្ឃដីកាថា ព្រះអង្គមកបោះឆ្នោត ដើម្បីបំពេញភារកិច្ចជាពលរដ្ឋខ្មែរ ហើយចង់បានមេដឹកនាំដែលយកចិត្តទុកដាក់លើវិស័យព្រះពុទ្ធសាសនា មានការគោរពសិទ្ធិមនុស្ស និងចេះគិតគូរពីសុខទុក្ខរបស់ប្រជារាស្ត្រ ។

អ្នកស្រី លី សុធារ៉ា ដែលទៅបោះឆ្នោត នៅមណ្ឌលបឋមសិក្សាសុធារស បានឱ្យដឹងថា អ្នកស្រីបោះឆ្នោតឱ្យគណបក្សកាន់អំណាច ពីព្រោះគណបក្សនេះ បានចូលរួមសុខទុក្ខជាមួយគាត់ និងអភិវឌ្ឍន៍ភូមិ-ឃុំ ផ្លូវថ្នល់ សាលារៀនបន្តទៀត ។

*ពលរដ្ឋអត់ឈ្មោះបោះឆ្នោតខឹងសម្បារ

ក្នុងបរិយាកាសថ្ងៃបោះឆ្នោតនេះ គេសង្កេតឃើញមានបញ្ហាការបាត់ឈ្មោះអ្នកបោះឆ្នោត អ្នកលួចបោះឆ្នោតជំនួស អ្នកខ្លះមានឈ្មោះហើយមិនបានបោះឆ្នោត ទាំងនៅរាជធានីភ្នំពេញ និងបណ្តាខេត្ត-ក្រុងនានា ដែលធ្វើឱ្យមហាជនមានការអក់អន់ស្រពន់ចិត្តយ៉ាងខ្លាំង ចំពោះនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្នុងទឹកមុខស្រពាប់ស្រពោន និងចង់បង្ហាញពីឆន្ទៈ ក្នុងនាមជាប្រជាពលរដ្ឋនោះ ស្រីម្នាក់ឈ្មោះ ភោគ ជា រស់នៅភូមិ ២៨ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ដែលធ្លាប់បោះឆ្នោតរាល់លើកបានឱ្យដឹងថា គាត់មានការសោកស្តាយណាស់ ដោយមិនបានបោះឆ្នោត ហើយគាត់មកកាន់ទីស្នាក់ការគណបក្ស សម រង្ស៊ី ឱ្យលោក សម រង្ស៊ី ជួយអន្តរាគមន៍ ដើម្បីមានសិទ្ធិបោះឆ្នោតនឹងគេ ។

អ្នកស្រី ភោគ ជា បន្តថា គាត់មានប័ណ្ណបោះឆ្នោត មានអត្តសញ្ញាណប័ណ្ណត្រឹមត្រូវ ប៉ុន្តែមិនមានឈ្មោះបោះឆ្នោតនឹងគេឡើយ ។ ចំណែកក្នុងគ្រួសារគាត់ មានមនុស្ស៥នាក់ត្រូវបោះឆ្នោតមានឈ្មោះតែ២នាក់ប៉ុណ្ណោះបានបោះឆ្នោត ។

នៅសង្កាត់បឹងទំពុន ប្រជាពលរដ្ឋប្រមាណ ១០.០០០នាក់ គ្មានសិទ្ធិបោះឆ្នោត ដោយសារការបាត់ឈ្មោះ ដើររកមិនឃើញមាន និងអ្នកខ្លះទៀតមានឈ្មោះដែរ សរសេរមិនត្រូវតាមអក្ខរាវិរុទ្ធ គេមិនអនុញ្ញាតឱ្យចូលបោះឆ្នោតឡើយ ។

លោក ម៉េង សុង ដែលធ្លាប់បោះឆ្នោត នៅសាលាបឋមសិក្សាបឹងទំពុន ដែលគ្មានឈ្មោះបោះឆ្នោត បានបង្ហាញពីអារម្មណ៍មិនសប្បាយចិត្ត ចំពោះគណៈកម្មាធិការរៀបចំការបោះឆ្នោតថ្នាក់ ឃុំ-សង្កាត់ ដែលធ្វើឱ្យមានលក្ខណៈស្មុគស្មាញធ្វើឱ្យពួកគាត់បាត់បង់សិទ្ធិជាប្រជាពលរដ្ឋ ។

សំរាប់នៅតាមបណ្តាខេត្ត-ក្រុងនានា នៅថ្ងៃបោះឆ្នោត មានបាតុភាពប្រហែលគ្នានោះ មានខេត្តរតនគិរី, ក្រចេះ, ព្រៃវែង, កំពង់ស្ពឺ, កំពង់ឆ្នាំង, ពោធិ៍សាត់, ស្វាយរៀង, សៀមរាប, ក្រុងព្រះសីហនុ, កោះកុង, បន្ទាយមានជ័យ, ប៉ៃលិន, និងកណ្តាល... ។

ក្នុងព្រឹកថ្ងៃបោះឆ្នោតនោះលោក សម រង្ស៊ី បានសំដែងនូវការសោកស្តាយចំពោះប្រជាពលរ

រដ្ឋភាគច្រើនដែលគ្មានឈ្មោះរាប់ពាន់នាក់នៅតាមមណ្ឌលនីមួយៗដោយសារតែការប្តូរនីតិវិធីរបស់គណៈកម្មាធិការរៀបចំការបោះឆ្នោត។

លោក សម រង្ស៊ី បញ្ជាក់ថា លោកនឹងធ្វើការតវ៉ាឱ្យមានការរៀបចំការបោះឆ្នោតឡើងវិញចំពោះមណ្ឌលភ្នំពេញញដែលមានភាពមិនប្រក្រតីយ៉ាងខ្លាំង ។

*ប្រតិកម្មរបស់អង្គការឃ្លាំមើលការបោះឆ្នោត :

មានបញ្ហាធ្ងន់ធ្ងរអំពីអ្នកបោះឆ្នោតចំពោះការបាត់ឈ្មោះយ៉ាងច្រើន ឬអ្នកបោះឆ្នោតរកការិយាល័យ និងឈ្មោះមិនឃើញ ។ ករណីនេះមានការកើតឡើងយ៉ាងច្រើននៅស្ទើរគ្រប់ខេត្ត-ក្រុង ។

ទិដ្ឋភាពនៅការិយាល័យបោះឆ្នោតជាយក្រុងភ្នំពេញ

លទ្ធផលនៃភាពមិនប្រក្រតីនេះនឹងជះឥទ្ធិពលដល់លទ្ធផលបោះឆ្នោត និងចំនួនអ្នកបានបោះឆ្នោត បើទោះបីជាចំនួនអ្នកបានទៅបោះឆ្នោតមានច្រើន ឬយ៉ាងណាក៏ដោយ ហើយការលុបឈ្មោះរបស់អ្នកបោះឆ្នោត និងការដូរទីតាំងការិយាល័យផងដែរ ។ នៅតាមបណ្តាខេត្ត-ក្រុងធំៗមួយចំនួន ដូចជា ភ្នំពេញ បន្ទាយមានជ័យ កំពង់ចាម ជាក់ស្តែងនៅសង្កាត់ ទន្លេបាសាក់ (សហគមន៍ដីក្រហម ប្លុកប៊ុលឌិញ) សង្កាត់បឹងទំពន់ (វត្តសន្សំកុសល) ទីក្រុងភ្នំពេញ។

លោក ធន សារាយប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល និងជាប្រធានសមាគមអាដហុក មានប្រសាសន៍ថា បញ្ហាបញ្ជីឈ្មោះបោះឆ្នោត ការបាត់ឈ្មោះអ្នកបោះឆ្នោត អ្នកបោះឆ្នោតគ្មានព័ត៌មានអំពីការិយាល័យ (មិនទទួលប័ណ្ណព័ត៌មានអ្នកបោះឆ្នោត) និងការយល់ច្រឡំរបស់អ្នកបោះឆ្នោត ក្នុងការប្រើប្រាស់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ឬនៅពេលគ្មានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ពិតជាបណ្តាលមកពីមូលហេតុនីតិវិធីបច្ចេកទេស រួមទាំងចេតនានយោបាយផងដែរ ។

លោក ធន សារាយ បន្តថា មានការសោកស្តាយយ៉ាងខ្លាំង ដែលបញ្ជីឈ្មោះអ្នកបោះឆ្នោតការបាត់ឈ្មោះនិងអ្នកបោះឆ្នោតគ្មានព័ត៌មានត្រឹមត្រូវអំពីប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ក៏បានចូលរួមចំណែកនាំឱ្យចំនួនអ្នកបោះឆ្នោតតិតជាភាគរយធ្លាក់ចុះ (បានប្រហែល៧០%) បើធៀបនឹងការបោះឆ្នោតឆ្នាំ២០០៣ ។

សហព័ន្ធ វេទិកាប្រជាជនស្តីពីកម្ពុជា-ជប៉ុន (PEFOC,J) មានប្រសាសន៍ថា ប្រព័ន្ធចុះបញ្ជីឈ្មោះអ្នកបោះឆ្នោតមិនត្រូវបានកែលម្អសោះ។ មន្ត្រីរាជការ និងអាជ្ញាធរមូលដ្ឋាន នៅតែមានវត្តមាននៅតាមការិយាល័យបោះឆ្នោត ដូចជាការបោះឆ្នោតមុនៗ ដែលទង្វើនេះ អាចនឹងប៉ះពាល់ដល់ការសម្រេចចិត្តតាមឆន្ទៈរបស់ពលរដ្ឋម្ចាស់ឆ្នោតក្នុងការជ្រើសរើសអ្នកតំណាងរបស់ខ្លួន ។

លោក Kumaoka Michiya បន្តថា ការចេញទម្រង់១០១៨ ដើម្បីបញ្ជាក់អត្តសញ្ញាណយកទៅបោះឆ្នោត នៅតែបន្តមាននៅថ្ងៃបោះឆ្នោត ដូចជានៅខេត្តរតនគិរីជាដើម បើទោះបីជាការណែនាំរបស់ គ.ជ.ប បានអនុញ្ញាតធ្វើបានត្រឹមម៉ោង៥:៣០ល្ងាច ថ្ងៃទី២៦ ខែកក្កដា ក៏ដោយ ។

លោក Kumaoka Michiya បញ្ជាក់ថា តាម ការសង្កេតនៅថ្ងៃសឃើញមានគណបក្សបានដឹកជញ្ជូនអ្នកបោះឆ្នោតជាកម្មករពីភ្នំពេញទៅតាមបណ្តាខេត្ត-ក្រុងនានា ដូចជានៅខេត្តស្វាយរៀង កំពង់ចាមជាដើម ។ គណបក្សនយោបាយក៏បានធ្វើសកម្មភាពចែកអំណោយដល់ម្ចាស់ឆ្នោតផងដែរ ដូច ជានៅ ឃុំចំប៉ី ស្រុកអង្គរជ័យ ខេត្តកំពត, ស្រុកកំពង់រោទិ៍, កំពង់ត្របែក ខេត្តព្រៃវែង ជាដើម ។

មានការបញ្ជូនកងកម្លាំងប្រដាប់អាវុធឱ្យទៅបិទការផ្សាយវិទ្យុមហានគរ FM 93.5MHz ទាំងយប់ (វេលាម៉ោងប្រមាណ ១១យប់ ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០០៨ ដោយក្រសួងព័ត៌មានដោយគ្មានលិខិតបញ្ជា ឬប្រកាសពីក្រសួងនេះឡើយ ។ លុះព្រឹកថ្ងៃទី២៧ ខែកក្កដា ទើបមានប្រកាសពីក្រសួងព័ត៌មានដកហូតអាជ្ញាប័ណ្ណផ្សាយវិទ្យុនេះឡើងវិញ ក្រោមហេតុផលថា វិទ្យុនេះបានរំលោភសេចក្តីណែនាំរបស់ក្រសួងព័ត៌មាន និងគោលការណ៍ណែនាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានស្នើដល់ក្រសួងព័ត៌មាន ដើម្បីអន្តរាគមន៍ ។

លោក គល់ បញ្ញា មានប្រសាសន៍ថា ការអនុវត្តច្បាប់ក្នុងការដាក់ទណ្ឌកម្ម ចំពោះប្រព័ន្ធផ្សព្វផ្សាយដែលរំលោភច្បាប់បទបញ្ជា-នីតិវិធី និងគោលការណ៍ណែនាំរបស់ គ.ជ.ប មិនមានលក្ខណៈស្មើភាពគ្នាចំពោះមុខច្បាប់ ។

ខុមហ្វ្រែល បានរកឃើញជាបឋមនូវភាពមិនប្រក្រតីមួយចំនួនដូចខាងក្រោមនេះ :

អាជ្ញាធរមូលដ្ឋាន មេភូមិ មេឃុំ/ សង្កាត់មាន វត្តមាននៅជិតទីតាំងការិយាល័យបោះឆ្នោត តាមឃ្លាំមើលអ្នកបោះឆ្នោតដែលនាំឱ្យមានភាពភ័យខ្លាចដល់អ្នកបោះឆ្នោតស្ទើរតែគ្រប់ទីតាំងការិយាល័យបោះឆ្នោត នៅស្រុកឡាបានសៀក ខេត្តរតនគិរី ក្រចេះ ភ្នំពេញ ព្រៃវែង កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ ស្វាយរៀង ។

លោក គល់ បញ្ញា បន្តថា ករណីបាត់ឈ្មោះអ្នកបោះឆ្នោត នៅសង្កាត់បឹងទំពុនប្រមាណជាង៣០ភាគរយនៃអ្នកទៅបោះឆ្នោត (ប្រហែលជាង ១០.០០០នាក់) នៅសង្កាត់ទន្លេបាសាក់ និងសហគមន៍ដីក្រហមប្រមាណ៥០ភាគរយ (គួរបញ្ជាក់ថា ការិយាល័យគឃ/សប

(តនៅទំព័រទី១៩)

Reasons Why You Want to Put
The Advertisement with the Khmer Post
In Philadelphia

បុព្វហេតុដែលនាំឱ្យលោកអ្នកផ្សាយពាណិជ្ជកម្មនៅ "ខ្មែរប៉ុស្តិ៍"

The Khmer Post is the only Cambodian media that available to reach out over 30,000 Cambodian readers who live in Philadelphia.

"ខ្មែរប៉ុស្តិ៍" គឺជាប្រព័ន្ធផ្សព្វផ្សាយខ្មែរតែមួយ ដែលចែកផ្សាយដល់អ្នកអានខ្មែរប្រមាណ ៣ ម៉ឺននាក់ កំពុងរស់នៅ ហ្វីឡាដែលហ្វីយ៉ា

One phone call away to grow your business, 20% discount when you sign up for a contract of year by calling this number (267) 253-3947.

លេខទូរស័ព្ទដែលធ្វើឱ្យពាណិជ្ជកម្មលោកអ្នករីកដុះដាល គឺ :
(267) 253-3947
យើងខ្ញុំចុះថ្លៃជូន ២០ % បើលោកអ្នកផ្សាយ ១ ឆ្នាំ

Growing your business. Advertise yourself.

ការដឹកនាំប្រទេសថ្មី...

នៅសង្កាត់នេះបានបិទទ្វារមិនធ្វើការ) សាលារៀនស្ទឹងមានជ័យសាលារៀនចាក់អង្រែក្រោមសង្កាត់ចាក់អង្រែក្រោមប្រមាណ២០ទៅ៣០ភាគរយ សង្កាត់បឹងរាំង សាលារៀនបឹងត្របែក សង្កាត់ទឹកល្អក់ ឃុំគោកដំបែរ ខេត្តកំពង់ចាម ឃុំព្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ និងឃុំដើមមៀន ស្រុកតាខ្មៅ ខេត្តកណ្តាល ឃុំអូរអំបិល ស្រុកសេរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ (សាលាបឋមសិក្សាព្រហូត) កំពង់ឆ្នាំង ប៉ៃលិន ឧត្តរមានជ័យ កណ្តាលបាត់ដំបង ។

លោក គល់ បញ្ញា បន្តថា អាជ្ញាធរមូលដ្ឋានមេឃុំបន្តធ្វើទម្រង់១០១៨ នៅថ្ងៃបោះឆ្នោតដែលជាក់ស្តែងនៅក្នុងឃុំ/ស្រុកឡាបានសៀក ខេត្តរតនគីរី ឃុំព្រែកល្ពៅ ស្រុកពញាឮ ខេត្តកំពង់ចាម ក្រុងព្រះសីហនុ កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ ភ្នំពេញ ។

ករណីឱ្យថវិកាដើម្បីឱ្យអ្នកបោះឆ្នោតទៅបោះឆ្នោតឬសន្យាថានឹងឱ្យលុយប្រសិនបើមិនទៅបោះឆ្នោត នៅឃុំខ្វាវ ស្រុកទ្រាំង ខេត្តតាកែវ កំពង់ធំ ស្ទឹងត្រែង ឃុំកំពង់រោទិ៍ ខេត្តព្រៃវែង កំពង់ឆ្នាំង ស្វាយរៀង យ៉ាងតិច១២ករណី ។


ទិដ្ឋភាពបោះឆ្នោត និងរាប់សន្លឹកឆ្នោត

ក្នុងសេចក្តីប្រកាសព័ត៌មានសង្កេតបឋម នៅថ្ងៃសនិងថ្ងៃបោះឆ្នោតរបស់អង្គការនេះ បានបង្ហាញថា គណបក្សនយោបាយដឹកប្រជាពលរដ្ឋទៅបោះឆ្នោតជាក់ស្តែងនៅឃុំសំពៅលូន ស្រុកសំពៅលូន ខេត្តបាត់ដំបង (ការិយាល័យលេខ ០៧២២) ស្រុកឡាបានសៀក ខេត្តរតនគីរី ស្វាយរៀង ឧត្តរមានជ័យ ។

ការរារាំងសិទ្ធិអ្នកបោះឆ្នោត ដែលជាក់ស្តែង ថៅកែភោជនីយដ្ឋាន និងសណ្ឋាគារភ្នំពេញ បានបំបិទសិទ្ធិអ្នកបោះឆ្នោតប្រមាណ៦០ភាគរយ នៃនិយោជិក ៤០នាក់ មិនឱ្យទៅបោះឆ្នោត ។

បោះឆ្នោតជំនួសនៅឃុំអូរស្រឡៅ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ផ្សារដើមថ្កូវ កំពង់ចាម ស្វាយរៀង៥ករណី ។

ខុមហ្វ្រែល បានរកឃើញមានអ្នកបោះឆ្នោតភាគច្រើនពាក់អាវយឺតសរជាក្រុម១ ទៅបោះឆ្នោតជាច្រើនពាន់អ្នកនៅខេត្តតាកែវ ។

ករណីមានគេបោះឆ្នោតជំនួសរួចហើយ នៅសាកលវិទ្យាល័យភ្នំពេញ (១ករណី) ។

ពាក់អាវឯកសណ្ឋានប៉ូលិស និងទាហានចូលទៅបោះឆ្នោតនៅការិយាល័យមន្ទីរវប្បធម៌ខេត្តរតនគីរី តាកែវ ភ្នំពេញ កំពង់ស្ពឺ ៤ករណី។ ករណីដើរចូលបន្ទប់សម្ងាត់ ដើម្បីប្រាប់អ្នកបោះឆ្នោត ១ករណី ។ ការដកហូតបញ្ជីឈ្មោះបោះឆ្នោតពីអ្នកសង្កេតការណ៍នៅខេត្តតាកែវ១ករណី ។

ការិយាល័យបោះឆ្នោតមួយពេលហូបបាយនៅក្នុងខណ្ឌឫស្សីកែវ១ករណី ។

រំលោភនីតិវិធីដោយផ្តល់សិទ្ធិបោះឆ្នោតដោយគ្រាន់តែមានប័ណ្ណព័ត៌មាន និងប័ណ្ណសមាជិកគណបក្ស១០ករណី ។

ការចូលបោះឆ្នោតបាន២ដង នៅភ្នំពេញ១ករណី ។

មិនឱ្យអ្នកសង្កេតការណ៍ចូលក្នុងការិយាល័យនៅការិយាល័យជ្រោយអំបិល ឃុំចំបក់ ខេត្តក្រចេះ១ករណី ។

ក្នុងសន្និសីទកាសែត កាលពីល្ងាចថ្ងៃទី២៧ និង ព្រឹកថ្ងៃទី២៨ កក្កដា លោក ធន សារាយ បានសំដែងនូវកង្វល់ និងផលប៉ះពាល់នៃដំណើរការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៤ អាចធ្វើឱ្យលទ្ធិប្រជាធិបតេយ្យធ្លាក់ចុះ ។

លោក Somsri Hananuntasak នាយិកាប្រតិបត្តិគណៈកម្មាធិការ អានហ្វ្រែល បានមានប្រសាសន៍ថា លទ្ធផលនៃដំណើរការបោះឆ្នោតនោះ អាចនឹងប៉ះពាល់ដល់អភិបាលកិច្ចគ្មានការត្រួតពិនិត្យ និងគ្មានតុល្យភាព ។

ក្នុងសន្និសីទកាសែតលោក ម៉ក់ទីន កាឡឹឡែន ប្រធានសហគមន៍សង្កេតការណ៍ អឺរ៉ុប បានឱ្យដឹងថា ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៤ មិនមានលក្ខណៈយុត្តិធម៌តាមស្តង់ដាអន្តរជាតិដូចប្រទេសប្រជាធិបតេយ្យនោះទេ ។

លោកបានបន្តថា ការបោះឆ្នោតមានលក្ខណៈមិនប្រក្រតីច្រើន ហើយលោកក៏មិនបានវាយតំលៃយ៉ាងណានោះទេ ដោយទុកឱ្យប្រជាពលរដ្ឋខ្មែរជាអ្នកសំរេចខ្លួនឯង ។

គណៈកម្មាធិការខុមហ្វ្រែល និងបណ្តាញអាស៊ាន សំរាប់ការបោះឆ្នោតដោយសេរីបានបង្ហាញពីការព្រួយបារម្ភថា លទ្ធផលនៃការបោះឆ្នោតនេះ ពិបាកនឹងទទួលយក ដោយលទ្ធផលឈ្នះផ្តាច់មុខរបស់គណបក្សប្រជាជនកម្ពុជា គឺជាគ្រោះថ្នាក់មួយសំរាប់ការដឹកនាំប្រទេសទាំងផ្នែករដ្ឋាភិបាល និងរដ្ឋសភាទៅអនាគត ។

*** ប្រតិកម្មរបស់គណបក្សនយោបាយ**

ទាក់ទិនទៅនឹងភាពមិនប្រក្រតីនៃដំណើរការបោះឆ្នោតនេះ គណបក្សនយោបាយដែលជាប់ឆ្នោតអាណត្តិទី៤ បានធ្វើការរិះគន់ចំពោះការបាត់ឈ្មោះប្រជាពលរដ្ឋក្នុងបញ្ជីអ្នកបោះឆ្នោតច្រើនលើសលប់ ហើយអ្នកខ្លះមិនបានបោះតែមានគេលួចបោះបាត់បញ្ហានេះអយុត្តិធម៌ខ្លាំងណាស់ក្នុងលទ្ធិប្រជាធិបតេយ្យយើងពិបាកនឹងទទួលយក ។ ចំពោះលទ្ធផលទៀតសោតវាមានគម្លាតពីគ្នាខ្លាំងពេក ហើយគណបក្ស សម រង្ស៊ី នរោត្តម រណឫទ្ធិ សិទ្ធិមនុស្ស និងហ៊្វុនស៊ិនប៉ិចបានបង្កើតសម្ព័ន្ធថ្មីមួយ ដើម្បីបដិសេធលទ្ធផលបោះឆ្នោត ដែលមានបញ្ហាចំរូងចំរាស់នេះ ។ សម្ព័ន្ធភាពនេះ គ្រោងនឹងធ្វើការតវ៉ាក្នុងទ្រង់ទ្រាយធំ ចំពោះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឱ្យសើរើពីលទ្ធផលបោះឆ្នោតមិនប្រក្រតីមួយចំនួនឡើងវិញ ។

ក្នុងសន្និសីទកាសែតមួយ កាលពីថ្ងៃទី២៨ កក្កដា នោះ លោក សម រង្ស៊ី ប្រធានគណបក្សសម រង្ស៊ី, លោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្ស ព្រះអង្គម្ចាស់ស៊ីសុវត្ថិសិរីរ័ត្ន អនុប្រធានទី១ (តទៅទំព័រទី២០)

រួមគ្នាការពារកេរដំណែលដូនតា

ចិត្តអស់អែកធ្វើការចរចាជាមួយសៀម ខេត្តស្រះកែវ ប្រទេសសៀម ហើយនៅតែមានចិត្តចង់ចរចាទ្វេភាគីបន្តទៀត ។ ការសំរេចចិត្តបែបនេះត្រូវបានមតិមួយចំនួនរិះគន់ថា រដ្ឋាភិបាលហាក់ដូចជាមានរឿងអាថ៌កំបាំងអ្វីជាមួយថ្នាក់ដឹកនាំសៀមពីអតីតកាល និងបច្ចុប្បន្ន ។

លោក សុន ឆ័យ តំណាងរាស្ត្រគណបក្ស សម រង្ស៊ី បានធ្វើសេចក្តីថ្លែងការណ៍ក្នុងនាមគណបក្ស និងស្នើសុំឱ្យរដ្ឋាភិបាលប្តឹងទៅអង្គការសហប្រ-ជាជាតិទើបប្រសើរ ពីព្រោះការចរចាបែបនេះគ្រាន់តែជាលេសរបស់សៀមប៉ុណ្ណោះ ។ សៀមគេមានទាំងប្រជាជន សេដ្ឋកិច្ច និងយោធា មានប្រៀបជាងយើង ដើម្បីឱ្យអន្តរជាតិដោះស្រាយតាមផ្លូវច្បាប់បង្ខំឱ្យសៀមដកកងទ័ពចេញពីទឹកដីខ្មែរ។

គណបក្សសិទ្ធិមនុស្ស បានធ្វើសេចក្តីថ្លែងការណ៍ និងសរសេរទៅអង្គការយូណេស្កូ ឱ្យជួយអន្តរាគមន៍ករណីប្រាសាទព្រះវិហារ ជាពិសេសស្នើឱ្យព្រះមហាក្សត្រចូលរួមដោះស្រាយ ពីព្រោះព្រះមហាក្សត្រ នៃប្រទេសទាំងពីរមានទំនាក់ទំនងល្អជាមួយគ្នា អាចទំលុះទំលាយគ្នាបាន ។

លោក ឡៅ ម៉ុងហៃ អ្នកស្រាវជ្រាវជាន់ខ្ពស់សិទ្ធិមនុស្សអាស៊ីប្រចាំក្រុងហុងកុង ក៏បានផ្តល់សេចក្តីទុកចិត្តដល់អតីតព្រះមហាក្សត្រនរោត្តម សីហនុ ដែលមានប្រាជ្ញាឈ្លាសវៃ និងកិត្តិស័ព្ទល្បីល្បាញក្នុងឆាកនយោបាយ ដោះស្រាយទំនាស់ប្រាសាទកន្លងមក ។ ជាពិសេសព្រះអង្គធ្លាប់បានទាមទារឯករាជ្យពីបារាំងថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ និងករណីប្រាសាទព្រះវិហារ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២ ។

លោក ឡៅ ម៉ុងហៃ ក៏បានអំពាវនាវឱ្យខ្មែរគ្រប់ស្រទាប់វណ្ណៈ ទាំងក្នុង និងក្រៅប្រទេសត្រូវតែរួបរួមគ្នាផ្តល់គួនាទីជូនព្រះមហាក្សត្រនរោត្តម សីហនុ ដឹកនាំគណៈប្រតិភូធ្វើកិច្ចការនេះប្រកបដោយប្រសិទ្ធភាព ។

ចាប់តាំងពីមានការរំលោភបំពានលើបូរណភាពទឹកដីខ្មែរចំណុចវត្តប្រាសាទព្រះវិហារ ពលរដ្ឋខ្មែរ អង្គការសង្គមស៊ីវិល បានស្រុះស្រួលគ្នាបរិច្ចាគទ្រព្យសម្បត្តិសំរាប់ជួយឧបត្ថម្ភដល់ព្រះសង្ឃកងទ័ពកំពុងការពារទឹកដី និងគ្រួសារពួកគេ ផ្នែកជីវភាព និងលើកទឹកចិត្ត ។

ចំណែកខ្មែរនៅឯនាយសមុទ្របានរៀបចំពិធីរ៉ៃអង្គាសប្រាក់ផ្តល់លុយកាក់ដល់យុទ្ធជនការពារព្រំដែន និងប្រជាពលរដ្ឋតាមរយៈទូរទស្សន៍ CTN អង្គការទ្រទ្រង់មូលនិធិអរិយធម៌ និងចុះទៅដោយផ្ទាល់ ។ សំរាប់ខ្មែរនៅឯនាយសមុទ្រចង់ឱ្យខ្មែរយើងដោះស្រាយដោយសន្តិវិធី ហើយផ្តោតអារម្មណ៍លើការបោះឆ្នោត និងយកបញ្ហាច្បាប់ជាមូលដ្ឋានដើម្បីដោះស្រាយ ។

លោក ខាល ធីល័រ អ្នកឯកទេសផ្នែកអាស៊ីអាគ្នេយ៍នៃមជ្ឈមណ្ឌលនៃមហាវិទ្យាល័យជាតិអូស្ត្រាលី បានផ្តល់បទសម្ភាសន៍ជាមួយ AFP ក្នុងប្រទេសសិង្ហបុរីថា ការប្រឈមមុខ ដោយអាវុធរវាងសៀម និងខ្មែរអាចរីករាលដាលបានយ៉ាងងាយ និងផុយស្រួយណាស់ ។

លោក ខាល ធីល័រ មានការបារម្ភពីមេបញ្ជាការ និងការគ្រប់គ្រងទាហានភាគីទាំងពីរភូមិភាគនេះ មិនដែលប្រឈមមុខក្នុងគ្រោះភ័យបែបនេះ ម្តងណាឡើយ រយៈពេលប្រហែល២០ឆ្នាំមកហើយ ។ ជំលោះបែបនេះធ្លាប់កើតឡើង នៅទសវត្សរ៍ឆ្នាំ ៨០ ពេលសៀម និងឡាវផ្ទុះសង្គ្រាមជាមួយឈុតដណ្តើមយកកោះនៅកណ្តាលទន្លេមេគង្គ ហើយបញ្ចប់ទៅវិញ បន្ទាប់ពីយន្តហោះសៀមត្រូវគេបាញ់ធ្លាក់ ។

ដើម្បីឱ្យសៀមដកកងទ័ពចេញពីចំណុចទំនាស់ និងតាមខ្សែក្រវ៉ាត់ព្រំដែននោះ អ្នកដឹកនាំ និងពលរដ្ឋខ្មែរគ្រប់ទិសទីត្រូវទុកផលប្រយោជន៍ជាតិជាធំ ហើយទុករឿងបុគ្គល និងរឿងបក្សពួកមួយរយៈសិន ។

ទោះបីជាខ្មែរយើងពូជអ្នកចំបាំងក្តី ក៏យើងមិនចាញ់តាមអាវុធដែរ គឺត្រូវតែច្បាំងតាមផ្លូវច្បាប់ឱ្យអង្គការសហប្រជាជាតិជួយតាមរយៈឯកសារភស្តុតាងនានា ដើម្បីឱ្យសៀមអាម៉ាសមុខលើឆាកអន្តរជាតិម្តងទៀត ដែលចង់បានកេរដំណែលខ្មែរមិនខ្មាសអៀននោះ ៕

ការិយាល័យមេធាវី លិនហ្សេ ដ័រង
LAW OFFICE OF LINDSAY DOERING

ទទួលការពារផលប្រយោជន៍លោកអ្នកករណីទូទៅតាមផ្លូវច្បាប់ដូចជា :
▸ ករណីបើករបរពាណិជ្ជកម្ម នឹងផ្ទេរប្រាក់ក្នុងមុខជំនួញ
▸ ករណីទិញលក់អចលនវត្ថុ ដូចជា: ផ្ទះសម្បែង ដីធ្លីជាដើម ។
▸ ករណីគ្រោះថ្នាក់រថយន្ត ឬគ្រោះថ្នាក់នៅកន្លែងធ្វើការ
▸ ករណីអន្តោប្រវេសន៍
▸ ឬករណីឧក្រិដ្ឋកម្ម ។ល។

ធ្លាប់មានបទពិសោធន៍ខ្ពស់ ~ផ្តល់សេវាជូនតាមវិជ្ជាជីវៈ ហើយតម្លៃក៏សមរម្យទៀតផង ~យើងអាចមានអ្នកបកប្រែភាសាជូនលោកអ្នកបាន ។

General practice law office handling matters in :

Corporations and business transations
Read estate
Car Accidents
Work place injury
Immigration
Criminal fefense
Experienced, professional service and reasonable rate. translator available.

Office: (215) 667-8118 2301 Delancey place, Philadelphia PA 19103
☎ Cell : (215) 840-1364 Email : lindsaydoering@yahoo.com

ការដូដឹកនាំប្រទេសថ្មី...

គណបក្សហ្វ៊ុនស៊ិនប៉ិច និងលោក មុត ចន្ថា តំណាងគណបក្ស នរោត្តម រណឫទ្ធិ បានប្រកាសច្រានចោលលទ្ធផលនៃការបោះឆ្នោត ពីព្រោះមានភាពមិនប្រក្រតីច្រើនពេក ។

លោក សម រង្ស៊ី ប្រធានគណបក្ស សម រង្ស៊ី បានថ្លែងថា យើងត្រូវតែធ្វើការទាមទារឱ្យមានការបោះឆ្នោតឡើងវិញ ពីព្រោះប្រជាពលរដ្ឋ ភាគច្រើនមិនមានឈ្មោះបោះឆ្នោត ។ ជាពិសេសយើងប្តឹងទៅអង្គការ UNDP ក្រុមអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ កុំឱ្យទទួលស្គាល់លទ្ធផលបោះឆ្នោតនេះ ។

លោក កឹម សុខា បានឱ្យដឹងថា យើងសូមអំពាវនាវឱ្យសហគមន៍អន្តរជាតិកុំទទួលស្គាល់លទ្ធផលការបោះឆ្នោត ដោយសារក្រុមប្រជាពលរដ្ឋភាគច្រើនគ្មានឈ្មោះបោះឆ្នោត និងការបំបោំងក្លែងបន្លំបញ្ជីបោះឆ្នោត ។

លោក កឹម សុខា បានបន្តថា យើងសូមឱ្យមតិសាធារណជនថ្កោលទោសចំពោះល្បិចកលខិលខូចរបស់ គ.ជ.ប ដែលជាឧបករណ៍របស់គណបក្សប្រជាជនកម្ពុជាក្នុងការរៀបចំការបោះឆ្នោតក្លែងក្លាយ ។

ក្នុងសេចក្តីថ្លែងការនោះ ក៏បានបង្ហាញពីចំណុចអវិជ្ជមានជាច្រើន ក្នុងថ្ងៃបោះឆ្នោត ដូចជាលប់ឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតច្រើនរាប់ពុំអស់ កំណើនសិប្បនិម្មិត ក្នុងសន្លឹកឆ្នោតរបស់គណបក្សប្រជាជនកម្ពុជា និងទំរង់ ១០១៨ ដែលអ្នកអត់អត្តសញ្ញាណប័ណ្ណត្រឹមត្រូវអាចស្នើបោះឆ្នោតបាន ។

យោងតាម The Cambodia Daily បានស្រង់សំដីរបស់លោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងលោក ទេព នីថា អគ្គលេខាធិការគណៈកម្មាធិការរៀបចំការបោះឆ្នោតបានថ្លែងប្រហាក់ប្រហែលគ្នាថា យើងមិនមានបំណង ឆ្លើយតបការចេញរបស់គណបក្សទាំង៤នោះទេ ។

ទាក់ទិននឹងការបាត់ឈ្មោះអ្នកបោះឆ្នោតច្រើន នោះគណកម្មការជាតិរៀបចំការបោះឆ្នោតបានលើកហេតុផលថា បណ្តាលមកអំពីបច្ចេកទេសកុំព្យូទ័រនៅតាមការិយាល័យ ។

ចំណែកគណបក្សទាំង៤នោះ បានធ្វើការបដិសេធលទ្ធផលបោះឆ្នោត និងដាក់ពាក្យបណ្តឹង នៅតាមបណ្តាខេត្ត-ក្រុង គណៈកម្មាការឃុំ-សង្កាត់ ដែលមានភាពមិនប្រក្រតីកើតមានឡើងជាបន្តបន្ទាប់ ។ ប៉ុន្តែប្រធានគណៈកម្មាការរៀបចំបោះឆ្នោតឃុំ-សង្កាត់ និងខេត្ត-ក្រុងភាគច្រើនបានច្រានចោលពាក្យបណ្តឹងទាំងនេះ ហើយថា ការបោះឆ្នោតនេះ សេរីយុត្តិធម៌ និងគ្មានអ្វីកើតឡើងទេ ។

*** លទ្ធផលបណ្តោះអាសន្ន**

យោងតាមលទ្ធផលជាបណ្តោះអាសន្នរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក៏ដូចជា អង្គការឃ្លាំមើលដំណើរការបោះឆ្នោត នៅកម្ពុជា បានបង្ហាញពីលទ្ធផលប្រហាក់ប្រហែលគ្នាថា គណបក្សប្រជាជនកម្ពុជាទទួលបាន៩០អាសនៈ គណបក្ស សម រង្ស៊ី ទទួលបាន២៦អាសនៈ គណបក្សសិទ្ធិមនុស្សទទួលបាន៣អាសនៈ គណបក្សនរោត្តម រណឫទ្ធិ ទទួលបាន២អាសនៈ និងគណបក្សហ៊្វុនស៊ិនប៉ិច ទទួលបាន២អាសនៈ ។

ដូច្នេះ លទ្ធផលឈ្នះដ៏ច្រើនលើសលប់នេះដូចការ ប៉ាន់ស្មានរបស់ CCP មុនការបោះឆ្នោតមែន ។ លទ្ធផលនេះ ត្រូវបានគណបក្សនយោបាយ និងអង្គការឃ្លាំមើលការបោះឆ្នោតថា មានបាតុភាពជាច្រើន ក្នុងដំណើរការបោះឆ្នោត ។ ជាពិសេសប្រជាពលរដ្ឋជាច្រើន នៅទូទាំងប្រទេសបាត់ឈ្មោះបោះឆ្នោត ដែលបង្កើតឱ្យមានប្រតិកម្មយ៉ាងខ្លាំង ។

នៅពេលនេះសកម្មជន នៅតាមមូលដ្ឋានដែលគាំទ្រគណបក្ស សម រង្ស៊ី សិទ្ធិមនុស្ស នរោត្តម រណឫទ្ធិ និងហ្វ៊ុនស៊ិនប៉ិចមួយចំនួនកំពុងរងនូវការគំរាមកំហែងពីអាជ្ញាធរ និងប៉ូលិស ។ ជាក់ស្តែងសកម្មជនឈ្មោះ ញឹម លៀង ដែលគាំទ្រគណបក្សនរោត្តម រណឫទ្ធិ រស់នៅភូមិល្វេ ឃុំល្វេ ស្រុកស្រីសន្ធរ ខេត្តព្រៃវែង ត្រូវប៉ូលិស ឃុំបាញ់សំលាប់ កាលពីយប់ថ្ងៃទី២៨ កក្កដា យ៉ាងអណោចអធម ។

គួរបញ្ជាក់ថា នៅប្រទេសកម្ពុជា បន្ទាប់ពីប្រកាសលទ្ធផលបោះឆ្នោតបណ្តោះអាសន្ន គណបក្សនយោបាយ ដែលចាញ់ឆ្នោត តែងធ្វើបាតុកម្មប្តឹងប្តល់ទៅ គ.ជ.ប ឱ្យដោះស្រាយ ។ ប៉ុន្តែ គ.ជ.ប មិនដែលឆ្លើយតប ចំពោះការស្នើសុំនោះទេ ហើយបាតុកម្មរាល់លើកតែងមានវត្តមានអតីតព្រះមហាក្សត្ររោត្តម សីហនុ ចូលរួមដោះស្រាយទម្លុះទម្លាយភាពទាល់ច្រក ។

ពេលនេះអតីតព្រះមហាក្សត្រនរោត្តម សីហនុ និងព្រះមហាក្សត្រនរោត្តម សីហមុនី ព្រះអង្គបានយាងទៅក្រុងប៉េកាំង ប្រទេសចិនទៅហើយ មិនដឹងថាព្រះអង្គត្រូវចូលរួមដោះស្រាយបញ្ហានេះដូចលើកមុនដែរឬទេ ? ប្រសិនបើបញ្ហានេះត្រូវជាប់គាំរយៈពេលយូរ នឹងធ្វើឱ្យជីវភាពប្រជាជនកាន់តែជួបនឹងភាពលំបាកមិនខានឡើយ ៕

រាយការណ៍បន្ថែមដោយ មាជ សុវណ្ណរ៉ា

ពន្លកលទ្ធិប្រជាធិបតេយ្យ...

អ្នកនយោបាយទាំងនោះគ្មានស្តីនិយាយ ក៏ចេះតែមូលបង្កាច់គេឯង ហើយប្រជាពលរដ្ឋគាត់យល់ហើយបញ្ហានេះ យើងធ្វើកន្លងមកដើម្បីអ្វី ។ យើងបានធ្វើការតស៊ូយូរណាស់ហើយ ដើម្បីឱ្យមានការផ្លាស់ប្តូរគណបក្សកាន់អំណាចមិនមែនចង់យកឈ្នះចាញ់ជាមួយគណ - បក្ស សម រង្ស៊ី នោះទេ ។ ដូច្នេះអ្វីដែលយើងធ្វើបានគណបក្សទាំងនោះធ្វើមិនបានទេ ដោយសារយើងមានមនុស្សសំខាន់៧ គឺលោក ប៉ែន សុវណ្ណ, លោក កែវ រ៉េមី និងលោក ស៊ីន សុប៉ែរ្តិ៍ សុទ្ធតែអ្នកដែលមានការតស៊ូលះបង់ប្តូរផ្តាច់ ។

+ នៅពេលនេះអ្នកប្រជាធិបតេយ្យមិនព្រម ធ្វើការរួបរួមជាមួយគណបក្សសិទ្ធិមនុស្សទេ តើលោកមានសង្ឃឹមថា អាចដណ្តើមបានជ័យជំនះដែរឬទេ ? ពីព្រោះអ្វី ?

យើងសង្ឃឹមថា អាចដណ្តើមបានជ័យជំនះ ពីព្រោះអ្នកដែលមិនព្រមចុះចូលជាមួយយើង គឺមានតែអ្នកដឹកនាំ២ ឬ ៣នាក់ប៉ុណ្ណោះ ចំណែកប្រជាពលរដ្ឋនៅតាមមូលដ្ឋានបានមករួបរួមជាមួយគណបក្សសិទ្ធិមនុស្សអស់ហើយ ។ ក្នុងរយៈពេល១០ខែប៉ុណ្ណោះ យើងបានជួបជាមួយប្រជាពលរដ្ឋធ្វើមិទ្ទេញជាង៤០០លើក ហើយយើងបានជួបជាមួយប្រជាពលរដ្ឋជាង៤០ម៉ឺននាក់ ។ ក្នុងចំណោមនោះ ពួកគាត់ភាគច្រើនសុទ្ធតែអ្នកធ្លាប់បោះឆ្នោតឱ្យគណបក្សហ្វ៊ុនស៊ិនប៉ិច, គណបក្សសម រង្ស៊ី និងគណបក្សនរោត្តម រណឫទ្ធិ ពេលនោះពួកគាត់បានសំរេចចិត្តថានឹងបោះឆ្នោតឱ្យគណបក្សសិទ្ធិមនុស្សវិញ ។

+ តើនៅពេលបោះឆ្នោតខាងមុខគណបក្សសិទ្ធិមនុស្សនឹងលើកយកបញ្ហាអ្វីខ្លះទៅឃោសនាដល់ប្រជាពលរដ្ឋឱ្យគាំទ្រ ?

បញ្ហាធំបំផុតដែលគណបក្សសិទ្ធិមនុស្សត្រូវលើកឡើងនោះ គឺបញ្ហាជីវភាពរបស់ប្រជាពលរដ្ឋ ដោយយើងចូលរួមដោះស្រាយបញ្ហាអាទិភាពមួយចំនួនដូចជា វិស័យអប់រំ សុខាភិបាល សង្គមកិច្ច និងកសិកម្ម ។

+ សព្វថ្ងៃនេះទំនាស់ដីធ្លីបានកើតឡើងស្ទើរគ្រប់ទីកន្លែង តើនៅពេលជាប់ឆ្នោតគណបក្សសិទ្ធិមនុស្សមានដំណោះស្រាយបែបណា ?

គណបក្សសិទ្ធិមនុស្ស ជាពិសេសខ្លួនខ្ញុំផ្ទាល់មុននឹងមកធ្វើគណបក្សនយោបាយ ខ្ញុំធ្វើអង្គការសិទ្ធិមនុស្ស ក៏ដូចជាធ្លាប់ធ្វើប្រធានគណៈកម្មាធិការសិទ្ធិមនុស្សរបស់រដ្ឋសភាព្រឹទ្ធសភា ខ្ញុំធ្លាប់ទទួលពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋច្រើនណាស់លើបញ្ហាដីធ្លីនេះ ។

ខ្ញុំបានស្គាល់បញ្ហាដីធ្លីច្បាស់ថា ដីធ្លីកើតមកពីហេតុអ្វី ដូច្នេះការស្គាល់ពីឫសគល់នេះច្បាស់ងាយស្រួលក្នុងការដោះស្រាយទេ ។ បញ្ហាសំខាន់បំផុត គឺត្រូវមានដំណោះស្រាយដីធ្លីជូនប្រជាពលរដ្ឋ ដូចជាប្លង់កម្មសិទ្ធិច្បាស់លាស់សិននិងត្រូវកំណត់ឱ្យច្បាស់លើប្រព័ន្ធតុលាការមានភាពឯករាជ្យ យុត្តិធម៌ និងមិនត្រូវពុករលួយ ។ម្យ៉ាងទៀតយើង អាចដោះស្រាយបានដោយយើងមានយន្តការឯករាជ្យ ដើម្បីជួយតាមដានលើបញ្ហាទំនាស់ ។

+ អតិផរណានៃទំនិញសព្វសារពើបានធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅប្រជាពលរដ្ឋគ្រប់ស្រទាប់សំរាប់រូបលោកនៅពេលជាប់ឆ្នោតអាចបញ្ចុះតំលៃទំនិញបានដែរ ឬទេ ?

យើងអាចបញ្ចុះបាន ពីព្រោះយើងដឹងពីមូលហេតុច្បាស់លាស់នៃទំនិញឡើងថ្លៃ ។ ឧទាហរណ៍ដូចជាប្រេងឥន្ធនៈក្តី គឺយើងយកពន្ធច្រើនពេក អំពើពុករលួយ អត់មានការដេញថ្លៃក្រុមហ៊ុនរកស៊ី ហើយក្រុមហ៊ុននេះទៀតសោតជារបស់គ្រួសារអ្នកដឹកនាំ គឺយើងត្រូវតែបើកទូលាយបញ្ហានេះ ។

ចំពោះទំនិញណាដែលចាំបាច់របស់ប្រជាពលរដ្ឋ គឺត្រូវតែបន្ធូរបន្ថយពន្ធ វាអាចចុះថ្លៃប្រេងបានហើយ ចំណែកឯទំនិញផ្សេងៗនឹងចុះតាមដែរដូចជា ជីដាក់ស្រែរបស់ប្រជាកសិករ គឺយើងទិញពីប្រទេសក្រៅ ។ បើសិនយើងឈ្នះឆ្នោតនឹងធ្វើការណែនាំឱ្យពួកគាត់ផលិតជី ដោយខ្លួនឯងហើយរដ្ឋាភិបាលជួយឧបត្ថម្ភជីគីមីបន្ថែមទៀត ។

ទំនិញផ្សេងៗទៀត គឺមិនត្រូវឱ្យពួកគាត់ចំណាយតាមផ្លូវក្រោមតុច្រើនពេកទេ បើកាលណាចំណាយច្រើនឱ្យទំនិញឡើងថ្លៃហើយ ។ ដូច្នេះត្រូវតែប្រឆាំងនឹងអំពើពុករលួយឱ្យខាងតែបាន ។

ចំណុចទាំងអស់នេះហើយ ដែលយើងសង្ឃឹមថា គណបក្សសិទ្ធិមនុស្សអាចឈ្នះឆ្នោត ពីព្រោះគណបក្សប្រជាជនកម្ពុជាប្រជាពលរដ្ឋអស់ជំនឿមិនអាចដោះស្រាយបញ្ហាជាតិជូនប្រជាពលរដ្ឋបានទេ ។ ចំណែកគណបក្សផ្សេងៗទៀតប្រជាពលរដ្ឋបានស្គាល់ធ្លាប់ភ្លក់រសជាតិអស់ហើយនៅតែមិនដោះស្រាយអ្វីជូនពួកគាត់មិនបាន ។ ជាពិសេសប្រជាពលរដ្ឋចូលរួមគាំទ្រ និងផ្តល់ឱកាសឱ្យយើងរួមចំណែកដឹកនាំប្រទេសជាតិនៅពេលខាងមុខ ៕

ជីវិតអកុសលផ្តល់ឱ្យយុវជនខ្មែរ

ហ្វីឡាដែលហ្វីយ៉ា : ដុល រឿន

•••កាលពីថ្ងៃទី២៦ រំលងអាធ្រាតចូលថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ នៅហ្វីឡាដែលហ្វីយ៉ាខាងត្បូង មានប្រព្រឹត្តការណ៍ដ៏រន្ធត់បានកើតឡើងដល់យុវជន យ៉ុន រ័ត្នសេរី ដែលមានអាយុទើបតែ ២៤ឆ្នាំ ត្រូវបានឃាតករបាញ់សំលាប់ចំនួន១១គ្រាប់ នៅមុំផ្លូវលេខ១៥ កែងផ្លូវ MOORE វេលាម៉ោង១ និង ៥២នាទីយប់ ។ តាមប្រភពអ្នកជិតខាងបានឱ្យដឹងថា ជនរងគ្រោះបានទារលុយចំនួន២០០ ដុល្លារ ពីរជនល្មើស ហើយត្រូវបានជនល្មើសហៅឆ្លងថ្នល់ទៅកន្លែងដែលមានសភាពស្ងាត់ ប្រហែលជា១០នាទីក្រោយមក ស្រាប់តែឮសូរសម្លេងផ្ទុះអាវុធ ក្រោយមកជនរងគ្រោះក៏បានរត់ទៅផ្ទះហៅម្តាយឱ្យជួយ ហើយបានប្រាប់ថា " អាផាន់ណា បានបាញ់ខ្ញុំ " ក្រោយមកសាច់ញាតិជិតខាងក៏បានដឹកយកទៅមន្ទីរពេទ្យ ដើម្បីជួយសង្គ្រោះ ប៉ុន្តែមច្ចុរាជ្យបានផ្តាច់យកអាយុសង្ខារ យុវជន រ័ត្នសេរី ពីលោកយើងនេះ នៅវេលាម៉ោង ៤ និង ៣៧ នាទីព្រឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ បានបន្សល់ទុកនូវភាពក្រៀមក្រំដល់ម្តាយដែលជាស្ត្រីមេម៉ាយ សពរបស់យុវជន យ៉ុន រ័ត្នសេរី ត្រូវបានម្តាយ ព្រមទាំងសាច់ញាតិ យកទៅធ្វើបុណ្យតាមប្រពៃណី នៅវត្តបាលិលេយ្យ ។

បន្ទាប់មកប៉ូលិស បានចាប់ខ្លួនយុវជនពីររូប ឈ្មោះ រីតី បូណាផា អាយុ១៧ឆ្នាំ និង សុផាណា សុវណ្ណ អាយុ១៨ឆ្នាំ ដែលចោទប្រកាន់ពីជម្លោះ របស់ក្រុមពាល ហៅ GANG រហូតដល់អំពើឧក្រិដ្ឋ ។

" បណ្តឹងចំពោះខ្មែរប៉ុស្តិ៍ "

ហ្វីឡាដែលហ្វីយ៉ា : ពិន សំខុន

•••នៅលើអត្ថបទមួយ ដែលខ្មែរប៉ុស្តិ៍ បាននិយាយថា ព្រះសង្ឃ ជា ឆោម នៅវត្តថ្មី នៅរ៉ូដអែឡិន បានរួមភេទជាមួយព្រះសង្ឃគ្នាឯង ហើយពីមុខមកទៀតជាមួយដូនជី នៅវត្តកណ្តាល ត្រូវបានគណកម្មាធិការវត្ត និងលោកគ្រូ ជា ឆោម បានតាំងជាដើមបណ្តឹងទៅតុលាការក្រេងស្តុន CRANSTON ចោទ ថា បរិហារកេរ្តិ៍ និយាយពាក្យមិនពិត ។

នៅថ្ងៃទី០១ ខែកញ្ញា ខាងមុខនេះ ខ្មែរប៉ុស្តិ៍ នឹងនាំសាក្សី រស់ ទៅបកស្រាយជូនតុលាការ អំពីភាពពិតនៃព័ត៌មានរបស់ខ្លួនជូនដើមចោទ ។

ម្ចាស់បេះដូងថ្មីទៅដល់ខ្មមកំសត់...

លោកសូមសំដែងនូវការដឹងគុណចំពោះអង្គការយ៉ាងជ្រាលជ្រៅ ដែលបានជួយសង្គ្រោះជនក្រីក្រកម្ពុជាដោយមិនរើសមុខបែបនេះ ។

អ្នកស្រុកដែលមកចូលរួមក្នុងពិធីសែនព្រេនហៅព្រលឹង ដោយមានលោកសង្ឃសូត្រធមិឧទ្ទិសកុសលផងនោះ បាននិយាយប្រហាក់ប្រហែលគ្នា គឺពួកគាត់ពិតជារំភើបខ្លាំងណាស់ មិនដឹងជារកពាក្យពេចន៍ណាមកថ្លែងអំណរគុណចំពោះអង្គការណ៍នោះទេ ។

ម្នាក់ៗមិនថាចាស់ ឬក្មេងទេ សុទ្ធតែមាន ទឹកមុខស្រស់ស្រាយ បង្ហាញនូវការស្វាគមន៏រាក់ទាក់ចំពោះសប្បុរសជន ហើយពួកគេបានរៀបចំនូវបាយទឹក ម្ហូបចំណី សំរាប់ប្រគេន ចំពោះព្រះសង្ឃ និងភ្ញៀវកិត្តិយសដែលចូលរួមក្នុងពិធីនេះញ៉ាំងឱ្យបរិយាកាសនេះកាន់តែអធិកអធមថែមទៀត ។

អ្នកស្រី ឈន ស៊ិន ម្ដាយ ដារិក ដែលទើបត្រឡប់មកពីសហរដ្ឋអាមេរិកជាមួយកូនស្រី ហើយមានសាច់ឈាមទ្រលុកទ្រលន់ដូចអ្នកមានទ្រព្យសម្បត្តិស្ដុកស្ដម្ភនោះ បានសំដែងនូវការអរគុណចំពោះអង្គការបេះដូងគ្មានព្រំដែន រកអ្វីប្រៀបស្មើពុំបានឡើយ គឺបានជួយទាំងមធ្យោបាយធ្វើដំណើរការស្នាក់នៅហូបចុក និងសេវាព្យាបាលកូនគាត់រយៈពេលជាង៥ខែ រហូតជាសះស្បើយ ហើយជូនដំណើរដល់លំនៅឋានទៀតផង ។

អ្នកស្រី ឈន ស៊ិន បន្តថា ជាមួយគ្នានេះដែរ អ្នកស្រីក៏សូមថ្លែងអំណរគុណចំពោះកាសែតខ្មែរប៉ុស្តិ៍ដែលបានជួយផ្សព្វផ្សាយដំណឹង ក៏ដូចជាសប្បុរសជននៅអាមេរិក ដែលបានជួយឧបត្ថម្ភគាំទ្រទាំងកំលាំងកាយចិត្ត និងសំភារៈ ។ ជាពិសេសបងប្អូនប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិតែងតែធ្វើការសាកសួរព័ត៌មាន និងមកអបអរសាទរយ៉ាងច្រើន ។

ចំណែក ដារិក ដែលទើបទទួលបានបេះដូងថ្មី ហើយវិលត្រឡប់មកដល់ខ្ទមកំសត់នោះ គេហាក់ដូចជាសប្បាយភ្លេចអស់នូវអនុស្សាវរីយ៍នៅឯអាមេរិក ។ ម្ចាស់បេះដូង២០ម៉ឺនដុល្លារបានស្ទុះទៅអោបរឹតមិត្តភក្តិ មីងមា និងចាស់ទុំក្នុងភូមិ បង្ហាញនូវក្ដីទីករលឹកចំពោះគ្នាទៅវិញទៅមក ។

ដារិក បញ្ជាក់ថា នាងមានអារម្មណ៏រំភើបក្រៃលែង ដែលអង្គការបេះដូងគ្មានព្រំដែន អាចជួយសង្គ្រោះឱ្យនាងរួចផុតពីសេចក្ដីស្លាប់ ហើយបានវិលត្រឡប់មកកាន់ស្រុកកំណើតវិញ ។ ពេលនេះខ្ញុំមានក្ដីសប្បាយរីករាយម្ល៉េះទេ ដែលបានមកជួបជុំគ្រួសារ និងអ្នកភូមិយ៉ាងច្រើនកុះករបែបនេះ ។

ក្នុងពិធីស្វាគមន៏ដំណើរមកដល់របស់ ដារិក នេះ លោក Peter Chhun ប្រធានអង្គការបេះដូងគ្មានព្រំដែន បានសំដែងនូវការសប្បាយរីករាយ និងមានមោទនភាពយ៉ាងខ្លាំងចំពោះបងប្អូនក្នុងភូមិ ដែលមកជួបជុំគ្នានៅទីនេះ ក្នុងទឹកមុខរីករាយប្រកបដោយក្ដីសង្ឃឹម ។

លោក Peter Chhun បន្តថា រយៈពេលជាង៥ខែកន្លងមកនេះ អង្គការរបស់លោកនឹងសប្បុរសជននៅអាមេរិក បានចំណាយកំលាំងកាយចិត្ត និងប្រាក់កាក់ដើម្បីជួយជ្រោមជ្រែងព្យាបាលបេះដូង ដារិក រហូត បានជាសះស្បើយឡើង វិញ ។

លោកប្រធានអង្គការបេះដូងគ្មានព្រំដែនបាន បន្តថា នៅពេលបានជាសះ ស្បើយ ខ្ញុំ និងសហការី ក៏ជូន ដារិក ត្រឡប់មកភូមិស្រុកវិញ ហើយអង្គការនៅតែបន្តជួយគាំទ្រ ដារិក ផ្នែក ថែទាំសុខភាពលុយកាក់សំរាប់រៀនសូត្រ លុះចប់ចុងចប់ដើម ។

លោកប្រធានអង្គការបេះដូងគ្មានព្រំដែនបញ្ជាក់ថា ចាប់តាំងពីឆ្នាំ២០០៦ ដែលអង្គការបង្កើតឡើង គឺ ដារិក ជាកុមារីទី១ដែលអង្គការជួយឧបត្ថម្ភគាំទ្រខ្លាំងជាងគេ ហើយនៅពេលថ្មីៗនេះ មានកុមារដែលមានជំងឺបេះដូងជាច្រើនបានមកជួបលោកនៅក្រុងភ្នំពេញ និងខេត្តសៀមរាប ។ ប៉ុន្តែលោកពុំទាន់សំរេចទទួលបានឯកសារពីគ្រូពេទ្យ បញ្ជាក់ពីជំងឺប្រភេទណានោះទេ បើឈឺពិតប្រាកដយើងនឹងទទួលយកទៅព្យាបាលសង្គ្រោះជីវិតឱ្យរួចផុតពីសេចក្ដីស្លាប់ទៀត ។

លោក Peter Chhun បានបញ្ជាក់ថា គោលការណ៏របស់អង្គការលោកជួយតែផ្នែកសុខភាពទេ គឺមិនមានគោលការណ៏ជួយសាងសង់ផ្ទះសំបែង ឬសំភារៈផ្សេងៗទៀតឡើយ ។ លោកសំណូមពរដល់អ្នកស្រី ឈន ស៊ិន ត្រូវតែប្រកបមុខរបរដូចដើម ដើម្បីទ្រទ្រង់ជីវភាពគ្រួសារឡើងវិញ ។

ក្នុងពិធីសំណេះសំណាលគ្នានោះ ក៏មានវត្តមានរបស់លោក Alex Morales Director School Improvement Initiative ក៏បានដឹកនាំសហការីរបស់ខ្លួនមកពីសហរដ្ឋអាមេរិក ដែលមានគ្នាប្រមាណជាង១០នាក់ ដើម្បីស្វែងយល់ពីជីវភាពរស់នៅរបស់អ្នកស្រុកនៅទីនោះ ។

លោក Alex Morales បានសំដែងនូវអារម្មណ៏ស្រងេះស្រងោចពន់ពេកចំពោះទិដ្ឋភាពភូមិស្វាយជ្រុំ ដែលមានទិដ្ឋភាពក្រីក្រយ៉ាងខ្លាំង ប៉ុន្តែទោះជាយ៉ាងណាក៏ដោយលោកបានផ្ដល់ការគាំទ្រផ្លូវកាយចិត្ត ចំពោះគ្រួសារ ដារិក និងអ្នកភូមិបន្តទៀត ដូចជាចែកសៀវភៅ, ប៊ិច, ខោអាវ និងរបស់របរមួយចំនួនទៀត ។

លោក Alex Morales បានបញ្ជាក់ថា នៅពេលអនាគតលោកនឹងវិលត្រឡប់មកប្រទេសកម្ពុជាម្ដងទៀត ដើម្បីជួយកសាងសាលារៀនបង្រៀនភាសាអង់គ្លេសងាយស្រួលក្នុងការរកការងារធ្វើចិញ្ចឹមជីវិត កាត់បន្ថយភាពក្រីក្រតាម ភូមិស្រុករបស់ខ្លួន ។

ដោយមើលឃើញទង្វើសប្បុរសធមិរបស់អង្គការបេះដូងគ្មានព្រំដែន ព្រះករុណានរោត្ដម សីហមុនី បានអនុញ្ញាតឱ្យក្រុមអង្គការបេះដូងគ្មានព្រំដែន និងក្រុមគ្រួសារកុមារី ដារិក ចូលគាល់នៅល្ងាចថ្ងៃទី២០ ខែកក្កដា កន្លងមកនេះ ។

ក្នុងឱកាសនោះ ព្រះករុណានរោត្ដម សីហមុនី បានមានបន្ទូលកោតសរសើរចំពោះអង្គការបេះដូងគ្មានព្រំដែន ដែលបានផ្ដល់សេវាថែទាំសុខភាពដល់កុមារកម្ពុជា ហើយព្រះអង្គ ក៏សូមឱ្យអង្គការបន្តការគាំទ្រជួយសង្គ្រោះប្រជាពលរដ្ឋខ្មែរបន្តទៀត ។

ព្រះអង្គក៏សព្វព្រះទ័យប្រទាននូវប្រាក់១០០០ដុល្លារដល់អង្គការបេះដូងគ្មានព្រំដែន និងបានសំដែងនូវការអរគុណជំនូសប្រជាជនខ្មែរទាំងអស់ផងដែរ ៕

ព្រះមហាក្សត្រនរោត្តម សីហមុនី អនុញ្ញាតឱ្យអង្គការបេះដូងគ្មានព្រំដែនចូលគាល់

ពិធីចែកសំលៀកបំពាក់ដល់ប្រជាពលរដ្ឋក្នុងភូមិ ដារិក

អតីតព្រះមហាក្សត្រ...

១៩៧៩នោះ ពុំមានការទទួលស្គាល់ជាអន្តរជាតិនោះទេ ពីព្រោះត្រូវតុលាការកាត់ទោសដោយកំបាំងមុខ ។ គឺពុំមែនជាដំណើរការរបស់តុលាការអាចទទួលយកបានឡើយ ហើយ អៀង សារី គេពុំទាន់បានកាត់ទោសពីរដងដែរ ។ ករណី អៀង សារី នេះ ត្រូវបានអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកំពុងធ្វើការពិចារណាយ៉ាងល្អិតល្អន់ពីព្រោះនេះជាឧបសគ្គដ៏ធំមួយក្នុងដំណើរការកាត់ក្ដី ។

ចំណែកលោក សុក សំអឿន ប្រធានក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បានធ្វើការប្រៀបពីប្រព័ន្ធតុលាការអំឡុងឆ្នាំ១៩៧៩ និងប្រព័ន្ធតុលាការនៅពេលបច្ចុប្បន្ន គឺវាមានលក្ខណៈខុសគ្នាឆ្ងាយណាស់ ។ ប្រព័ន្ធតុលាការបច្ចុប្បន្នមានលក្ខណៈស្តង់ដារ ហើយ ករណី អៀង សារី នេះត្រូវបានព្រះរាជអាជ្ញាចាប់ខ្លួនបញ្ជូនមកសាលាក្ដីខ្មែរក្រហម ដើម្បីធ្វើការស៊ើបអង្កេត ។

លោក សុក សំអឿន បញ្ជាក់ថា ករណី អៀង សារី ដែលតុលាការខ្មែរកាត់ទោស កាលពីឆ្នាំ១៩៧៩នោះ គាត់ហាក់ដូចជាមិនសូវខ្វាយខ្វល់នឹងការកាត់ទោសពេលកន្លងមកនោះទេ ។

ពេលនេះគាត់បានយកលេសថា ព្រះមហាក្សត្រនរោត្ដម សីហនុ លើកលែងទោសឱ្យគាត់ កាលពីឆ្នាំ១៩៥៦ រួចហើយ ។

ចាប់តាំងពីសាលាក្ដីខ្មែរក្រហមបង្កើតឡើង មេខ្មែរក្រហមដែលត្រូវចាប់ខ្លួនរួមមាន : **១.** អ៊ុង ជឿន ហៅតា ម៉ុក បានស្លាប់បន្ទាប់ពីឃ ឃាំងមួយរយ: ។ **២.** កាំង ហ្គិចអ៊ាវ ហៅ ឌុច មេគុកទួលស្លែងមន្ទីរស -២១ ។ **៣.** នួន ជា បងធំទី២ អតីតប្រធានសភាប្រជាជន និងជាអនុលេខាមជ្ឈិមបក្ស ។ **៤.** ខៀវ សំផន អតីត ប្រមុខ រដ្ឋក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ **៥.** អៀង សារី អតីតរដ្ឋមន្ត្រីក្រសួងការបរទេស និង ភរិយា អៀង ធីរិទ្ធ អតីតរដ្ឋមន្ត្រីក្រសួងសង្គម កិច្ច ។

អតីតមេដឹកនាំខ្មែរក្រហមទាំងនេះ សព្វថ្ងៃ មានវ័យចំណាស់ សុខភាពទ្រុឌទ្រោម និងមាន ជំងឺប្រចាំកាយទៀតផង ហើយពួកគេបានសំណូមព សុំឱ្យសាលាក្ដីខ្មែរក្រហមដោះលែងឱ្យនៅ ក្រៅ ឃុំបណ្ដោះអាសន្ន ដើម្បីងាយស្រួលព្យាបាល ជំងឺ ។

ប្រជាពលរដ្ឋខ្មែរមួយចំនួនបានសំដែងកា ព្រួយបារម្ភខ្លាចមេដឹកនាំខ្មែរក្រហមទាំងនេះ ស្លាប់បាត់បង់ជីវិត ហើយតុលាការមិនទាន់ ដំណើរការចេញជាផ្លែផ្កា ពីព្រោះមេដឹកនាំខ្មែរ ក្រហមពីរនាក់បាន ស្លាប់ទៅហើយ គឺ ប៉ុល ពត បងធំទី១ និង តាម៉ុក មេទ័ពកំពូលរបស់ខ្មែរ ក្រហម ។ ចំណែកអ្នកផ្សេងៗទៀត សុខភាព កាន់តែដុនដាបគួរឱ្យបារម្ភផងដែរ ៕

New World Travel II

New World Travel II

ញូវ៉លត្រាវែលធូ

Specialized in Selling Flight Tickets
For National and International

ជំនាញខាងលក់សំបុត្រយន្តហោះសំរាប់ក្នុងប្រទេស និងអន្តរជាតិ យើងតំណាងឱ្យក្រុមហ៊ុន ចិន កូរ៉េ កាថៃ ។ល ធ្វើលិខិត Re-Entry Permit ប្រញាប់ជូនបាន ទិញសំបុត្រជិះនាវាសមុទ្រ- សណ្ឋាគារ ឬជួលឡាន សំបុត្រយន្តហោះទៅច្រើនប្រទេសក្នុងតម្លៃទាបបំផុត ។

Represented Several of Company such as China, Korea, Cathay etc.,
Offer Rush Re-Entry Permit
Reserve Cruise, Hotels and Car Rentals
Best Price Air Ticket for Many Destinations

600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

ហោរាសាស្ត្រប្រចាំខែ សីហា ថ្ងៃទី ០៩_២៣

ឆ្នាំជូត : (ពពួកទេវតាប្រុស ធាតុទឹក)

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះ លោកអ្នកមានអារម្មណ៍ភ្លឺថ្លា គំនិត ប្រាជ្ញាឈ្លាសវៃ ទោះប្រកបកិច្ចការងារអ្វី១ក៏ដោយ ក៏អាចទទួលបានផលសម្រេចសមតាមបំណងប្រាថ្នាទាំងអស់ ។ ចំពោះស្វាមីភរិយាវិញមានភាពល្អូកល្អីនគ្នាណាស់ ហើយពិសេស នោះស្រលាញ់គ្នាលើសមុនទៅទៀត ៕

ឆ្នាំឆ្លូវ : (ពពួកមនុស្សប្រុស ធាតុដី)

រាសីលោកអ្នកល្អធម្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះរាល់ឧបទ្រពចង្រៃ និងរាល់ឧបសគ្គ ត្រូវបានសាបរលាបជាបណ្តើរ១ ដូច្នេះលោកអ្នកអាចប្រកបកិច្ចការងាររកស៊ីបានពេញដៃពេញជើង ។ ចំពោះអ្នកជំនួញជួញដូរ បើមានប្រគល់ឬទទួលនូវមុខទំនិញសព្វសារពើ ចូរចេះពិនិត្យគុណភាព និងរាប់ចំនួនឱ្យបានច្បាស់លាស់ ទើបពុំមានរឿងឆបោកកើតឡើង ៕

ឆ្នាំខាល : (ពពួកយក្សស្រី ធាតុឈើ)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបរឿងរកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ បើមានរឿងឈ្លោះប្រកែកកើតឡើង ចូរចេះអត់ធ្មត់ និងរម្ងាប់ចិត្តឱ្យបានត្រជាក់ដាច់ខាតមិនត្រូវតបតទាំងកំហឹងទល់នឹងកំហល់ឡើយ ទើបរឿងតូចមិនអាចក្លាយជារឿងធំបាន ។ ក្នុងរយៈពេលនេះ បើមានដំណើរទៅណាមក ណា ចូរប្រយ័ត្នប្រយែងក្រែងជួបគ្រោះថ្នាក់ចរាចរ ៕

ឆ្នាំថោះ : (ពពួកមនុស្សស្រី ធាតុឈើ)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹម១ ។ ក្នុងរយៈពេលនេះ បើជាបុគ្គលិក កម្មករដែលបំរើការងារនៅតាមក្រុមហ៊ុន ឬរោងចក្រនានា ចូរចេះដាក់ខ្លួនដាក់កាយ និងចេះធ្វើទំនាក់ទំនងល្អជាមួយនឹងចៅហ្វាយនាយ ឬថៅកែ ព្រមទាំងអ្នករួមការងារ ជាមួយ ទើបកិច្ចការងារអាចដំណើរការបានស្រួល ៕

ឆ្នាំរោង : (ពពួកទេវតាប្រុស ធាតុមាស)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបរឿងរកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ លោកអ្នកអាចផ្អាករាល់កិច្ចការងារសំខាន់១មួយរយៈពេលសិន ព្រោះបើហ៊ានតែមានចិត្តមានរឹងរូស គឺពិតជាស៊ីយធំអាចបង់ខាតទ្រព្យជាក់ជាមិនខាន ។ ចំពោះស្ត្រីភេទក្នុងរយៈពេលនេះ មិនត្រូវដើរផ្លូវឆ្ងាយដាច់សង្វែង តែម្នាក់ឯងឡើយ ប្រយ័ត្នបានជួបគ្រោះភ័យ ៕

ឆ្នាំម្សាញ់ : (ពពួកមនុស្សប្រុស ធាតុភ្លើង)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹម១ ។ ក្នុងរយៈពេលនេះ ថ្វីត្បិតតែមានផលចំណូលហូរចូលបានច្រើនក្រាស់ក្រែលគួរសមក្តី តែពុំមានសល់អ្វីជាដុំកំភួនឡើយ ព្រោះចាយវាយខ្ជះខ្ជាយខ្លាំងពេក ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះ បើស្រលាញ់កុំទៅញ៉ីក បើរពួកកុំទៅញយ ទើបចំណងស្នេហាអាចគង់វង្សបានយូរអង្វែង ៕

ឆ្នាំមមី : (ពពួកទេវតាស្រី ធាតុភ្លើង)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹង បញ្ហាលំបាក១ច្រើន ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ចូរកុំមានការធ្វេសប្រហែសឱ្យសោះ ជាពិសេសចំពោះអាជីវករអ្នករកស៊ីប្តូរប្រាក់ ឬលក់គ្រឿងអលង្ការមានតម្លៃផ្សេង១ ត្រូវប្រយ័ត្នប្រយែងមានជនខិលខូចលួចបន្លំ ឬឆក់ប្លន់ ៕

ឆ្នាំមមែ : (ពពួកទេវតាស្រី ធាតុមាស)

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ក៏អាចទទួលបានផលសម្រេចសមតាមបំណងប្រាថ្នាទាំងអស់ ។ បើជាអាជីវករ អ្នករកស៊ីជួញដូរ នឹងមានទំនិញលក់ចេញទិញចូលឥតទំនេរដៃ ព្រមទាំងមានទ្រព្យហូរចូលជាហូរហែទៀតផង ៕

ឆ្នាំវក : (ពពួកយក្សប្រុស ធាតុដែក)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹម១ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយត្រូវមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច ជាពិសេសមុននឹងចុះហត្ថលេខា ឬផ្តិតស្នាមមេដៃផ្សេង១ ចូរចេះពិនិត្យពិច័យឱ្យបានល្អិតល្អន់ ព្រោះកាលបើមានការភ្លាំងភ្លាត់តែបន្តិច អាចបង់ខាតផលប្រយោជន៍ច្រើន ៕

ឆ្នាំរកា : (ពពួកយក្សប្រុស ធាតុដែក)

រាសីលោកអ្នកខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីក ចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ ឱកាសល្អ១បានមកដល់ហើយ ដូច្នេះលោកអ្នកត្រូវតែរវៀសរវៃញាប់ជើងញាប់ដៃបន្តិច ព្រោះពេលវេលា ជាមាសប្រាក់ធ្វើច្រើនបានច្រើន ។ ចំពោះគូស្នេហ៍ក្នុងរយៈខែនេះ មានភាពស្និទ្ធស្នាលដូចប្រក្រតី ៕

ឆ្នាំច : (ពពួកយក្សស្រី ធាតុដី)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ក្នុងរយៈពេលនេះ អ្វីដែលលោកអ្នកត្រូវយកចិត្តទុកដាក់នោះ គឺនៅតែមានមនុស្សខិលខូចខ្លះប៉ងបំផ្លិចបំផ្លាញរាល់កិច្ចការងារ ដូច្នេះមុននឹងធ្វើអ្វីមួយ ឬមុននឹងធ្វើដំណើរទៅណាមកណា ចូរមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច ។ ចំពោះគូស្នេហ៍ក្នុង រយៈពេលនេះមានការយល់ចិត្តគ្នាល្អ គ្មានបញ្ហាអ្វីកើតឡើងធំដុំទេ ៕

ឆ្នាំកុរ : (ពពួកមនុស្សស្រី ធាតុទឹក)

រាសីលោកអ្នកខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយក៏មានអ្នកជួយជ្រោមជ្រែងយ៉ាងពេញទំហឹងដែរ ។ ចំពោះស្ត្រីភេទនៅលីវ និងត្រូវបានកម្លោះ១ចោមរោមស្រលាញ់ រហូតអាចឈានដល់ការ ស្តីដណ្តឹងយកធ្វើជាគូអនាគតទៀតផង ៕

Buy something... **Sell** something…**Announce** something…**advertise** on the **Khmer Post Classifieds!**

WANTED
Nail Technicians Are Needed
Please call 215 - 834 - 0559
For details.

Your Advertisement
Is Here For
Less than $10 for two weeks!

South Philadelphia Library, 1700 S. Broad St.
ESL classes, Tuesdays & Thursdays 12:30-3:00 p.m.

Books and DVDs in Khmer language
South Philadelphia Branch, 1700 S .Broad St.
Whitman Branch, 200 Snyder Ave.
Greater Olney Branch, 5501 N. 5th St.
Wyoming Branch, 231 E. Wyoming Ave.

Service
C.C. Building Services
Metropolitan Area

C.C. BUILDING SERVICES
COMMERCIAL & RESIDENTIAL CLEANING
CHEA CHHAY
PRESIDENT
50 NUGENT DRIVE
STAFFORD, VIRGINIA 22554
PHONE: (540) 720-4696
FAX: (540) 720-4697
CELL: (703) 606-9010

រកមនុស្សធ្វើការច្រើនគ្នា

ធ្វើជាអ្នកជំនួយដល់មនុស្សពិការនៅ ជុំវិញ Philadelphia
THIG ទូរស័ព្ទ : **215 320 2040** WEBSITE : www.taigine.org ការងារល្អត្រឹមត្រូវ មាន BENEFIC មានសវិស្សមកាល...

Clip & Fax This
Classified Coupon
Classified Advertising
Name your category: Sales, Services, Fund Raisers…etc.
Our rates: $5.00 for up to 20 words
15 cents each additional words
Send us your ad in one of the following ways:
1. by Fax to (215) 722-2226
2-by mail to the Khmer Post 5730 Rising Sun Avenue.
Philadelphia, Pa 19120 3-By phone (267) 253-3947
Payments methods: cash or checks.
Name:____________Address: _________
City________________________________
State _________Zip_________________
Phone: _______Fax__________________
Your Advertisement Message:
____
____
____

តាម៉ុក និយាយអំពីសេដ្ឋកិច្ចនៅអន្លង់វែង ថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៨

តាម៉ុក និងលោក ខៀវ សំផន បានអនុញ្ញាត្តិនូវបទសម្ភាសន៍ជូន "ពលរដ្ឋសេរី" ស្ដីអំពី ការកាត់ទោសស្ដេចក្រុមព្រះនរោត្តម រណឫទ្ធិ និងការឈប់បាញ់គ្នា"

ដោយ : ពិន សំខុន

សំនួរ : តើអ្នកស្រុកអន្លង់វែង រស់ដោយសារអ្វី ?

តាម៉ុក : អ្នកនៅអន្លង់វែង គឺតំណាងឱ្យប្រជាជនទាំងមូល ជីវិតរបស់គេ គឺស្អាតណាស់ អត់មានប្រឡូកប្រឡាក់ទេ ! រស់ដោយខ្លួនឯងខ្លួនទីពឹងខ្លួន ម្នាក់ៗគេបញ្ចេញកំលាំងពលិកម្មរបស់គេ ដើម្បីខ្លួនគេ គ្មាននរណាផ្គងផ្ដើមទេរដ្ឋ គ្រាន់តែណែនាំ និងជាផែនការណ៍ ។ ជីវភាពបើគិតជាមធ្យម គឺ "កណ្ដាល-លើ" ! មិនធម្មតាទេ បានន័យថា ជីវភាពគេមិនខ្វះខាតម្នាក់ៗ យ៉ាងអន់បំផុតមានគោ ៥ទៅ១៥ ក្នុងមួយគ្រួសារៗ គិតជាតម្លៃគឺ ១សែនបាត គ្រួសារមួយៗ យ៉ាងអន់បំផុតមានលុយជាប្រចាំខ្លួនពី ១ម៉ឺន ទៅមួយសែនបាត ។

សំនួរ : នៅអន្លង់វែង ខ្ញុំឃើញមានតែស្រូវ ក្រៅពីហ្នឹងអត់មានអីសោះ តើមានតែបណ្ដើងទេឬ ?

តាម៉ុក : មានគោ ! មានដំណាំស្រូវ មានចេក ដូច អំពៅ ស្វាយ មាន់ ទា ជ្រូក បើនិយាយពីជ្រូកវិញ ហូបអត់អស់ទេ កងទ័ពប៉ុន្មានក៏ហូបមិនអស់ដែរ ។

សំនួរ: បើសល់មានយកទៅលក់នៅទីណាទេ ?

តាម៉ុក : លក់មិនដាច់ទៀត ! ឯគោ ឥឡូវហ្នឹង ច្រើនជាងមនុស្ស ពីព្រោះមួយគ្រួសារមានគោ១០ក្បាល ។

សំនួរ : បើដូច្នោះ តើធ្វើម៉េច ដើម្បីឱ្យមាន ១សែនបាត ?

តាម៉ុក : លក់គោ !

សំនួរ : លក់ឱ្យនរណា ?

តាម៉ុក : លក់ឱ្យគ្នាឯងផង លក់ឱ្យថៃក៏បានខ្លះដែរ ។

សំនួរ : នៅថៃមានខ្វះគោទេ ?

តាម៉ុក : អាហ្នឹងខ្ញុំមិនដឹងទេ ! យ៉ាងណាក៏ដោយ ក៏ខ្វះដែរ មិនមែនសំបូរទេ ព្រោះប្រទេសធំ ។

សំនួរ : ខ្ញុំឃើញគោច្រើនណាស់ នៅតាមផ្លូវមានជនភៀសខ្លួនចំនួន៧-៨ពាន់នាក់នោះ តើពេលណាទៅបានយកគោហ្នឹងលក់យកលុយ មានលុយមកដាក់ក្នុងផ្ទះ ទើបក្លាយជាសម្បត្តិផ្ទាល់ខ្លួន ស្រួលនាំយកទៅចាយទីផ្សេងបាន ?

តាម៉ុក : យើងខ្ញុំមានផែនការណ៍ហើយ ! ជីវភាពរបស់ប្រជាជនអន្លង់វែង មិនចោទទេ ! អង្ករគេគ្រប់ហូប នេះដែលខ្ញុំថា "កណ្ដាល" ម្ហូប មានហូប !

(តទៅទំព័រទី២៤)

ឱសថស្ថានខ្មែរ
Sav-Mor PHARMACY
បំរើលោកអ្នកដោយមិត្តភាព និងទាន់ចិត្ត
Fast and Friendly Service
Sam EA R.Ph.
2232 S. 7th St. (7th & Wolf) Philadelphia, Pa 19148
Tel: 215.467.1220 Fax: 215.467.1447
▸▸Sav-Mor គឺជាឱសថស្ថានបំរើ ការចែកចាយថ្នាំ ហើយអាចពន្យល់ពីរបៀបប្រើប្រាស់ថ្នាំ តាមវេជ្ជបញ្ជាជាភាសាខ្មែរបាន
▸▸យើងទទួលយកនូវ MEDICARE -MEDICAID និង INSURANCES ជាច្រើនទៀតផង យើងមានលក់កាត សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ឬទៅអន្តរជាតិ
*Accept most insurance plans including Medicare & Medicaid
*Easy Prescription transfer
*Inside. Prepaid phone card. Call Cambodia.

Buy now on DVD
award winning film about a Cambodian American family's story
www.NewYearBaby.net
Phone Order: 877-345-6222
Find out more about Socheata Poeuv's organization Khmer Legacies:
www.KhmerLegacies.org
ទិញនៅទីនេះ
"ទទួលពានរង្វាន់ខ្សែភាពយន្តស្ដីអំពីរឿងគ្រួសារខ្មែរ-អាមេរិកាំង
www.NewYearBaby.net លេខទូរស័ព្ទបញ្ជាទិញ (877) 345-6222
មើលចង់ដឹងបន្ថែមពីអង្គការ "ខ្មែរកេរ្តិ៍ដំណែល" របស់ សុជាតា នៅ : www.KhmerLegacies.org

Nationwide
Insurance & Financial Service
សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ
We offer Cheap Price for Every Client
យើងធ្វើជូនគ្រប់ភ្ញៀវដោយតម្លៃថោក
Business Liability Insurance ធានារ៉ាប់រងជំនួញលោកអ្នក
Home Insurance ធានារ៉ាប់រងផ្ទះសម្បែង
Health Insurance ធានារ៉ាប់រង សុខភាព
Auto Insurance ធានារ៉ាប់រងរថយន្ត
Life Insurance ធានារ៉ាប់រងជីវិត
Discount 30% when you purchase Home & Auto Insurance
ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញ ធានារ៉ាប់រង ផ្ទះ និងរថយន្តរួមគ្នា
South Philadelphia office:
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036
North Philadelphia office:
6603 Bustleton Ave.
Philadelphia, Pa 19149
Tel: (215) 335-2140
Fax: (215) 335-2147

តាម៉ុក និយាយអំពីសេដ្ឋកិច្ចនៅអន្លង់វែង...

មានមាន់ មានគោ មានជ្រូក មាន ត្រីជាមូលដ្ឋាន ត្រី ! គ្រួសារណា ក៏មានត្រីហូបដែរ ជាប្រចាំថ្ងៃ ។ ឯគោ ! គេចិញ្ចឹមជារបរទី២ ស្រូវជាទី១ ។ ស្រូវសំរាប់ហូប គោសំរាប់លក់ ទិញសម្ភារៈប្រើប្រាស់ កាំបិត ចប សំលៀកបំពាក់ គេលក់បានប្រចាំផ្លាស់គ្នាទៅវិញទៅមក ។ ទិសដៅរបស់រដ្ឋ នៅអន្លង់វែង ក្នុងមួយគ្រួសារនៅ អន្លង់វែង ត្រូវពង្រីកគោ ក្នុងមួយគ្រួសារ យ៉ាងអន់ណាស់ មានគោ១០ក្បាល ហើយទាំងអស់ គ្នាធ្វើយ៉ាងម៉េច៥ឆ្នាំទៀត មានគោ ១សែន៥ ម៉ឺនក្បាល ទៅ ២សែនក្បាល ។

សំនួរ : គោដែលចាស់ គេយកទៅលក់ ដើម្បីយកលុយមកចាយវាយ ចុះបើសព្វថ្ងៃលក់មិនបាន គោដែលចាស់ទៅ វានឹងធ្វើឱ្យខាតបង់ទៅហើយ ?

តាម៉ុក : ចាស់ ! កាប់ស៊ី ។

សំនួរ : ចំនួនគោវាច្រើនពេកទេដឹង ?

តាម៉ុក : នឹងលក់ទៅក្រៅខ្លះទៅ ! ថៃគេត្រូវការណាស់ ។

សំនួរ : តើមានបំណង នឹងធ្វើផ្សារសេរីនៅ អន្លង់វែងដែរឬទេ ?

តាម៉ុក : រាល់ថ្ងៃហ្នឹង សេរីហើយតើ ! មិនមែនជារបបកុម្មុយនីស្ត ឬរដ្ឋអីទេ ! រដ្ឋ គឺវាអញ្ចេះ រាល់ថ្ងៃនេះ អ្នកណាលក់អី ក៏លក់ទៅ ! លក់ស្រូវលក់ទៅ ! លក់គោលក់ទៅ ! ស្រេចតែនឹងគេ គ្មានរដ្ឋណាកំណត់ថា អ្នកឯងត្រូវតែលក់ឱ្យរដ្ឋទេ ។ គេលក់ឱ្យគ្នាឯង គេទិញ គេកាប់ស៊ីគ្នាគេ ។

សំនួរ : តើរដ្ឋមានយកពន្ធដែរឬទេ ?

តាម៉ុក : គ្មានយកពន្ធដាអីទេ រាល់ថ្ងៃនេះ ។

សំនួរ : ដូច្នេះ តើរដ្ឋមានអ្វីសំរាប់ផ្គត់ផ្គង់យុទ្ធជន ដែរទៅប្រយុទ្ធនៅជួរមុខ ?

តាម៉ុក : រដ្ឋមិនយកពន្ធទេ ! តែនៅឆ្នាំនេះ មានធ្វើបុណ្យឧបត្ថម្ភកងទ័ព ២ដង បានពីរម៉ឺនបាត ។ ឯរឿងឧបត្ថម្ភកងទ័ព គឺលុយជាតិដែល រដ្ឋរកបាន រដ្ឋធ្វើ ។

សំនួរ : តើរកពីណាមក ?

តាម៉ុក : តាមធម្មតា ! អាហ្នឹង ពីនោះពីនេះ ពីព្រៃឈើអីបានខ្លះ ។

សំនួរ : ព្រៃជាចំណូលធំរបស់អន្លង់វែង ! ដូចខ្ញុំបានឃើញគរទុកជាច្រើននោះ តែចុងក្រោយនេះ ឃើញឈើហាក់ដូចជាអត់លក់បានទេ ព្រោះឈើគរចោល កំពុងតែខូចបន្តិចម្តងៗហើយ ។

តាម៉ុក : បាទ ! តែចេះតែសន្សំលុយ ដែលមានតិចតួច ព្រោះយើងខ្ញុំមិនមែនជាអ្នកខ្ជះខ្ជាយទេ ! លុយកាក់នេះ គឺប្រយ័ត្នប្រយែងណាស់ មិនមែនសេរីអីដែរ ! ទាំងរដ្ឋ ទាំងប្រជាជន សន្សំម៉ាំណាស់ ។ គោក្របីអីក៏ដោយមុននឹងចាយ មុននឹងលក់ប្រយ័ត្នណាស់ មិនសេរី ទាល់តែអស់គោនោះទេ ! លែងបៀរ អាប៉ោងអីអត់ មានទេ ! ក្នុងរបបខ្ញុំ គ្មានលេងសើច អបាយមុខទេ ។ ដល់អញ្ចឹងលក់វាសល់ លុយវាសំរាប់តែជីវិត ! ឥតអ្នកណាមាន ឥតអ្នកណាកេងប្រវ័ញ្ច អ្នកណាបោកអីទេ ។ គ្មានបារម្ភណ៍ពីរឿងចោរលួចប្លន់ អត់មានទេ ! ដល់អញ្ចឹង ស្រែចំការ គោក្របី ចិញ្ចឹមស្រួលណាស់ តែបីឆ្នាំ គ្រួសារខ្ញុំរកបានជិត ១សែនបាតគ្រាន់តែចិញ្ចឹមគោតែមួយមុខ ។

សំណួរ : អាទិត្យចុងក្រោយនេះ បើសិនជាក្រុមផ្តាច់ខ្លួន និងលោក ហ៊ុន សែន វាយយកអន្លង់វែងបានគោទាំងអស់មុខជាត្រូវគេយកជាសម្បត្តិគេ ហើយខាងអន្លង់វែងមុខជាខូចខាត។ ខ្ញុំចង់សួរទៅផ្សារសេរីទីនេះ លុយដែលលក់បានមានយកទៅដាក់ធនាគារដែលលុយមិនបាត់ទៅណាដែរឬទេ ? នៅអន្លង់វែង តើមានគំរោងទៅដល់នោះឬទេ ? ដើម្បីឱ្យអ្នកស្រុកក្លាយទៅជា អ្នកមាន អ្នកបាន អាចសង់ផ្ទះថ្មអីនឹងគេ។

តាម៉ុក : ឥឡូវមិនទាន់គិតដល់ទេ ! តែនៅអនាគត ត្រូវតែធ្វើដូចគេឯង ព្រោះរស់នៅលើលោកនេះ ខុសគេម៉េចនិងកើត ? ត្រូវតែរស់នៅ ដូចគេដូចឯង លើលោកពិសេសលោកសេរី និង ហើយ ។ វាគ្មានផ្លូវឯណាចេញរួចទេឥឡូវនេះ មានលោកឯណាពីនោះ ? មានតែមួយទេ ! មានតែលោកសេរី របបសេរី ពហុបក្សរបបសភា ។ គោក្របី ក៏អញ្ចឹងដែរ មិនមែនអ្នកទទួលខុសត្រូវអន្លង់វែង មិនគិតគូរនោះទេ ។ ខ្ញុំគិតប៉ាន់ ជាលុយគោទាំងអស់ហ្នឹងប្រហែលជា៣០លានបាត ។ រដ្ឋចង់ទិញដែរ តែរដ្ឋរកលុយ៣០លាន ទៅទិញក៏តឹងដែរ ហើយកំពុងតែចរចារកអ្នកទិញ ! មិនមែនឱ្យអា ហ៊ុន សែន ទេ ! វាគ្មានសមត្ថភាពអីមកវាយយកគោអន្លង់វែងទេ !

សំនួរ : ចុះប្រជាជនដែលកំពុងតែចេញពីអន្លង់វែងភៀសខ្លួនទៅតាមទល់ដែនថៃ តើមានអ្នកដែលមានលុយខ្ចប់ជាប់នឹងខ្លួនដែរ ឬទេ?

តាម៉ុក : មាន ! ១សែន ទៅ២សែន គេមិនអត់ទេ អ្នកខ្លះបែប ៥សែនផង ក៏មិនដឹង !

សំនួរ : តើពេលណាទៅទើបឱ្យប្រជាពលរដ្ឋទាំងនោះ ត្រឡប់មកលំនៅដ្ឋានគេវិញ?

តាម៉ុក : ថ្ងៃនេះ ថ្ងៃស្អែក ពីថ្ងៃនេះ ត្រឡប់មកវិញហើយ!

សំនួរ : មានជនភៀសខ្លួនខ្លះចេញទៅប្រទេសថៃ គេយកទៅព្យាបាលខ្លួននៃជំរុំភាប់ឆើង គេនិយាយថា មានចំនួន២ទៅ៣នាក់ហើយ តើអ្នកទាំងនោះ ទៅពីនេះទៅឬ ?

តាម៉ុក : ខាងនេះអត់មានទេ ! ខាងព្រះវិហារ អត់ទាន់មានទេ បើទោះជាទៅ ក៏គេត្រឡប់មកផ្ទះសម្បែងគេវិញដែរ ។

សំនួរ : ចុះកុមារទាំងអស់នៅអន្លង់វែងដែលទៅមុខនេះ មានបានរៀនសូត្រអីទេ ឬក៏សាលារៀនបិទអស់ទៅហើយ?

តាម៉ុក : ៣ថ្ងៃនេះ បិទហើយ!

សំនួរ : តើមានអង្គការអន្តរជាតិណា ចូលមកជួយសាលា ដើម្បីឱ្យកម្រិតវិជ្ជា ខ្ពង់ខ្ពស់ស្មើ និងគេទេ ?

តាម៉ុក : ឥឡូវមិនទាន់មានទេ ! ថ្ងៃក្រោយ បើអត់មានបញ្ហាអ្វីទេ ម៉េចដែលគេហៅថាលោកសេរី ឱ្យតែមានគេជួយស្វាគមន៍មិនមែនទទួលជំនួយតែកុមារា កុមារីទេ ជំនួយខាងសុខភាព អនាម័យ ពេទ្យអ្វីៗ ទទួលទាំងអស់ ។ តែជំនួយត្រូវឥតចំណង ជំនួយដែលត្រឹមត្រូវស្មើភាព ពួកខ្ញុំ មិនរស់បែបឯកោម្នាក់ឯង មិនកើតទេ !

អន្លង់វែង គ្មានមនុស្សសុំទាន គ្មានមនុស្សកើតអេសដី គឺមនុស្សដែលស្រឡាញ់ពលកម្មជាអ្នកស្នេហាជាតិ គឺមានតួនាទីកសាងប្រទេស ដោយកាប់គាស់រុករានដី ដោយខ្លួនឯង ហូបចុក ខ្លួនឯង ចិញ្ចឹមខ្លួនឯង ទាំងគោ ទាំងមាន់ជ្រូក ។ មិនត្រឹមតែមិនទិញទេ តែលក់ឱ្យគេទៀត គោក៏ លក់ ជ្រូកក៏លក់ ៕

Hosted by: Mt Enon Community Outreach (MECO)

FREE!

ពិពណ៌សុខភាពឆ្នាំ ២០០៨ របស់ពហុវប្បធម៌

MULTI-CULTURAL HEALTH FAIR 2008

SATURDAY, AUGUST 23, 2008
12:00 PM-5:00 PM
5TH STREET & SNYDER AVENUE
PHILADELPHIA, PA 19148
Rain Date: Sunday, August 24, 2008
1:00 PM-6:00 PM
For more info: 215-334-1074

HEALTH SCREENINGS AND MEDICAL INFORMATION FOR THE ENTIRE FAMILY!
FREE FOOD, MUSIC, ENTERTAINMENT AND PRIZES.
*Special performance by Chaz Shepherd, from Oprah's *The Color Purple**

សូមអញ្ជើញមកចូលរួមដោយឥតគិតថ្លៃ

ថ្ងៃសៅរ៍ទី ២៣ ខែ សីហា ឆ្នាំ ២០០៨ ពីម៉ោង ១២:០០ ដល់ ម៉ោង ៥ រសៀល នៅផ្លូវលេខ៥ នឹង SNYDER Ave. ហ្វីឡាដែលហ្វីយ៉ាខាងត្បូង ពិនិត្យសុខភាព នឹងផ្តល់ពត៌មានសំរាប់ព្យាបាលជូនដល់ក្រុមគ្រួសារទាំងអស់ ជូនម្ហូបអាហារ មានភ្លេងសិល្បៈ និងរង្វាន់ សំដែងសិល្បៈ ពិសេសដោយក្រុមរបស់ OPRAH´S

SCREENINGS FOR:
Blood Pressure
Cholesterol
Diabetes
Prostate Cancer
HIV
Asthma
COPD
Body Fat
Vision

INFORMATION ON:
Nutrition & Exercise
HPV Vaccine (Gardasil)
Family Planning
Breast Cancer
Dental Care
HIV/AIDS
Smoking Cessation
Hepatitis B & C
Depression

ពិនិត្យសុខភាព
លើសឈាម
ខ្លាញ់ក្នុងឈាម
ទឹកនោមផ្អែម
កង់ស៊ែប្រូស្តាត
HIV , ហឺត
ធាត់ឡើងទម្ងន់
ភ្នែក

ពត៌មានពី :
ម្ហូបអាហារ និងហាត់ប្រាណ
HPV (ចាក់ថ្នាំបង្ការ)
គម្រោងគ្រួសារ
មហារីកដោះ
ថែធ្មេញ
HIV / AIDS
ឈប់ជក់បារី
អេប៉ាតាយទីស B&C
អារម្មណ៍មិនល្អ

SUPPORTERS

ORGANIZATIONS

AmeriChoice
Bristol-Myers Squibb
Eli Lilly
Evercare
Novo Nordisk
GlaxoSmithKline
Grays Ferry Medical Center
Keystone Mercy
Merck
Mt. Enon Community Outreach
Pfizer
Young's Medical Equipment
AstraZeneca
Health Partners
Bayer
Shop Rite
Southeastern Asian Mutual Assistance Associations Coalition (SEAMAAC)
Mexican Consulate
Quest Diagnostics
Boehringer Ingelheim

PROVIDERS

Dr. Donna Carstens
Dr. Nimida Oviedo
Dr. Ngoc Phan
Dr. Clement Au
Sandy McCarthy, PA
Dr. Jacque Curtis
Dr. Carver Hills
Dr. Lisa Schaffer
Audrey Fisher, PA
Dr. Melissa
Sharon Kneenbush, NP
Dr. Cheung Yeah
Dr. Joseph Cassan
Dr. David Yuan
Paula Larson, NP
Dr. James Smith
Dr. Kim Thai
Dr. Phuong Trinh
Dr. Donna Jones
Dr. George Fisher
Dr. Anthony Lutano

Bayer HealthCare Diabetes Care
Bristol-Myers Squibb
Boehringer Ingelheim
MERCK SERVICES.
Evercare
SEAMAAC
AmeriChoice
KEYSTONE MERCY
gsk
Lilly
AstraZeneca